# គោលការណ៍ណែនាំអាស៊ាន

## ស្តីពីការធានាគុណភាព និង ការទទួលស្គាល់ ប្រព័ន្ធផ្តល់គុណវុឌ្ឍិសមត្ថភាព

ចក្ខុវិស័យតែមួយ
អត្តសញ្ញាណតែមួយ
សហគមន៍តែមួយ

# គោលការណ៍ណែនាំអាស៊ាន

# ស្តីពី

# ការធានាគុណភាព និងការទទួលស្គាល់

# ប្រព័ន្ធផ្តល់គុណវុឌ្ឍសមត្ថភាព

សមាគមនៃប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន) ត្រូវបានបង្កើតឡើងនៅថ្ងៃទី០៨ ខែសីហា ឆ្នាំ១៩៦៧។ ប្រទេសជាសមាជិករួមមាន ប្រ៊ុយណេ កម្ពុជា ឥណ្ឌូនេ-ស៊ី ឡាវ ម៉ាឡេស៊ី ភូមា ហ្វីលីពីន សិង្ហបុរី ថៃ និងវៀតណាម។ លេខាធិការដ្ឋានអាស៊ានមានទីតាំង នៅទីក្រុងហ្សាការតា ប្រទេសឥណ្ឌូនេស៊ី។

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនង៖
ផ្នែកទំនាក់ទំនងសហគមន៍-Community Relations Division (CRD) នៃលេខាធិការដ្ឋានអាស៊ាន
70A Jalan Sisingamangaraja, Jakarta 12110
សាធារណប្រទេសឥណ្ឌូនេស៊ី
ទូរស័ព្ទ៖ (៦២ ២១) ៧២៤-៣៣៧២, ៧២៦-២៩៩១
ទូរសារ៖ (៦២ ២១) ៧៣៩-៨២៣៤, ៧២៤-៣៥០៤
អ៊ីម៉ែល៖ public@asean.org

ព័ត៌មាននៃការបោះពុម្ពផ្សាយ
គោលការណ៍ណែនាំអាស៊ានសម្រាប់ការធានាគុណភាព និងការទទួលស្គាល់ប្រព័ន្ធផ្ដល់គុណវុឌ្ឍសមត្ថភាព
ទីក្រុងហ្សាការតា លេខាធិការដ្ឋានអាស៊ាន ខែសីហា ឆ្នាំ២០១៦

៣៣១, ១១៤
អាស៊ាន-ស្តង់ដា-ធនធានមនុស្ស
គុណវុឌ្ឍ-ជំនាញ-គោលការណ៍ណែនាំ

ISBN 978-602-5798-58-0

9 786025 798580

អាស៊ាន៖ សហគមន៍ដែលពោរពេញដោយឱកាស

អត្ថបទបោះពុម្ពនេះ អាចដកស្រង់ ឬបោះពុម្ពឡើងវិញបានដោយសេរី ដែលត្រូវបញ្ជាក់ហេតុផលសមរម្យ និងជូនភ្ជាប់នូវឯកសារគាំទ្រដល់ការបោះពុម្ពឡើងវិញនោះផ្ញើទៅកាន់ផ្នែកទំនាក់ទំនងសហគមន៍ (CRD) របស់លេខាធិការដ្ឋានអាស៊ាន ទីក្រុងហ្សាការតា។

ព័ត៌មានទូទៅស្ដីអំពីអាស៊ាន មាននៅលើគេហទំព័រ៖ www.asean.org

រក្សាសិទ្ធិដោយសមាគមនៃប្រជាជាតិអាស៊ីអាគ្នេយ៍ (ASEAN) ឆ្នាំ២០១៦។
សូមរក្សាសិទ្ធិគ្រប់យ៉ាង។

# សេចក្តីថ្លែងអំណរគុណ

គោលការណ៍ណែនាំអាស៊ានស្តីពីការធានាគុណភាព និងការទទួលស្គាល់ប្រព័ន្ធផ្តល់គុណវុឌ្ឍិសមត្ថភាព គឺជាគម្រោងផែនការដែលដាក់នៅក្នុងកម្មវិធីការងាររបស់រដ្ឋមន្ត្រីការងារអាស៊ាន ឆ្នាំ២០១០-២០១៥ និងបានរៀបចំដោយកិច្ចប្រជុំមន្ត្រីជាន់ខ្ពស់ការងារអាស៊ាន (SLOM) ក្រោមការសម្របសម្រួល នៃអាជ្ញាធរផ្តល់គុណវុឌ្ឍិវិជ្ជាជីវៈឥណ្ឌូនេស៊ី (BNSP) និងក្រសួងធនធានមនុស្ស នៃប្រទេសឥណ្ឌូនេស៊ី សហការជាមួយអង្គការអន្តរជាតិទេសន្តរប្រវេសន៍ (IOM) និងលេខាធិការដ្ឋានអាស៊ាន។ គោលការណ៍ណែនាំអាស៊ាននេះ ត្រូវបានអនុម័តដោយកិច្ចប្រជុំរដ្ឋមន្ត្រីការងារអាស៊ាន (ALMM) លើកទី២៤ នៅថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០១៦ នៅទីក្រុងវៀងចន្ទន៍ ប្រទេសឡាវ។

គោលការណ៍ណែនាំអាស៊ាននេះ មានបំណងផ្តល់ជាមូលដ្ឋានសម្រាប់ការអភិវឌ្ឍនូវទំនុកចិត្ត និងយល់ដឹងអំពីក្របខណ្ឌជាតិ និងប្រព័ន្ធផ្តល់គុណវុឌ្ឍិសមត្ថភាពនៃបណ្តាប្រទេសជាសមាជិកអាស៊ានទាំងអស់ និងផ្តល់គោលការណ៍ និងពិធីសារសម្រាប់អភិវឌ្ឍដំណើរការនៃការទទួលស្គាល់ប្រព័ន្ធទាំងនេះ។ ការរួមបញ្ចូលជាមួយនឹងក្របខណ្ឌគុណវុឌ្ឍិយោងអាស៊ាន ត្រូវបានយកមកពិចារណាក្នុងការអភិវឌ្ឍគោលការណ៍ណែនាំអាស៊ាននេះ ដូចដែលត្រូវបានរំពឹងទុកថាអាចបំពេញបន្ថែមដល់ក្របខណ្ឌគុណវុឌ្ឍិយោងអាស៊ាន។ ការប្រើប្រាស់គោលការណ៍ណែនាំអាស៊ាននាពេលអនាគត នឹងត្រូវស្ម័គ្រចិត្តដោយប្រទេសសមាជិកអាស៊ាន ដែលត្រៀមខ្លួនជាស្រេច ដើម្បីធ្វើការផ្តួចផ្តើមទៅវិញទៅមកលើស្តង់ដាជំនាញ និងមុខរបរពិតប្រាកដរបស់គេ។

សូមផ្តល់ការកោតសរសើរចំពោះកិច្ចប្រជុំមន្ត្រីជាន់ខ្ពស់ការងារអាស៊ានរបស់ប្រទេសជាសមាជិកអាស៊ានទាំង១០ ចំពោះការចែករំលែកចំណេះដឹង និងការជួយគាំទ្រតាមរយៈសេចក្តីព្រាង និងការពិនិត្យមើលឡើងវិញទៅលើគោលការណ៍ណែនាំអាស៊ាន។ ក្នុងនោះផងដែរ ក៏សូមថ្លែងអំណរគុណចំពោះរាជរដ្ឋាភិបាលជប៉ុន ដែលបានបន្តការគាំទ្ររបស់ខ្លួនតាមរយៈការផ្តល់មូលនិធិសមាហរណកម្មអាស៊ាន-ជប៉ុន (JAIF) ដល់ការអភិវឌ្ឍគោលការណ៍ណែនាំរបស់អាស៊ាននេះ។ ជាទីបញ្ចប់ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ លោកស្រី Andrea Bateman អ្នកពិគ្រោះយោបល់ និងលោក Bonardo Aldo Tobing អ្នកសម្របសម្រួលគម្រោង ចំពោះការគាំទ្រផ្នែកបច្ចេកទេស។

# មាតិកា

**បញ្ជីតារាង** ........................................ ១

**អក្សរកាត់** ........................................ ២

**សន្ទានុក្រមនៃពាក្យបច្ចេកទេសសំខាន់ៗ** ........................................ ៣

**សេចក្តីផ្តើម** ........................................ ៧

**ផ្នែកទី១៖** ទិដ្ឋភាពទូទៅនៃក្របខណ្ឌគុណវុឌ្ឍិជាតិ (ក.គ.ជ) របស់ប្រទេសជាសមាជិកអាស៊ាន ........................................ ១០

**ផ្នែកទី២៖** ទិដ្ឋភាពទូទៅនៃប្រព័ន្ធផ្តល់គុណវុឌ្ឍិសមត្ថភាពរបស់ប្រទេសជាសមាជិកអាស៊ាន ........................................ ១៦

**ផ្នែកទី៣៖** ទិដ្ឋភាពសំខាន់ៗនៃការធានាគុណភាព ........................................ ២៦

**ផ្នែកទី៤៖** គោលការណ៍ណែនាំ និងពិធីសារសម្រាប់ការធានាគុណភាព ........................................ ៣៦

**ផ្នែកទី៥៖** គោលការណ៍ណែនាំនិងពិធីសារសម្រាប់ទទួលស្គាល់ប្រព័ន្ធផ្តល់គុណវុឌ្ឍិសមត្ថភាពរបស់ប្រទេសជាសមាជិកអាស៊ាន ........................................ ៤២

**ផ្នែកទី៦៖** ការចូលរួមនៅក្នុងសកម្មភាពផ្គូផ្គងថ្នាក់ជាតិ ........................................ ៤៦

**ឧបសម្ព័ន្ធ៖** ក្របខណ្ឌធានាគុណភាពអន្តរជាតិ ........................................ ៤៩

**ឯកសារយោង** ........................................ ៥២

**ស្ថាប័ន/អង្គភាពមានសមត្ថកិច្ចរបស់ប្រទេសជាសមាជិកអាស៊ាន** ........................................ ៥៣

# បញ្ជីតារាង

**តារាងទី១៖** សេចក្តីសង្ខេបក្របខណ្ឌគុណវុឌ្ឍិជាតិ (ក.គ.ជ) ........ ១០

**តារាងទី២៖** សេចក្តីសង្ខេបរចនាសម្ព័ន្ធនៃក្របខណ្ឌគុណវុឌ្ឍិជាតិ ........ ១១

**តារាងទី៣៖** ក្របខណ្ឌគុណវុឌ្ឍិជាតិថៃ ........ ១៧

**តារាងទី៤៖** កម្រិតជំនាញ ........ ១៨

**តារាងទី៥៖** កម្រិតគុណវុឌ្ឍិជំនាញជាតិវៀតណាម ........ ១៨

**តារាងទី៦៖** និយមន័យនៃវាក្យសព្ទសមត្ថភាព ........ ២០

**តារាងទី៧៖** សូចនាករគុណភាពនៃក្របខណ្ឌធានាគុណភាព អ.ប.វ នៃកិច្ចប្រជុំកំពូលអាស៊ីបូព៌ា ........ ៥០

# អក្សរកាត់

| | |
|---|---|
| ក.ប.រ.ក.អ<br>ALMM | កិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីការងារអាស៊ាន<br>ASEAN Labour Ministers Meeting |
| ប.ស.អ<br>AMS | ប្រទេសជាសមាជិកអាស៊ាន<br>ASEAN Member States |
| ក.គ.យ.អ<br>AQRF | ក្របខណ្ឌគុណវុឌ្ឍិយោងអាស៊ាន<br>ASEAN Qualifications Reference Framework |
| ទ.ជ.ផ.វ.វ<br>BNSP | ទីភ្នាក់ងារជាតិសម្រាប់ការផ្តល់វិញ្ញាបនបត្រវិជ្ជាជីវៈ<br>Badan Nasional Sertifikasi Profesi |
| ក.ធ.គ.អ.ប.វ ក.ប.អ.ប<br>EAS TVET QAF | ក្របខណ្ឌធានាគុណភាពការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ<br>នៃកិច្ចប្រជុំកំពូលអាស៊ីបូព៌ា<br>East Asia Summit Technical and Vocational Education and Training Quality Assurance Framework |
| អ.ធ.ម<br>HRD | ការអភិវឌ្ឍធនធានមនុស្ស<br>Human Resource Development |
| ប.អ.ធ.គ.ឧ<br>INQAAHE | បណ្តាញអន្តរជាតិសម្រាប់ទីភ្នាក់ងារធានាគុណភាពនៅឧត្តមសិក្សា<br>The International Network for Quality Assurance Agencies in Higher  Education |
| អ.យ.គ<br>MOU | អនុស្សរណៈនៃការយោគយល់គ្នា<br>Memorandum of Understanding |
| ក.គ.ជ<br>NQF | ក្របខណ្ឌគុណវុឌ្ឍិជាតិ<br>National Qualification Framework |
| ក.គ<br>QF | ក្របខណ្ឌគុណវុឌ្ឍិ<br>Qualification Framework |
| ក.ប.ម.ជ.ក.អ<br>SLOM | កិច្ចប្រជុំមន្ត្រីជាន់ខ្ពស់ការងារអាស៊ាន<br>ASEAN Senior Labour Officials Meeting |
| អ.ប.វ<br>TVET | ការអប់រំបណ្តុះបណ្តាលបច្ចេកទេស  និងវិជ្ជាជីវៈ<br>Technical Vocational Education and Training |

## សទ្ទានុក្រមនៃពាក្យបច្ចេកទេសសំខាន់ៗ

ពាក្យបច្ចេកទេសខាងក្រោមនេះ ត្រូវបានឯកភាពដោយប្រទេសជាសមាជិកអាស៊ាន។ ជាពិសេសពាក្យដែលមានសញ្ញា [*] ត្រូវបានព្រមព្រៀងគ្នានៅក្នុងក្របខណ្ឌគុណវុឌ្ឍិយោងអាស៊ាន។

| ពាក្យបច្ចេកទេស | និយមន័យ |
|---|---|
| ការទទួលស្គាល់គុណភាព* | ការអនុម័តជាផ្លូវការនៃស្តង់ដាសមិទ្ធផលរាប់បញ្ចូលទាំងគុណវុឌ្ឍិ ឬផ្នែកនៃគុណវុឌ្ឍិ ដែលឆ្លើយតបទៅនឹងលក្ខខណ្ឌតម្រូវជាក់ស្តែង ដែលកំណត់ដោយអង្គភាពទទួលស្គាល់គុណភាពអប់រំ។ ជាធម្មតាការទទួលស្គាល់គុណភាពមានរយៈពេលកំណត់ជាក់លាក់មួយ។ |
| គុណវុឌ្ឍិដែលបានទទួលស្គាល់គុណភាព* | គុណវុឌ្ឍិដែលត្រូវបានផ្តល់ការអនុម័តដោយទីភ្នាក់ងារ ឬស្ថាប័ន/អង្គភាពទទួលស្គាល់គុណភាព នៅពេលឆ្លើយតបនឹងលក្ខខណ្ឌតម្រូវជាក់លាក់ ឬស្តង់ដាគុណភាព។ |
| ទីភ្នាក់ងារទទួលស្គាល់គុណភាពអប់រំ* | ទីភ្នាក់ងារទទួលស្គាល់គុណភាពអប់រំ គឺជាស្ថាប័ន/អង្គភាពមានសមត្ថកិច្ច (ដូចជា ទីភ្នាក់ងារផ្តល់គុណវុឌ្ឍិជាតិ ទីភ្នាក់ងារទទួលស្គាល់គុណភាពអប់រំថ្នាក់ជាតិ ក្រុមប្រឹក្សាត្រួតពិនិត្យ ឬស្ថាប័ន ឬទីភ្នាក់ងារផ្សេងៗទៀត ដែលទទួលខុសត្រូវក្នុងការអនុម័តគុណវុឌ្ឍិ) ដែលគ្រប់គ្រងកម្មវិធី និងការទទួលស្គាល់គុណវុឌ្ឍិដែលស្ថិតក្រោមច្បាប់ជាតិ។ ទីភ្នាក់ងារទទួលស្គាល់គុណភាពអប់រំ ត្រូវអនុវត្តតួនាទីរបស់ខ្លួនក្នុងក្របខណ្ឌដែល បានកំណត់ក្នុងប្រព័ន្ធធានាគុណភាព។ |
| ស្តង់ដាសមិទ្ធផល | សេចក្តីថ្លែងដែលបានអនុម័ត និងយល់ព្រមឱ្យប្រើជាផ្លូវការដោយស្ថាប័ន/អង្គភាពមានសមត្ថកិច្ច ដែលកំណត់នូវវិធាននានាក្នុងការអនុវត្តតាមបរិបទដែលបានផ្តល់ជូន ឬលទ្ធផលដែលត្រូវសម្រេចបាន។<br>ភាពខុសគ្នាអាចត្រូវបានធ្វើឡើងរវាងស្តង់ដាសមត្ថភាព ស្តង់ដាអប់រំ ស្តង់ដាមុខរបរ ឬស្តង់ដានៃការផ្តល់គុណវុឌ្ឍិ៖<br>• ស្តង់ដាសមត្ថភាព សំដៅចំពោះចំណេះដឹង ចំណេះធ្វើ/ជំនាញ និង/ឬសមត្ថភាព ដែលទាក់ទងនឹងការអនុវត្តមុខរបរណាមួយ<br>• ស្តង់ដាអប់រំ សំដៅចំពោះសេចក្តីថ្លែងនៃលទ្ធផលសិក្សា មាតិកានៃកម្មវិធីសិក្សា តម្រូវការចូលសិក្សា និងធនធានតម្រូវឱ្យត្រូវនឹងគោលដៅសិក្សា<br>• ស្តង់ដាវាយតម្លៃសមត្ថភាព សំដៅចំពោះសេចក្តីថ្លែងនៃលទ្ធផលសិក្សាដែលត្រូវវាយតម្លៃ និងវិធីសាស្ត្រដែលត្រូវប្រើប្រាស់<br>• ស្តង់ដាមុខរបរ សំដៅចំពោះសេចក្តីថ្លែងនៃសកម្មភាព និងកិច្ចការដែលពាក់ព័ន្ធ មុខរបរជាក់លាក់ណាមួយ និងការអនុវត្តចំពោះកិច្ចការនោះ<br>• ស្តង់ដានៃការផ្តល់គុណវុឌ្ឍិ សំដៅចំពោះសេចក្តីថ្លែងនៃវិធានដែលអាចអនុវត្តដើម្បីទទួលបាននូវគុណវុឌ្ឍិ (ឧទាហរ-ណ៍៖ វិញ្ញាបនបត្រ ឬសញ្ញាបត្រ) ព្រមទាំងសិទ្ធដែលបានប្រគល់ឱ្យ។ [1] |
| ក្របខណ្ឌគុណវុឌ្ឍិយោងអាស៊ាន | ក្របខណ្ឌគុណវុឌ្ឍិយោងអាស៊ាន ជាក្របខណ្ឌយោងរួមមួយ ដែលមានមុខងារជាឧបករណ៍សម្រាប់ធ្វើការប្រៀបធៀបគុណវុឌ្ឍិជាតិរវាងប្រទេសជាសមាជិកអាស៊ាន។ |
| ការផ្តល់គុណវុឌ្ឍិ | ដំណើរការនៃការចេញវិញ្ញាបនបត្រ សញ្ញាបត្រ ឬចំណងជើងលទ្ធផលសិក្សាដែលបញ្ជាក់ជាផ្លូវការថា សំណុំនៃលទ្ធផលសិក្សា (ចំណេះដឹង របៀបធ្វើ ជំនាញ និង ឬសមត្ថភាព) បុគ្គលម្នាក់ទទួលបានដោយវាយតម្លៃសមត្ថភាព និងផ្តល់សុពលភាពដោយស្ថាប័ន/អង្គភាពមានមានសមត្ថកិច្ចផ្អែកលើស្តង់ដាកំណត់។ [2] |
| កម្រងសមត្ថភាពសម្រាប់ការផ្តល់គុណវុឌ្ឍិ | កម្រងសមត្ថភាពសម្រាប់ការផ្តល់គុណវុឌ្ឍិ គឺជាសមត្ថភាព និងលក្ខខណ្ឌតម្រូវផ្សេងៗទៀតដែលទាក់ទងនឹងប្រភេទនៃមុខរបរជាក់លាក់។[3] វាអាចជាលទ្ធផលដែលជាវិញ្ញាបនបត្រសមត្ថភាព ដែលបង្ហាញថាបុគ្គលម្នាក់បានបំពេញនូវរាល់លក្ខ-ខណ្ឌតម្រូវដែលកំណត់ក្នុងគុណវុឌ្ឍិមួយ។ |

[1] Cedefop (2011), p. 109
[2] Cedefop (2011), p. 16
[3] Adapted from ISO/IEC 17024:2012

| | |
|---|---|
| ស្ថាប័ន/អង្គភាពផ្តល់ការបញ្ជាក់ និង/ឬផ្តល់គុណវុឌ្ឍិ* | ស្ថាប័ន/អង្គភាពនៃការផ្តល់គុណវុឌ្ឍិ (ឧទាហរណ៍៖ វិញ្ញាបនបត្រ សញ្ញាបត្រ ឬលិខិតបញ្ជាក់) ដែលទទួលស្គាល់ជាផ្លូវការនូវលទ្ធផលសិក្សា (ចំណេះដឹង ជំនាញ និង/ឬសមត្ថភាព) របស់បុគ្គលម្នាក់ៗសម្រេចបានដោយអនុវត្តតាមនីតិវិធីវាយតម្លៃសមត្ថភាព និងការផ្តល់សុពលភាព។ [4] |
| សមត្ថភាព* | សមត្ថភាព គឺជាភាពប៉ិនប្រសប់លើសពីចំណេះដឹង និងជំនាញដែលបុគ្គលម្នាក់ៗមាន។ សមត្ថភាពរួមមាន៖<br>• សមត្ថភាពក្នុងការគិត គឺជាការប្រើប្រាស់ទ្រឹស្តី និងគោលគំនិត ព្រមទាំងចំណេះដឹងក្រៅផ្លូវការ ដែលទទួលបានតាមរយៈបទពិសោធន៍<br>• សមត្ថភាពផ្នែកមុខងារ (ជំនាញ ឬការយល់ដឹងពីរបៀបធ្វើ) គឺជាសមត្ថភាព ដែលបុគ្គលម្នាក់ៗធ្វើបានលើការងារដែលគេប្រគល់ឱ្យតាមជំនាញរបស់ខ្លួន<br>• សមត្ថភាពផ្ទាល់ខ្លួន គឺការយល់ដឹងពីរបៀបដឹកនាំខ្លួនឯងនៅក្នុងស្ថានភាពជាក់លាក់មួយ<br>• សមត្ថភាពផ្នែកក្រមសីលធម៌ គឺការប្រកាន់ខ្ជាប់នូវគុណតម្លៃផ្ទាល់ខ្លួន និងវិជ្ជាជីវៈជាក់លាក់។ [5] |
| ស្តង់ដាសមត្ថភាព* | សេចក្តីថ្លែងអំពីវិធាននានាសម្រាប់កំណត់កិច្ចការត្រូវអនុវត្ត ឬលទ្ធផលសម្រេចបាន ដែលបានអនុម័ត និងចុះហត្ថលេខាដាក់ឱ្យប្រើប្រាស់ជាផ្លូវការដោយស្ថាប័ន/អង្គភាពមានសមត្ថកិច្ច។<br>ស្តង់ដាសមត្ថភាព សំដៅលើចំណេះដឹង ជំនាញ និង/ឬសមត្ថភាពដែលផ្សារភ្ជាប់ទៅនឹងមុខរបរជាក់លាក់ណាមួយ។ [6] |
| ស្តង់ដាមុខរបរ* | សេចក្តីថ្លែងអំពីវិធាននានាសម្រាប់កំណត់កិច្ចការត្រូវអនុវត្ត ឬលទ្ធផលសម្រេចបាន ដែលបានអនុម័ត និងចុះហត្ថលេខាដាក់ឱ្យប្រើប្រាស់ជាផ្លូវការដោយស្ថាប័ន/អង្គភាពមានសមត្ថកិច្ច។<br>ស្តង់ដាមុខរបរ សំដៅលើសកម្មភាព និងកិច្ចការដែលផ្សារភ្ជាប់ទៅនឹងមុខរបរជាក់លាក់ណាមួយ និងការអនុវត្តនូវសកម្មភាព និងកិច្ចការទាំងនោះ។ [7] |
| អង្គភាពផ្តល់សេវា* | អង្គភាពដែលធ្វើផែនការ ផ្តល់សេវាអប់រំ/បណ្តុះបណ្តាល និងវាយតម្លៃសមត្ថភាពដើម្បីទទួលបានការផ្តល់គុណវុឌ្ឍិ ឬផ្នែកនៃគុណវុឌ្ឍិ។ |
| គុណវុឌ្ឍិ* | គុណវុឌ្ឍិ គឺជាវិញ្ញាបនបត្រ ឬសញ្ញាបត្រផ្លូវការដែលផ្តល់ដោយស្ថាប័ន/អង្គភាពមានសមត្ថកិច្ច ក្នុងការទទួលស្គាល់បុគ្គលណាម្នាក់ថា មានសមត្ថភាពសម្រេចបានលទ្ធផលសិក្សា ឬសមត្ថភាពតាមស្តង់ដាដែលបានកំណត់តាមចំណងជើងគុណវុឌ្ឍិណាមួយ ដែលជាធម្មតាជាប្រភេទនៃវិញ្ញាបនបត្រ ឬកម្រិតសញ្ញាបត្រ។ ការសិក្សា និងការវាយតម្លៃសមត្ថភាពសម្រាប់ទទួលបានគុណវុឌ្ឍិអាចធ្វើទៅបានសម្រាប់អ្នកដែលមានបទពិសោធន៍នៅកន្លែងការងារ និង/ឬអ្នកដែលបានឆ្លងកាត់កម្មវិធីបណ្តុះបណ្តាលណាមួយ។ គុណវុឌ្ឍិផ្តល់ការទទួលស្គាល់ជាផ្លូវការនូវគុណតម្លៃនៅក្នុងទីផ្សារការងារ និងការអប់រំបណ្តុះបណ្តាលបន្ថែម។ [8] |
| ក្របខណ្ឌគុណវុឌ្ឍិ* | ជាឧបករណ៍សម្រាប់ធ្វើការអភិវឌ្ឍ និងចំណាត់ថ្នាក់គុណវុឌ្ឍិ (ឧទាហរណ៍៖ កម្រិតថ្នាក់ជាតិ ឬតាមវិស័យ) ដោយយោងតាមសំណុំនៃលក្ខណវិនិច្ឆ័យ (ឧទាហរណ៍៖ ការពិពណ៌នាកម្រិតគុណវុឌ្ឍិ (Qualification Level Descriptors) ដែលអាចអនុវត្តបានទៅតាមកម្រិតជាក់លាក់នៃលទ្ធផលសិក្សា។ [9] |
| ប្រព័ន្ធគុណវុឌ្ឍិ* | ប្រព័ន្ធគុណវុឌ្ឍិ រាប់បញ្ចូលរាល់ទិដ្ឋភាពនៃសកម្មភាពទាំងអស់របស់ប្រទេសណាមួយក្នុងការធ្វើឱ្យមានការទទួលស្គាល់ការសិក្សា។ ប្រព័ន្ធទាំងនេះ រួមមាន មធ្យោបាយនៃការអភិវឌ្ឍនិងអនុវត្តគោលនយោបាយថ្នាក់ជាតិ ឬថ្នាក់តំបន់ស្តីពីគុណវុឌ្ឍិ ការរៀបចំផ្តល់គុណវុឌ្ឍិកម្រិតស្ថាប័ន ដំណើរការធានាគុណភាព ដំណើរការវាយតម្លៃសមត្ថភាព និងការផ្តល់គុណវុឌ្ឍិ ការទទួលស្គាល់ជំនាញ និងយន្តការផ្សេងៗទៀត ដែលផ្សារភ្ជាប់រវាងការអប់រំ និងការបណ្តុះបណ្តាលទៅនឹងតម្រូវការទីផ្សារ |

[4] Cedefop (2011), p. 10 & 11
[5] Coles & Werquin (2006), p. 23
[6] Cedefop (2011), p. 109
[7] Cedefop (2011), p. 109
[8] Coles & Werquin (2006), p 21 &22
[9] Cedefop (2011), p. 82

| | |
|---|---|
| | ការងារ និងសង្គមជាតិ។ ប្រព័ន្ធគុណវុឌ្ឍិអាចរួមបញ្ចូលនូវសកម្មភាពតិច ឬច្រើន និងមានភាពស៊ីសង្វាក់គ្នា។ លក្ខណៈពិសេសមួយនៃប្រព័ន្ធគុណវុឌ្ឍិអាចជាក្របខណ្ឌជាក់លាក់មួយនៃគុណវុឌ្ឍិ។ [10] |
| ការធានាគុណភាព* | ការធានាគុណភាព គឺជាសមាសភាគមួយនៃការគ្រប់គ្រងគុណភាព និង "ផ្តោតទៅលើការផ្តល់ទំនុកចិត្តថា លក្ខខណ្ឌតម្រូវគុណភាពត្រូវបានបំពេញ"។ [11]<br>ចំពោះសេវាអប់រំ និងបណ្តុះបណ្តាល ការធានាគុណភាពគឺសំដៅលើដំណើរការដែលបានគ្រោងទុក និងមានលក្ខណៈជាប្រព័ន្ធ ដើម្បីផ្តល់នូវទំនុកចិត្តក្នុងការរៀបចំដំណើរការបណ្តុះបណ្តាល និងការផ្តល់គុណវុឌ្ឍិក្នុងប្រព័ន្ធអប់រំ និងបណ្តុះបណ្តាល។ ការធានាគុណភាពត្រូវឱ្យប្រាកដថាបានការពារផលប្រយោជន៍ និងការវិនិយោគរបស់ភាគីពាក់ព័ន្ធនៅក្នុងកម្មវិធីអប់រំ និងបណ្តុះបណ្តាលដែលបានទទួលស្គាល់។ |
| ក្របខណ្ឌធានាគុណភាព* | សំណុំនៃគោលការណ៍ គោលការណ៍ណែនាំ ឧបករណ៍ និងស្តង់ដា ដែលប្រើជាឯកសារយោងគោល សម្រាប់ណែនាំឱ្យមានសង្គតិភាពដល់ការអនុវត្តសកម្មភាពធានាគុណភាព។ |
| សូចនាករគុណភាព* | តួលេខ ឬសមាមាត្រដែលបានទទួលស្គាល់ជាផ្លូវការ ត្រូវបានប្រើដើម្បីវិនិច្ឆ័យ និងវាយតម្លៃគុណភាពនៃការប្រតិបត្តិ។ [12] |
| គោលការណ៍គុណភាព* | បំណង និងទិសដៅរួមនៃក្របខណ្ឌធានាគុណភាព ឬការរៀបចំមួយដែលទាក់ទងទៅនឹងការធានាគុណភាព។ |
| ស្តង់ដាគុណភាព* | លក្ខខណ្ឌលម្អិតផ្នែកបច្ចេកទេសដែលអាចវាស់វែងបាន ហើយត្រូវបានបង្កើតឡើងដោយការមូលមតិគ្នាជាឯកច្ឆន្ទ និងត្រូវបានអនុម័តដោយអង្គភាពដែលទទួលស្គាល់ក្នុងកម្រិតជាតិ កម្រិតតំបន់ ឬកម្រិតអន្តរជាតិ។ គោលបំណងរបស់ស្តង់ដាគុណភាព គឺការបង្កើនប្រសិទ្ធភាពនៃធាតុចូល និង/ឬលទ្ធផលសិក្សា។ [13] |
| ប្រព័ន្ធធានាគុណភាព* | ប្រព័ន្ធធានាគុណភាព រាប់បញ្ចូលរាល់ទិដ្ឋភាពនៃសកម្មភាពទាំងអស់របស់ប្រទេសណាមួយ ដែលទាក់ទងនឹងការធានាគុណភាពនៃការអប់រំ និងការបណ្តុះបណ្តាល។ ប្រព័ន្ធទាំងនេះ រួមបញ្ចូលនូវធាតុដូចខាងក្រោម៖<br>• គោលបំណង និងស្តង់ដាមានលក្ខណៈច្បាស់លាស់ និងអាចវាស់វែងបាន ដែលជាគោលការណ៍ណែនាំសម្រាប់ការអនុវត្ត រួមទាំងការចូលរួមរបស់ភាគីពាក់ព័ន្ធ<br>• ធនធានសមស្រប<br>• វិធីសាស្ត្រវាយតម្លៃមានសង្គតិភាព រួមបញ្ចូលនូវស្វ័យវាយតម្លៃ និងការពិនិត្យឡើងវិញពីខាងក្រៅដោយអង្គភាពមានសមត្ថកិច្ចឯករាជ្យ<br>• យន្តការនៃការផ្តល់ព័ត៌មានត្រឡប់ និងនីតិវិធីសម្រាប់ការធ្វើការកែលម្អ<br>• លទ្ធផលនៃការវាយតម្លៃត្រូវបានផ្សព្វផ្សាយយ៉ាងទូលំទូលាយ |
| ការទទួលស្គាល់ | ការទទួលស្គាល់ផ្លូវការ គឺជាដំណើរការនៃការផ្តល់ការទទួលស្គាល់លទ្ធផលសិក្សា ដែលសម្រេចបានជាផ្លូវការចំពោះជំនាញ និងសមត្ថភាព តាមរយៈ៖<br>• ការផ្តល់ជូននូវគុណវុឌ្ឍិ (វិញ្ញាបនបត្រ សញ្ញាបត្រ ឬចំណងជើងគុណវុឌ្ឍិ) ដែលជាលទ្ធផលនៃការវាយតម្លៃសមត្ថភាព ឬ<br>• ការផ្តល់សមមូលភាពផ្នែកសមត្ថភាព ឬក្រេឌីត ឬលិខិតបញ្ជាក់សមត្ថភាព ការផ្តល់សុពលភាពលើជំនាញ និង/ឬសមត្ថភាពដែលសន្សំបាន<br>• ការទទួលស្គាល់ពីសង្គម គឺជាការទទួលស្គាល់ពីគុណតម្លៃនៃជំនាញ និង/ឬសមត្ថភាពដោយភាគីពាក់ព័ន្ធផ្នែកសេដ្ឋកិច្ច និងសង្គម។ [14] |

---

[10] Coles $ Werquin (2006), p.22
[11] AS/NZS ISO 9000:2006, P.9
[12] Cedefop Glossary (2011), p. 98
[13] Cedefop Glossary (2011), p. 98
[14] ស្របតាម Cedefop (2011), p.97

| | |
|---|---|
| ការផ្ទួផ្គង* | ការផ្ទួផ្គង គឺជាដំណើរការបង្កើតឱ្យមានទំនាក់ទំនងរវាងក្របខណ្ឌគុណវុឌ្ឍិជាតិ និងក្របខណ្ឌគុណវុឌ្ឍិតំបន់។ |
| ក្របខណ្ឌគុណវុឌ្ឍិតំបន់* | រចនាសម្ព័ន្ធទូលំទូលាយមួយនៃកម្រិតលទ្ធផលសិក្សា ដែលមានការឯកភាពគ្នាដោយបណ្តាប្រទេសក្នុងតំបន់ភូមិសាស្ត្រមួយ សម្រាប់ជាមធ្យោបាយដែលជួយជំរុញឱ្យក្របខណ្ឌគុណវុឌ្ឍិជាតិមួយ មានទំនាក់ទំនងទៅនឹងក្របខណ្ឌគុណវុឌ្ឍិជាតិមួយផ្សេងទៀត ហើយជាបន្តបន្ទាប់សម្រាប់ធ្វើឱ្យគុណវុឌ្ឍិរបស់ប្រទេសមួយត្រូវបានប្រៀបធៀប ទៅនឹងគុណវុឌ្ឍិរបស់ប្រទេសមួយទៀត។ |
| ភ្នាក់ងារ/អង្គភាពចុះបញ្ជិកាទទួលស្គាល់គុណភាព* | ភ្នាក់ងារចុះបញ្ជិកាទទួលស្គាល់គុណភាព គឺជាស្ថាប័ន/អង្គភាពមានសមត្ថកិច្ចដែលទទួលបន្ទុកលើការទទួលស្គាល់គុណភាពនៃស្ថាប័ន/អង្គភាពផ្តល់សេវាអប់រំ និងបណ្តុះ បណ្តាល ឧទាហរណ៍៖ ភ្នាក់ងារ/អង្គភាពផ្តល់គុណវុឌ្ឍិជាតិ ក្រុមប្រឹក្សាត្រួតពិនិត្យផ្លូវការ ឬភ្នាក់ងារ/អង្គភាពផ្តល់ការអនុម័តថ្នាក់ជាតិផ្សេងៗទៀត។ ភ្នាក់ងារ/អង្គភាពចុះបញ្ជិកាទទួលស្គាល់គុណភាពមានមុខងារ/ដែនមានសមត្ថកិច្ចនៅក្នុងប្រព័ន្ធធានាគុណភាព។ |
| ការចុះបញ្ជិកាទទួលស្គាល់អង្គភាពផ្តល់សេវា* | ដំណើរការនៃការចុះបញ្ជិកាទទួលស្គាល់គុណភាព រួមបញ្ចូលការទទួលស្គាល់ជាផ្លូវការដោយភ្នាក់ងារចុះបញ្ជិកាទទួល-ស្គាល់គុណភាព ដែលស្ថាប័ន/អង្គភាពផ្តល់សេវាឆ្លើយតបទៅនឹងស្តង់ដាគុណភាពដែលពាក់ព័ន្ធ។ ក្របខណ្ឌគុណវុឌ្ឍិជាតិ ជាទូទៅចែងថាស្ថាប័ន/អង្គភាពផ្តល់សេវាអប់រំ និងបណ្តុះបណ្តាលមួយត្រូវចុះបញ្ជិកាទទួលស្គាល់គុណភាព ដើម្បីដំណើរការបណ្តុះបណ្តាល និងវាយតម្លៃសមត្ថភាពសម្រាប់កម្មវិធីបណ្តុះបណ្តាល/វគ្គសិក្សា និងការផ្តល់គុណវុឌ្ឍិ។<br><br>ភ្នាក់ងារមួយចំនួនបង្ហាញភាពខុសគ្នារវាងដំណើរការទាំងពីរ ឧទាហរណ៍៖<br>• ការទទួលស្គាល់ផ្លូវការបញ្ជាក់ថា អង្គភាពផ្តល់សេវាឆ្លើយតបនឹងស្តង់ដាទូទៅសំខាន់ៗ<br>• ការទទួលស្គាល់ផ្លូវការបញ្ជាក់ថា ស្ថាប័ន/អង្គភាពផ្តល់សេវាឆ្លើយតបនឹងស្តង់ដាជាក់លាក់ទាក់ទងនឹងបញ្ញត្តិនៃការបង្រៀន ការសិក្សា និងការវាយតម្លៃសមត្ថភាពលើកម្មវិធីបណ្តុះបណ្តាលច្បាស់លាស់។<br><br>ចំពោះគោលបំណងនៃក្របខណ្ឌគុណវុឌ្ឍិយោងអាស៊ាន ការចុះបញ្ជិកាទទួលស្គាល់គុណភាពនៃស្ថាប័ន/អង្គភាពផ្តល់-សេវា គឺជាពាក្យបច្ចេកទេសដែលត្រូវបានប្រើសម្រាប់ដំណើរការទាំងពីរ។ |

## សេចក្តីផ្តើម

ធម្មនុញ្ញអាស៊ាន ដែលបានចុះហត្ថលេខាដោយថ្នាក់ដឹកនាំ នៃប្រទេសអាស៊ានទាំង១០ នៅក្នុងប្រទេសសិង្ហបុរី កាលពីថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៧ មាន បំណង "បង្កើតទីផ្សារ និងមូលដ្ឋានផលិតកម្មតែមួយដែលមានស្ថិរភាព ចម្រុងចម្រើន និងមានការប្រកួតប្រជែងខ្ពស់ និងធ្វើសមាហរណកម្មសេដ្ឋកិច្ចដោយមានការសម្របសម្រួលប្រកបដោយប្រសិទ្ធភាពសម្រាប់ពាណិជ្ជកម្ម និងការវិនិយោគដែលមានលំហូរដោយសេរីនៃទំនិញ សេវាកម្ម និងការធ្វើវិនិយោគ ដើម្បីជួយសម្រួលដល់ការចល័តនៃពាណិជ្ជករ អ្នកវិជ្ជាជីវៈអាជីព អ្នកមានទេពកោសល្យ កម្លាំងពលកម្ម និងលំហូរមូលធនដោយសេរី"។ បន្ថែមជាងនេះទៅទៀត វាក៏មានគោលបំណងដើម្បី "អភិវឌ្ឍធនធានមនុស្ស តាមរយៈកិច្ចសហប្រតិបត្តិការជិតស្និទ្ធក្នុងការអប់រំ និងការសិក្សាពេញមួយជីវិត ទាំងនៅក្នុងវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាសម្រាប់ការផ្តល់សិទ្ធិអំណាចដល់ប្រជាជននៃប្រទេសអាស៊ាន និងសម្រាប់ពង្រឹងសហគមន៍សេដ្ឋកិច្ចអាស៊ាន"។[15]

ក្នុងឆ្នាំ ២០០៧ ប្រទេសជាសមាជិកអាស៊ាន (AMS)[16] បានអនុម័តផែនការសហគមន៍សេដ្ឋកិច្ចអាស៊ាន (ASEAN 2007) ដែលបានអំពាវនាវឱ្យមានកិច្ចសហប្រតិបត្តិការ ដែលក្នុងនោះ រួមមានការទទួលស្គាល់គុណវុឌ្ឍិវិជ្ជាជីវៈអាជីព។ បន្ថែមលើកិច្ចព្រមព្រៀងទទួលស្គាល់ជំនាញគ្នាទៅវិញទៅមក (MRA) លើវិស័យវិស្វកម្ម និងគិលានុបដ្ឋាក ដែលបានចុះហត្ថលេខាក្នុងឆ្នាំ២០០៥ និង២០០៦។ កិច្ចព្រមព្រៀងទទួលស្គាល់ជំនាញគ្នាទៅវិញទៅមកលើវិស័យចំនួន៥ ត្រូវបានចុះហត្ថលេខាជាបន្តបន្ទាប់ នៅឆ្នាំ២០០៧ និង២០០៩ មានវិស័យ ស្ថាបត្យកម្ម ការវាស់ស្ទង់ដី វេជ្ជសាស្ត្រនិងទន្តសាស្ត្រ និងគណនេយ្យ។ សមាសភាពសំខាន់មួយទៀត នៃផែនការសហគមន៍សេដ្ឋកិច្ចអាស៊ាន គឺបង្កើតលំហូរដោយសេរីនៃកម្លាំងពលកម្មជំនាញតាមរយៈ "សុខដុមនីយកម្ម និងស្តង់ដាភាវូបនីយកម្ម" (ASEAN 2007:18) ជាពិសេស ការត្រៀមខ្លួនសម្រាប់សហគមន៍សេដ្ឋកិច្ចអាស៊ានក្នុងឆ្នាំ២០១៥។

សម្រាប់សហគមន៍សេដ្ឋកិច្ចអាស៊ាន សកម្មភាពពាក់ព័ន្ធនឹងការអភិវឌ្ឍធនធានមនុស្សនឹងដើរតួនាទីយ៉ាងសំខាន់ក្នុងកំណើនសេដ្ឋកិច្ចនៅក្នុងសេដ្ឋកិច្ចប្រទេសអាស៊ាននីមួយៗ ដែលនាំមកនូវការរួមចំណែកដ៏សំខាន់ដល់ការអភិវឌ្ឍក្នុងតំបន់ទាំងមូល។ ដូចដែលបានដឹងស្រាប់ហើយថា ភាពជោគជ័យនៃរាល់សកម្មភាពអភិវឌ្ឍធនធានមនុស្សទាំងអស់ពឹងផ្អែកយ៉ាងខ្លាំងទៅលើដំណើរការនៃការសិក្សាពេញមួយជីវិត ការបណ្តុះបណ្តាល និងភាពមានការងារធ្វើប្រកបដោយចីរភាព។ ជាការពិតណាស់នឹងមានការចល័ត និងផ្លាស់ប្តូរកម្លាំងពលកម្មជំនាញនៅក្នុងរង្វង់ទីផ្សារការងារអាស៊ាន ហើយកត្តាសំខាន់មួយក្នុងចំណោមកត្តាសំខាន់ទាំងឡាយដែលធ្វើឱ្យការងារនេះបានជោគជ័យ គឺការទទួលស្គាល់សមត្ថភាព និងជំនាញរបស់ពលរដ្ឋ។ បញ្ហាពិតដែលប្រឈមមុខដោយសេដ្ឋកិច្ចនីមួយៗនៅក្នុងការទទួលស្គាល់សមត្ថភាព និងជំនាញរបស់បុគ្គល គឺការគ្មានគោលការណ៍ណែនាំដែលអាចត្រូវបានប្រើជាឯកសារយោងសម្រាប់តម្រូវការនៃការទទួលស្គាល់គ្នា។ ដោយសារគ្មានគោលការណ៍ណែនាំ និងប្រព័ន្ធនៃការផ្តល់គុណវុឌ្ឍនេះហើយ ទើបមានបញ្ហាជាច្រើន ដែលនឹងជួបប្រទះចំពោះមុខក្នុងវិស័យសេដ្ឋកិច្ចទាំងអស់ ដែលទាក់ទងនឹងសកម្មភាពអភិវឌ្ឍធនធានមនុស្ស ដូចជា៖ (i) ការជ្រើសរើសធនធានមនុស្ស (ii) លក្ខខណ្ឌតម្រូវរបស់គម្រោងនានា (iii) ការអនុវត្តការផ្តល់គុណវុឌ្ឍ (iv) ស្តង់ដាសមត្ថភាព/ជំនាញ។

បច្ចុប្បន្ននេះ ប្រទេសជាសមាជិកអាស៊ាននីមួយៗមានក្របខណ្ឌគុណវុឌ្ឍជាតិផ្ទាល់ខ្លួន ដែលទាក់ទងនឹងសកម្មភាពអភិវឌ្ឍធនធានមនុស្ស។ ចំណុចយោង គឺជាមុខងារមួយនៃក្របខណ្ឌទាំងនោះ សម្រាប់ធ្វើការទទួលស្គាល់ប្រភេទផ្សេងៗនៃគុណវុឌ្ឍ និងជំនាញធនធានមនុស្សនៅក្នុងរង្វង់នៃវិស័យឧស្សាហកម្មដែលបានកំណត់។ ក្របខណ្ឌទាំង១០ក្នុងសហគមន៍សេដ្ឋកិច្ចអាស៊ាន សុទ្ធតែមានចរិតលក្ខណៈពិសេសរបស់ពួកគេរៀងៗខ្លួន។ ការធ្វើសមាហរណកម្មអាស៊ានជាទីផ្សារតែមួយ ក្របខណ្ឌទាំងនោះ នឹងត្រូវបានប្រើប្រាស់រួមគ្នាជាមួយនឹងសេដ្ឋកិច្ចដូចជាហេដ្ឋារចនាសម្ព័ន្ធរូបវន្តនៅក្នុងសកម្មភាពអភិវឌ្ឍធនធានមនុស្ស។

គោលការណ៍ណែនាំនេះ ផ្តល់ជាមូលដ្ឋានក្នុងការបង្កើតភាពជឿជាក់ ទំនុកចិត្ត និងការយល់ដឹងលើប្រព័ន្ធផ្តល់គុណវុឌ្ឍសមត្ថភាព និងមានបំណងផ្តល់នូវគោលការណ៍ និងពិធីសារសម្រាប់អភិវឌ្ឍដំណើរការនៃការទទួលស្គាល់ប្រព័ន្ធនេះ។
គោលការណ៍នេះ រួមមាន៖

- ទិដ្ឋភាពទូទៅនៃក្របខណ្ឌគុណវុឌ្ឍជាតិរបស់ប្រទេសជាសមាជិកអាស៊ាន (ផ្នែកទី១)
- ទិដ្ឋភាពទូទៅនៃប្រព័ន្ធការផ្តល់គុណវុឌ្ឍសមត្ថភាពរបស់ប្រទេសជាសមាជិកអាស៊ាន(ផ្នែកទី២)

---

[15] Charter of the Association of Southeast Asian Nations (2007), Chapter 1, Article 1, paras 5 and 10

[16] Brunei Darussalam, Cambodia, Indonesia, Lao PDR, Malaysia, Myanmar, Philippines, Singapore, Thailand, and Viet Nam

- ការពិភាក្សាអំពីទិដ្ឋភាពសំខាន់ៗនៃការធានាគុណភាព (ផ្នែកទី៣)
- គោលការណ៍ណែនាំ និង ពិធីសារធានាគុណភាពដែលបានឯកភាពគ្នា ដែលទាក់ទងនឹងអង្គភាព មានសមត្ថកិច្ច និងអង្គភាពផ្ដល់សេវាវាយតម្លៃសមត្ថភាព (ផ្នែកទី៤)
- គោលការណ៍ណែនាំ និងពិធីសារសម្រាប់ប្រព័ន្ធទទួលស្គាល់ការផ្ដល់គុណវុឌ្ឍិសមត្ថភាពដែលបានឯកភាពគ្នា (ផ្នែកទី៥)
- ទិដ្ឋភាពទូទៅ នៃក្របខណ្ឌគុណវុឌ្ឍិយោងអាស៊ាន និងរបៀបដែលស្ថាប័ន/អង្គភាពមានសមត្ថកិច្ចត្រូវចូលរួមក្នុងសកម្មភាពលើការផ្ទៀងផ្ទាត់ជាតិ (ផ្នែកទី៦)។

គោលការណ៍ណែនាំ ក៏រួមបញ្ចូលផងដែរនូវពាក្យបច្ចេកទេសថ្នាក់តំបន់ ដែលបានឯកភាពគ្នាសម្រាប់សម្របសម្រួលការពិភាក្សាគ្នារវាងប្រទេសជាសមាជិកអាស៊ាន។

នៅពេលប្រទេសជាសមាជិកអាស៊ាន (AMS) អនុវត្តប្រព័ន្ធធានាគុណភាពរបស់ខ្លួនសម្រាប់ការអប់រំបណ្ដុះ បណ្ដាលដែលប្រើប្រាស់វិធីសាស្ត្រផ្សេងៗគ្នា និងដោយកម្រិតនៃការអនុវត្តខុសៗគ្នា វាមានការលំបាកក្នុងការសន្មត់អំពីប្រភេទនៃអង្គភាពដែលទទួលបន្ទុកលើគ្រោងការណ៍នៃការផ្ដល់គុណវុឌ្ឍិសមត្ថភាព។ និយមន័យនៃវាក្យសព្ទបច្ចេកទេសសំខាន់ៗចំនួនពីរ ដែលបានប្រើប្រាស់ទាំងនៅក្នុងគោលការណ៍ណែនាំ និងនិយមន័យដែលបានឯកភាពគ្នាប្រើក្នុងក្របខណ្ឌគុណវុឌ្ឍិយោងអាស៊ានសម្រាប់ស្ថាប័ន/អង្គភាពផ្ដល់ និងបញ្ជាក់គុណវុឌ្ឍិ មានដូចខាងក្រោម៖[17]

- **ស្ថាប័ន/អង្គភាពមានសមត្ថកិច្ច។** ទទួលខុសត្រូវចម្បងលើគ្រប់ ឬផ្នែកខ្លះៗនៃទិដ្ឋភាពប្រព័ន្ធផ្ដល់គុណវុឌ្ឍិសមត្ថភាព។ ស្ថាប័ន/អង្គភាពមានសមត្ថកិច្ចអាចជាអាជ្ញាធរផ្ដល់គុណវុឌ្ឍិ ដែលជាស្ថាប័ន/អង្គភាពទទួលបន្ទុកលើការអភិវឌ្ឍ/អនុម័តស្ដង់ដាសមត្ថភាព/ស្ដង់ដាមុខរបរ ជាស្ថាប័ន/អង្គភាពផ្ដល់គុណវុឌ្ឍិ ឬជាស្ថាប័ន/អង្គភាពដែលទទួលខុសត្រូវក្នុងការផ្ដល់គុណវុឌ្ឍិសមត្ថភាព។
- **ស្ថាប័ន/អង្គភាពផ្ដល់សេវាវាយតម្លៃសមត្ថភាព។** ជាអ្នកផ្ដល់នូវសេវាវាយតម្លៃសមត្ថភាព (និងអាចជាអ្នកផ្ដល់សេវាបណ្ដុះបណ្ដាល) និងក៏អាចជាស្ថាប័ន/អង្គភាពផ្ដល់គុណវុឌ្ឍិសមត្ថភាពផងដែរ។
- **ស្ថាប័ន/អង្គភាពផ្ដល់/បញ្ជាក់គុណវុឌ្ឍិ។** ជាស្ថាប័ន/អង្គភាពដែលចេញគុណវុឌ្ឍិ (ឧទាហរណ៍៖ វិញ្ញាបនបត្រ សញ្ញាបត្រ ឬចំណងជើងគុណវុឌ្ឍិផ្សេងៗទៀត) ដែលបានទទួលស្គាល់ជាផ្លូវការនូវលទ្ធផលសិក្សាដែលសម្រេចបានរបស់បុគ្គលណាម្នាក់ ដោយអនុវត្តតាមនីតិវិធីនៃការវាយតម្លៃសមត្ថភាព និងការផ្ដល់សុពលភាព។[18]

គោលការណ៍ណែនាំនេះ បានប្រើប្រាស់វាក្យសព្ទបច្ចេកទេស *ស្ថាប័ន/អង្គភាពមានសមត្ថកិច្ច* ជាជាង *ស្ថាប័ន/អង្គភាពផ្ដល់គុណវុឌ្ឍិសមត្ថភាព* ពីព្រោះប្រព័ន្ធនៃការផ្ដល់គុណវុឌ្ឍិខ្លះ ស្ថាប័ន/អង្គភាពដែលទទួលខុសត្រូវក្នុងការបញ្ជាក់គុណវុឌ្ឍិ ក៏អាចជាស្ថាប័ន/អង្គភាពផ្ដល់សេវាវាយតម្លៃសមត្ថភាពផងដែរ ហើយក៏មិនទទួលបន្ទុកនូវរាល់គ្រប់ទិដ្ឋភាពទាំងអស់សម្រាប់ការធានាគុណភាពនៃប្រព័ន្ធនៃការផ្ដល់គុណវុឌ្ឍិទូទៅ ឬការផ្ដល់គុណវុឌ្ឍិផ្អែកលើសមត្ថភាពនោះឡើយ។

[17] ពាក្យសំខាន់២ ដែលបានយកពីផ្នែកទី៤ ដើម្បីធានាថាមានការយល់ដឹងរួមចាប់ពីចំណុចចាប់ផ្ដើមដំបូងនៃគោលការណ៍នេះ។ និយមន័យទី៣ គឺជាពាក្យបច្ចេកទេស AQRF ដែលបានឯកភាពគ្នា ដែលបានយកពីសន្ទានុក្រមមានស្រាប់ក្នុងគោលការណ៍នេះ។

[18] Cedefop (2011), p. 10 & 11

# ផ្នែកទី១៖

## ទិដ្ឋភាពទូទៅនៃក្របខណ្ឌគុណវុឌ្ឍិជាតិ(ក.គ.ជ)

## របស់ប្រទេសជាសមាជិកអាស៊ាន

## ផ្នែកទី ១ ៖ និន្នាការទូទៅនៃក្របខណ្ឌគុណវុឌ្ឍិជាតិ (ក.គ.ជ) របស់ប្រទេសជាសមាជិកអាស៊ាន

សេដេហ្វប់ (Cedefop, ២០១១, ទំព័រ៨២) បានឱ្យនិយមន័យក្របខណ្ឌគុណវុឌ្ឍិថាជា៖

> *ឧបករណ៍សម្រាប់ការអភិវឌ្ឍ និងការធ្វើចំណាត់ថ្នាក់គុណវុឌ្ឍិ (ឧទាហរណ៍៖ កម្រិតជាតិ ឬតាមវិស័យ) ដោយអាស្រ័យលើលក្ខណវិនិច្ឆ័យមួយចំនួន (ឧទាហរណ៍៖ ការប្រើប្រាស់ការពិពណ៌នាកម្រិតគុណវុឌ្ឍិ) ដែលអាចអនុវត្តបានចំពោះកម្រិតជាក់លាក់នៃលទ្ធផលសិក្សា*

នៅក្នុងប្រទេសជាសមាជិកអាស៊ាន គ្មានគោលការណ៍រួមតែមួយសម្រាប់ការអភិវឌ្ឍ ឬការអនុវត្តក្របខណ្ឌគុណវុឌ្ឍិជាតិទេ។ ប្រទេសនីមួយៗស្ថិតនៅក្នុងដំណាក់កាលខុសៗគ្នាក្នុងការធ្វើផែនការ ឬការអនុវត្ត រវាងក្របខណ្ឌគុណវុឌ្ឍិតាមវិស័យ ទាំងក្របខណ្ឌគុណវុឌ្ឍិជាតិ និងខ្លះទៀតអាចនឹងមិនទាន់មានប្រព័ន្ធជាតិច្បាស់លាស់នៅឡើយក្នុងការអភិវឌ្ឍក្របខណ្ឌគុណវុឌ្ឍិជាតិ។ ការអភិវឌ្ឍក្របខណ្ឌគុណវុឌ្ឍិជាតិអាចត្រូវបានដាក់ជាក្រុម ទៅតាមប្រភេទទូទៅ ដូចខាងក្រោម៖

១. គ្មានចេតនា
២. មានតម្រូវការ ប៉ុន្តែមិនមានវឌ្ឍនភាព
៣. ការរៀបចំផែនការបាននឹងកំពុងដំណើរការ
៤. ការផ្តួចផ្តើមអភិវឌ្ឍ និងការបញ្ចប់ប្លង់រចនា
៥. រចនាសម្ព័ន្ធ និងដំណើរការខ្លះៗ បានឯកភាព និងបានចងក្រងជាឯកសារ
៦. រចនាសម្ព័ន្ធ និងដំណើរការខ្លះៗ បានបង្កើត និងអាចប្រតិបត្តិបាន
៧. រចនាសម្ព័ន្ធ និងនីតិវិធីមួយចំនួនបានបង្កើតអស់រយៈពេល៥ឆ្នាំហើយ
៨. ការពិនិត្យឡើងវិញនូវរចនាសម្ព័ន្ធ និងនីតិវិធីត្រូវបានដាក់ស្នើ ឬកំពុងដំណើរការ។[19]

តារាងខាងក្រោមរៀបរាប់ត្រួសៗសំខាន់ៗនូវកម្រិតនៃការផ្តួចផ្តើមឲ្យមាននៃក្របខ័ណ្ឌគុណវុឌ្ឍិជាតិនៅក្នុងតំបន់។

**តារាងទី ១៖ តារាងសង្ខេបក្របខណ្ឌគុណវុឌ្ឍិជាតិ**

| ប្រទេស | កម្រិតនៃការបង្កើត | ដំណាក់កាល |
|---|---|---|
| ប្រ៊ុយណេ | សម្ភោធដាក់ឱ្យប្រើប្រាស់នៅឆ្នាំ២០១៣ | ៦ |
| កម្ពុជា | បង្កើតនៅឆ្នាំ២០១២ ស្ថិតនៅដំណាក់កាលផ្តួចផ្តើមអនុវត្ត | ៥ |
| ឥណ្ឌូនេស៊ី | បង្កើតនៅឆ្នាំ២០១២ ស្ថិតនៅដំណាក់កាលផ្តួចផ្តើមអនុវត្ត | ៥ |
| ឡាវ | រៀបចំផែនការបាននឹងកំពុងដំណើរការ | ៣ |
| ម៉ាឡេស៊ី | បង្កើតនៅឆ្នាំ២០០៧ បានអនុវត្តពេញលេញ និងស្ថិតក្នុងដំណាក់កាលត្រួតពិនិត្យឡើងវិញ | ៨ |
| ភូមា (មីយ៉ាន់ម៉ា) | រៀបចំផែនការបាននឹងកំពុងដំណើរការ | ៣ |
| ហ្វីលីពីន | បង្កើតនៅឆ្នាំ២០១២ ស្ថិតនៅដំណាក់កាលផ្តួចផ្តើមអនុវត្ត | ៥ |
| សិង្ហបុរី | ផ្នែកក្របខណ្ឌគុណវុឌ្ឍិ-ប្រព័ន្ធគុណវុឌ្ឍិកម្លាំងពលកម្មជំនាញ ត្រូវបានដាក់សម្ភោធនៅឆ្នាំ២០០៥ | ៧ |
| ថៃ | បង្កើតនៅឆ្នាំ២០១៤ ស្ថិតនៅដំណាក់កាលផ្តួចផ្តើមអនុវត្ត បានបង្កើតអនុក្របខណ្ឌចំនួន៣ | ៤ |
| វៀតណាម | រៀបចំផែនការបាននឹងកំពុងដំណើរការ | ៣ |

*ប្រភព៖* ***Bateman & Coles 2015***

នាពេលថ្មីៗនេះ ក្របខណ្ឌគុណវុឌ្ឍិត្រូវបានអភិវឌ្ឍ ហើយការអភិវឌ្ឍទាំងនោះស្ថិតក្នុងការធ្វើផែនការដែលមានភាពខុសៗគ្នាក្នុងស្ថានភាពដូចខាងក្រោម៖

- ការរៀបចំអភិបាលកិច្ច
- គោលបំណង
- រចនាសម្ព័ន្ធ (កម្រិត ផ្នែកនៃលទ្ធផលសិក្សា កម្មវិធីអនុវត្តប្រព័ន្ធក្រេឌីត)។

[19] ចំណាត់ថ្នាក់ទាំងនេះត្រូវបានប្រើប្រាស់ក្នុងការផ្តួចផ្តើមការស្រាវជ្រាវដំបូងសម្រាប់បង្កើតក្របខណ្ឌគុណវុឌ្ឍិយោងអាស៊ាន

នៅបណ្តាប្រទេសជាសមាជិកអាស៊ាន ក្របខណ្ឌគុណវុឌ្ឍិត្រូវបានបង្កើតឡើងតាមរយៈដំណើរការផ្សេងៗគ្នារួមមានច្បាប់ ឬលិខិតតូបករណ៍ ដែលមានទំនាក់ទំនងទៅនឹងក្របខណ្ឌ ឬភ្នាក់ងារទទួលបន្ទុក។ នៅក្នុងតំបន់អាស៊ាន ក្របខណ្ឌគុណវុឌ្ឍិបីត្រូវបានផ្សារភ្ជាប់គ្នាដោយផ្ទាល់ទៅនឹងទីភ្នាក់ងារដែលទទួលបន្ទុក (ប្រ៊ុយណេ ម៉ាឡេស៊ី សិង្ហបុរី [20]) ក្របខណ្ឌគុណវុឌ្ឍិពីរ ត្រូវបានបង្កើតតាមរយៈលិខិតតូបករណ៍ ដែលមានទំនាក់ទំនងផ្ទាល់ទៅនឹងក្របខណ្ឌនោះ (ឧទាហរណ៍៖ កម្ពុជា និងឥណ្ឌូនេស៊ី)។ ក្របខណ្ឌរបស់ប្រទេសថៃត្រូវបានអនុម័តដោយគណៈរដ្ឋមន្ត្រី រីឯហ្វីលីពីន ត្រូវបានបង្កើតឡើងស្ថាប័ននីតិប្រតិបត្តិ (Executive Order)។

ជារឿយៗ ការរៀបចំអភិបាលកិច្ចលើក្របខណ្ឌគុណវុឌ្ឍិត្រូវបានផ្សារភ្ជាប់នឹងក្របខណ្ឌនៃមូលដ្ឋានច្បាប់ និងអង្គភាពមានសមត្ថកិច្ច។ យ៉ាងណាក៏ដោយ នៅក្នុងប្រទេសខ្លះ ដូចជាកម្ពុជា និងឥណ្ឌូនេស៊ី មិនទាន់មានអង្គភាពទទួលខុសត្រូវច្បាស់លាស់សម្រាប់ការគ្រប់គ្រង និងត្រួតពិនិត្យលើក្របខណ្ឌគុណវុឌ្ឍិជាតិ នៅកម្រិតថ្នាក់ជាតិទេ។

ខូល អេ អាល់ (Coles et al, ២០១៤) បានបញ្ជាក់ពីមុខងារចម្បងនៃក្របខណ្ឌគុណវុឌ្ឍិជាតិគឺ "ដើម្បីដើរតួជាឯកសារគោលមួយ (benchmark) សម្រាប់ទទួលស្គាល់កម្រិតនៃលទ្ធផលសិក្សាក្នុងប្រព័ន្ធគុណវុឌ្ឍិជាតិ" (ទំព័រ២២)។ តាមរយៈក្របខណ្ឌដែលបានចងក្រងជាឯកសារនៅក្នុងតំបន់អាស៊ានដែលមានគោលបំណងផ្សេងៗគ្នា ប៉ុន្តែទោះជាយ៉ាងណាក៏មានប្រធានបទរួមខ្លះៗ ដូចជាបទប្បញ្ញត្តិ និងលក្ខខណ្ឌបច្ចេកទេសលម្អិតនៃគុណវុឌ្ឍិ ការបង្កើនឱ្យមានច្រកសិក្សាច្រើនសម្រាប់អ្នកសិក្សា និងការទទួលស្គាល់ថ្នាក់អន្តរជាតិ។

តារាងខាងក្រោម បង្ហាញនូវលក្ខណៈសំខាន់ៗរបស់ក្របខណ្ឌគុណវុឌ្ឍិជាតិបច្ចុប្បន្ន និងបានដាក់ស្នើ។

**តារាងទី ២៖ សង្ខេបរចនាសម្ព័ន្ធនៃក្របខណ្ឌគុណវុឌ្ឍិជាតិ**

| ប្រទេស | កម្រិត | ផ្នែកនៃលទ្ធផលសិក្សា | ចំនួនក្រេឌីត |
|---|---|---|---|
| ប្រ៊ុយណេ | ៨ | • ចំណេះដឹង និងជំនាញ (ប្រភេទនៃចំណេះដឹង និងជំនាញដែលពាក់ព័ន្ធ)<br>• ការអនុវត្ត៖ ត្រូវអនុវត្តចំណេះដឹង និងការយល់ដឹង (បរិបទដែលចំណេះដឹង និងជំនាញត្រូវបានអនុវត្ត)<br>• ជំនាញក្នុងការគិតទូទៅ<br>• ជំនាញក្នុងការប្រាស្រ័យទាក់ទង ព័ត៌មានវិទ្យា និងជំនាញលេខនព្វន្ត<br>• ស្វ័យភាព គណនេយ្យភាព និងការធ្វើការងារជាមួយអ្នកផ្សេងៗ (កម្រិតនៃឯករាជ្យភាព) | ឧត្តមសិក្សា៖ ៤០ម៉ោងនៃសញ្ញាណម៉ោងសិក្សា = ១ក្រេឌីត<br>TVET៖ ១០ម៉ោងនៃសញ្ញាណម៉ោងសិក្សា = ១ក្រេឌីត |
| កម្ពុជា | ៨ | • ចំណេះដឹង<br>• ជំនាញក្នុងការគិត (ចំណេះដឹងវិភាគ)<br>• ជំនាញចិត្តចលនា<br>• ជំនាញទំនាក់ទំនងអន្តរបុគ្គល និងការទទួលខុសត្រូវ<br>• ជំនាញក្នុងការប្រាស្រ័យទាក់ទង ព័ត៌មានវិទ្យា និងជំនាញលេខនព្វន្ត | ប្រែប្រួលទៅតាមវិធីសាស្ត្រនៃការបង្រៀន |
| ឥណ្ឌូនេស៊ី | ៩ | មាន២ផ្នែក៖<br>• ទូទៅ៖ ចរិតលក្ខណៈ បុគ្គលិកលក្ខណៈឥរិយាបថការងារ ក្រមសីលធម៌ និងសីលធម៌<br>• ជាក់លាក់៖<br>១.ជំនាញក្នុងការបំពេញការងារ និងសមត្ថភាព<br>២.វិទ្យាសាស្ត្រ/ចំណេះដឹង<br>៣.វិធីសាស្ត្រ និងកម្រិតសមត្ថភាពក្នុងការអនុវត្តវិទ្យាសាស្ត្រ/ចំណេះដឹង<br>៤.ជំនាញគ្រប់គ្រង | គិតជាក្រេឌីតចាប់ពីកម្រិតឧត្តមសិក្សាឡើងទៅ+ |

[20] ក្របខណ្ឌគុណវុឌ្ឍិវិស័យអប់រំ

| | | | |
|---|---|---|---|
| ឡាវ* | ៨ | • ចំណេះដឹង<br>• ជំនាញ<br>• ការអនុវត្ត<br>• ជំនាញសង្គម | |
| ម៉ាឡេស៊ី | ៨ | • ចំណេះដឹង<br>• ជំនាញអនុវត្ត<br>• ជំនាញសង្គម និងទំនួលខុសត្រូវ គុណតម្លៃ ឥរិយាបថ និងជំនាញវិជ្ជាជីវៈ<br>• ជំនាញក្នុងការប្រាស្រ័យទាក់ទង ភាពជាអ្នកដឹងនាំ និងការងារជាក្រុម<br>• ជំនាញក្នុងការដោះស្រាយបញ្ហា និងវិទ្យាសាស្ត្រ<br>• ជំនាញក្នុងការគ្រប់គ្រងព័ត៌មាន និងការសិក្សាពេញមួយជីវិត<br>• ជំនាញគ្រប់គ្រង និងសហគ្រិនភាព | ៤០ម៉ោង = ១ក្រេឌីត |
| ភូមា (មីយ៉ាន់ម៉ា)* | ៨ | • ចំណេះដឹង និងជំនាញ<br>• ការអនុវត្ត និងសមត្ថភាព<br>• ការទទួលខុសត្រូវ | |
| ហ្វីលីពីន | ៨ | • ចំណេះដឹង ជំនាញ និងគុណតម្លៃ<br>• ការអនុវត្ត<br>• កម្រិតនៃឯករាជ្យភាព (ស្វ័យភាព និងទំនួលខុសត្រូវ) | |
| សិង្ហបុរី | ៦ | • កម្រិតនៃចំណេះដឹង និងជំនាញដែលពាក់ព័ន្ធ<br>• កម្រិតនៃការអនុវត្តលើចំណេះដឹង និងជំនាញ<br>• កម្រិតនៃគណនេយ្យភាព ឯករាជ្យភាព ការគ្រប់គ្រងខ្លួនឯង ឬការគ្រប់គ្រងអ្នកដទៃ ដែលត្រូវការក្នុងដំណោះស្រាយបញ្ហា ឬបំពេញកិច្ចការ<br>• យល់ដឹងពីកម្រិត និងលំដាប់ការងារ និងជម្រៅនៃចំណេះដឹង និងជំនាញដែលជាតម្រូវការការងារដែលពាក់ព័ន្ធនឹងគុណវុឌ្ឍិ | 1 WSQ credit value (cv) សមមូលនឹង Recommended Learning hours. (RLH), (១ ក្រេឌីត = ១០ម៉ោង).^ |
| ថៃ | ៩ | • ចំណេះដឹង<br>• ជំនាញ<br>• អកប្បកិរិយា | គិតជាក្រេឌីត |
| វៀតណាម* | ៨ | • ចំណេះដឹង<br>• ជំនាញ<br>• ស្វ័យភាព និងទំនួលខុសត្រូវ | ១ក្រេឌីត = ៣០ម៉ោងនៃសញ្ញាណម៉ោងសិក្សា |

**កំណត់សម្គាល់៖**

* =បានស្នើឡើង #=អគ្គនាយកដ្ឋានឧត្តមសិក្សា ២០១២ +=មិនទាន់បានបញ្ចូលទៅក្នុងក្រឹត្យច្បាប់

^អនុសាសន៍នៃម៉ោងសិក្សា (RLH) ត្រូវបានកំណត់ជាចំនួនម៉ោងមធ្យម ដែលសិក្ខាកាមទូទៅបានរំពឹងថាអាចទទួលបាន ដើម្បីសម្រេចនូវលទ្ធផលសិក្សាជាក់លាក់ដែលបានកំណត់ក្នុងផ្នែកសមត្ថភាពនីមួយៗដោយមិនគិតពីវិធីសាស្ត្របណ្តុះបណ្តាល និងការវាយតម្លៃសមត្ថភាពដែលបានអនុម័ត។

*ប្រភព៖ **Bateman & Coles 2015***។

ភាគច្រើននៃសកម្មភាពអភិវឌ្ឍក្របខណ្ឌគុណវុឌ្ឍិជាតិក្នុងតំបន់ គឺជាលទ្ធផលផ្ទាល់នៃផលប្រយោជន៍ក្នុងការបង្កើតឱ្យមានលំហូរកម្លាំងពលកម្មជំនាញតាមរយៈ "ការធ្វើសុខដុមនីយកម្ម និងស្តង់ដាភាវូបនីយកម្ម" (ASEAN ២០០៧ ទំព័រទី ១៨) និងជាពិសេសនៅក្នុងការត្រៀមខ្លួនសម្រាប់សហគមន៍សេដ្ឋកិច្ចអាស៊ានឆ្នាំ២០១៥។ រួមជាមួយនឹងការអភិវឌ្ឍទាំងនេះ បានអនុម័តលើក្របខណ្ឌគុណវុឌ្ឍិយោងអាស៊ាន (AQRF) ដែលត្រូវអនុវត្តចាប់ពីឆ្នាំ២០១៦ ហើយក៏បានបង្កើតកម្លាំងរុញច្រានប្រទេសជាសមាជិកអាស៊ាន (AMS) ក្នុងការអភិវឌ្ឍក្របខណ្ឌគុណវុឌ្ឍិជាតិ ឬកែសម្រួលឡើងវិញនូវក្របខណ្ឌគុណវុឌ្ឍិជាតិរបស់គេ។

ក្របខណ្ឌគុណវុឌ្ឍិយោងអាស៊ាន គឺជាក្របខណ្ឌយោងទូទៅដែលមានតួនាទីជាឧបករណ៍មួយ ដើម្បីធ្វើឱ្យមានការប្រៀបធៀបគុណវុឌ្ឍិនៅក្នុងប្រទេសជាសមាជិកអាស៊ាន។ ក្របខណ្ឌនេះបានបញ្ជាក់នូវវិស័យអប់រំ និងបណ្តុះបណ្តាល[21] និងមានគោលដៅទូលាយក្នុងការលើកកម្ពស់ការសិក្សាពេញមួយជីវិត។

ក្របខណ្ឌ គុណវុឌ្ឍិយោងអាស៊ាន តម្រូវឱ្យប្រទេសជាសមាជិកធ្វើការផ្ទៀងផ្ទាត់នឹងក្របខណ្ឌគុណវុឌ្ឍិ/ប្រព័ន្ធគុណវុឌ្ឍិរបស់ពួកគេ។ ដំណើរការផ្ទៀងផ្ទាត់ គឺជាដំណើរស្វ័យតជាតិមួយដែលអាជ្ញាធរជាតិនិងផ្នែកពាក់ព័ន្ធឯកភាពទៅលើការភ្ជាប់ទំនាក់ទំនងរវាងកម្រិតគុណវុឌ្ឍិជាតិនីមួយៗ ទៅនឹងកម្រិតនៅក្នុងក្របខណ្ឌគុណវុឌ្ឍិយោងអាស៊ាន។ ការភ្ជាប់ទំនាក់ទំនងរវាងកម្រិតគុណវុឌ្ឍិជាតិ និងកម្រិតក្របខណ្ឌគុណវុឌ្ឍិយោងអាស៊ាននេះ គឺជាលទ្ធផលនៃដំណើរការផ្ទៀងផ្ទាត់ និងជំរុញឱ្យការផ្សារភ្ជាប់ទំនាក់ទំនងកាន់តែល្អប្រសើរឡើងថែមទៀតតាមរយៈក្របខណ្ឌគុណវុឌ្ឍិយោងអាស៊ាន ទៅនឹងកម្រិតគុណវុឌ្ឍិនៅក្នុងប្រទេសជាសមាជិកអាស៊ានផ្សេងៗទៀត។

ដើម្បីកសាងភាពជឿជាក់ក្នុងការផ្តល់គុណវុឌ្ឍិដែលបានចេញនៅទូទាំងតំបន់ ក្របខណ្ឌនេះត្រូវបានគាំទ្របន្ថែមទៀតដោយគោលការណ៍ធានាគុណភាព និងស្តង់ដាគុណភាពដែលបានឯកភាពគ្នាដូចខាងក្រោម៖

- មុខងាររបស់ភ្នាក់ងារទទួលបន្ទុកការអនុម័ត
- ប្រព័ន្ធសម្រាប់ការវាយតម្លៃសមត្ថភាពលើការសិក្សា និងការចេញគុណវុឌ្ឍិ
- បទប្បញ្ញត្តិនៃការចេញគុណវុឌ្ឍិ។

ក្របខណ្ឌគុណវុឌ្ឍិយោងអាស៊ាន តម្រូវឱ្យប្រទេសសមាជិកដែលបានបង្កើតក្របខណ្ឌធានាគុណភាពមួយ ឬ ច្រើន ដែលប្រើជាមូលដ្ឋានសម្រាប់គោលការណ៍ធានាគុណភាព និងស្តង់ដាគុណភាពឯកភាពមួយ។ ក្របខណ្ឌធានាគុណភាពទាំងនេះ ត្រូវបានប្រើប្រាស់ជាឯកសារគោលសម្រាប់ធ្វើការវាយតម្លៃប្រព័ន្ធធានាគុណភាពដែលពាក់ព័ន្ធវិស័យអប់រំ និងបណ្តុះបណ្តាល។ ដំណើរការផ្ទៀងផ្ទាត់នេះ ក៏តម្រូវឱ្យប្រទេសជាសមាជិកពិពណ៌នាអំពីប្រព័ន្ធធានាគុណភាពនៃការអប់រំ និងបណ្តុះបណ្តាលរបស់គេផងដែរដើមឆ្នាំ២០១៦ មិនមានប្រទេសជាសមាជិកអាស៊ានណាមួយអនុវត្តដំណើរការផ្ទៀងផ្ទាត់ក្របខណ្ឌគុណវុឌ្ឍិជាតិរបស់ខ្លួនទៅនឹងក្របខណ្ឌគុណវុឌ្ឍិយោងអាស៊ានជាផ្លូវការទេ ថ្វីបើមានអ្នកខ្លះអនុវត្តការផ្ទៀងផ្ទាត់ក្រៅផ្លូវការដោយរាប់បញ្ចូលទាំងការពឹងផ្អែកលើប្រព័ន្ធធានាគុណភាពរបស់ពួកគេ។

គិតចាប់ពីដើមឆ្នាំ 2016 គ្មានប្រទេសសមាជិកអាស៊ានបានទទួលធ្វើដំណើរការផ្ទៀងផ្ទាត់ផ្លូវការឡើយ ថ្វីបើប្រទេសខ្លះអាចនឹងទទួលធ្វើការផ្ទៀងផ្ទាត់ក្រៅផ្លូវការក្តី ដែលរួមមានការធ្វើបទដ្ឋាននីយកម្មប្រព័ន្ធធានាគុណភាពរបស់ពួកគេ។

[21] ការអប់រំ និងការបណ្តុះបណ្តាលរួមបញ្ចូលការសិក្សាក្នុងប្រព័ន្ធ ការសិក្សាក្រៅប្រព័ន្ធ និងការសិក្សាមិនផ្លូវការ។ ការសិក្សាក្នុងប្រព័ន្ធ រួមមាន តែមិនកំណត់៖ ការសិក្សាក្រោយមធ្យមសិក្សា ការអប់រំមនុស្សពេញវ័យ និងសហគមន៍ ការអប់រំបណ្តុះបណ្តាល បច្ចេកទេស និងវិជ្ជាជីវៈ និងការអប់រំឧត្តមសិក្សា។

# ផ្នែកទី២៖
# ទិដ្ឋភាពទូទៅនៃប្រព័ន្ធផ្តល់គុណវុឌ្ឍ្យសមត្ថភាពរបស់ប្រទេសជាសមាជិកអាស៊ាន

## ផ្នែកទី ២៖ និន្នាការទូទៅនៃប្រព័ន្ធផ្តល់គុណវុឌ្ឍិសមត្ថភាពរបស់ប្រទេសជាសមាជិកអាស៊ាន

សេដេហ្វប់ (Cedefop, ២០១១, ទំព័រ១៦) កំណត់ថា ការផ្តល់គុណវុឌ្ឍិជា "ដំណើរការនៃការចេញវិញ្ញាបនបត្រ សញ្ញាបត្រ ឬចំណងជើងនៃលទ្ធផលសិក្សា បញ្ជាក់ជាផ្លូវការពីសំណុំនៃលទ្ធផលសិក្សា (ចំណេះដឹង ការដឹងរបៀបធ្វើ ជំនាញ និង/ឬសមត្ថភាព) ដែលទទួលបានដោយបុគ្គលម្នាក់ក្រោយពីបានវាយតម្លៃសមត្ថភាព និងផ្តល់សុពលភាពដោយស្ថាប័ន/អង្គភាពមានសមត្ថកិច្ចផ្អែកលើស្តង់ដាដែលបានកំណត់រួច"។

ការអភិវឌ្ឍធនធានមនុស្សជាប្រភេទដ៏សំខាន់បំផុតមួយនៃប្រព័ន្ធផ្តល់គុណវុឌ្ឍិ ដែលបញ្ជាក់ពីសមត្ថភាពរបស់បុគ្គលម្នាក់ក្នុងការអនុវត្តកិច្ចការជាក់លាក់លើមុខរបរណាមួយ។ ជាទូទៅ ការផ្តល់គុណវុឌ្ឍិត្រូវផ្អែកលើការវាយតម្លៃសមត្ថភាព រួមមាន ការធ្វើតេស្ត ការវាយតម្លៃសមត្ថភាពលើការប្រតិបត្តិ និង/ឬការវាយតម្លៃលើឯកសារភស្តុតាង។ ការផ្តល់គុណវុឌ្ឍិ អាចរាប់បញ្ចូលទាំងបទពិសោធន៍ការងារ មុននឹងធ្វើការវាយតម្លៃសមត្ថភាព។ ប្រព័ន្ធផ្តល់គុណវុឌ្ឍិខ្លះ បញ្ជាក់ពីរយៈពេលដែលមានសុពលភាពនៃការទទួលស្គាល់ហើយនៅពេលផុតសុពលភាព តម្រូវឲ្យមានការផ្តល់គុណវុឌ្ឍិឡើងវិញ ចំណែកប្រព័ន្ធផ្តល់គុណវុឌ្ឍិខ្លះទៀត មានសុពលភាពពេញមួយជីវិត ដោយអាស្រ័យលើការបំពេញរាល់លក្ខខណ្ឌតម្រូវទាំងអស់នៃការផ្តល់គុណវុឌ្ឍិ។ ការផ្តល់គុណវុឌ្ឍិ គឺមិនចាំបាច់សំដៅលើការអនុវត្តវិជ្ជាជីវៈតាមក្បួនច្បាប់ជាក់លាក់នោះទេ ដែលនេះជាទូទៅ គេហៅថាប័ណ្ណវិជ្ជាជីវៈ (អាជ្ញាប័ណ្ណ)។ ជាទូទៅការផ្តល់ប័ណ្ណវិជ្ជាជីវៈ ត្រូវបានផ្អែកលើលិខិតបទដ្ឋានគតិយុត្ត ជាតម្រូវការរបស់រដ្ឋាភិបាល ដែលពាក់ព័ន្ធនឹងការការពារសុវត្ថិភាពសាធារណៈ និងត្រូវបានគ្រប់គ្រងដោយស្ថាប័នដែលជាបញ្ញត្តិករ។

ក្នុងករណីខ្លះ ប្រព័ន្ធផ្តល់គុណវុឌ្ឍិសមត្ថភាពស្ថិតនៅក្រៅក្របខណ្ឌគុណវុឌ្ឍិជាតិ ឬប្រព័ន្ធផ្តល់គុណវុឌ្ឍិផ្លូវការ ដោយមិនគិតថា តើត្រូវបានបង្កើតឡើងដោយរដ្ឋាភិបាល ស្ថាប័នវិជ្ជាជីវៈ ឬសហគ្រាសនោះទេ។ ប្រព័ន្ធផ្តល់គុណវុឌ្ឍិសមត្ថភាពនេះ អាចមានលើសពីមួយប្រភេទ (ឧទាហរណ៍៖ រដ្ឋាភិបាល ស្ថាប័នវិជ្ជាជីវៈ សហគ្រាសឯកជន) ដែលបានបង្កើតនៅក្នុងប្រទេសនោះ។ ក្នុងករណីខ្លះ ប្រព័ន្ធផ្តល់គុណវុឌ្ឍិសមត្ថភាព មិនអាចផ្តល់គុណវុឌ្ឍិ ឬលទ្ធផលការងារពេញលេញនោះទេ គឺអាចចេញត្រឹមជាសេចក្តីប្រកាសអំពីសមត្ថភាពដែលសម្រេចបាន។
គោលការណ៍ណែនាំនេះ ទាក់ទងយ៉ាងជាក់លាក់ទៅនឹងប្រព័ន្ធផ្តល់គុណវុឌ្ឍិសមត្ថភាព ដែលត្រូវបានអភិវឌ្ឍតាមរយៈលិខិតបទដ្ឋានគតិយុត្តដូចជាច្បាប់ ក្រឹត្យ ឬបទបញ្ជា និងត្រូវបានគ្រប់គ្រងដោយភ្នាក់ងាររដ្ឋាភិបាល ឬអង្គភាពឯករាជ្យមិនមែនរដ្ឋាភិបាល។ ប្រព័ន្ធផ្តល់គុណវុឌ្ឍិសមត្ថភាពពាក់ព័ន្ធនឹងអង្គការវិជ្ជាជីវៈ ឬសហគ្រាសឯកជនអាចប្រើប្រាស់គោលការណ៍ណែនាំនេះ ដោយផ្តល់នូវព័ត៌មានអំពីការអនុវត្តរបស់ពួកគេ។

### *និន្នាការទូទៅនៃប្រព័ន្ធផ្តល់គុណវុឌ្ឍិសមត្ថភាព*

ប្រព័ន្ធផ្តល់គុណវុឌ្ឍិសមត្ថភាពនៃប្រទេសជាសមាជិកអាស៊ាន ត្រូវបានផ្តោតទៅលើការអភិវឌ្ឍ និងការទទួលបាននូវសមត្ថភាព។ ប្រព័ន្ធផ្តល់គុណវុឌ្ឍិសមត្ថភាពក្នុងតំបន់ ជាទូទៅផ្តោតលើជំនាញកម្រិតទាប ទៅមធ្យម ប៉ុន្តែក៏អាចទាក់ទងនឹងជំនាញកម្រិតខ្ពស់ ឬមុខរបរផងដែរ ឧទាហរណ៍ក្របខណ្ឌគុណវុឌ្ឍិវិជ្ជាជីវៈអាជីពប្រទេសថៃ។
ប្រព័ន្ធផ្តល់គុណវុឌ្ឍិសមត្ថភាពរបស់ប្រទេសជាសមាជិកអាស៊ាន ជាទូទៅស្ថិតនៅក្រោមក្រសួងទទួលបន្ទុកការអភិវឌ្ឍកម្លាំងពលកម្មជំនាញ។ ទោះជាយ៉ាងណាក៏ដោយ ថ្មីៗនេះប្រព័ន្ធផ្តល់គុណវុឌ្ឍិសមត្ថភាពបានបង្កើត ដោយរដ្ឋាភិបាល និងត្រូវបានគ្រប់គ្រងដោយស្ថាប័ន/អង្គភាពមានសមត្ថកិច្ចឯករាជ្យមួយ ដូចជានៅ ប្រទេសថៃប្រព័ន្ធផ្តល់គុណវុឌ្ឍិសមត្ថភាពត្រូវទទួលបន្ទុកដោយវិទ្យាស្ថានគុណវុឌ្ឍិវិជ្ជាជីវៈអាជីពថៃ (TPQI) និងនៅប្រទេសឥណ្ឌូនេស៊ីគ្រប់គ្រងដោយទីភ្នាក់ងារជាតិវិជ្ជាជីវៈអាជីព (BNSP) ឥណ្ឌូនេស៊ី។

### *ភាពបន្ស៊ីគ្នានៃប្រព័ន្ធផ្តល់គុណវុឌ្ឍិសមត្ថភាពទៅនឹងប្រព័ន្ធគុណវុឌ្ឍិ*

ក្នុងករណីជាច្រើន ប្រព័ន្ធផ្តល់គុណវុឌ្ឍិសមត្ថភាពបានបង្កើតមុនពេលធ្វើការអភិវឌ្ឍ និងការអនុម័តក្របខណ្ឌគុណវុឌ្ឍិជាតិ។ ក្នុងករណីខ្លះទៀត បញ្ហាខាងលើបណ្តាលឱ្យមានភាពមិនស៊ីគ្នារវាងប្រព័ន្ធមួយដែលមានឯកសារបញ្ជាក់ពីកម្រិតនៃសមត្ថភាព និងការពិពណ៌នាអំពីកម្រិតនីមួយៗដែលបានស្នើក្នុងក្របខណ្ឌគុណវុឌ្ឍិជាតិ។ ការរកឱ្យឃើញនូវចំណុចរួម ឬសុខដុមនីយកម្មនៃក្របខណ្ឌទាំងពីរជារឿយៗ នៅតែជាឧបសគ្គគន្លឹះក្នុងការព្រមព្រៀង និងការអនុវត្តក្របខណ្ឌគុណវុឌ្ឍិជាតិ។

ក្របខណ្ឌគុណវុឌ្ឍិជាតិដែលបានអភិវឌ្ឍថ្មីៗនេះ ផ្តោតលើការរួមបញ្ចូលប្រព័ន្ធផ្តល់គុណវុឌ្ឍិសមត្ថភាពដែលមានស្រាប់នៅក្នុងក្របខណ្ឌគុណវុឌ្ឍិជាតិនោះ។ ក្របខណ្ឌគុណវុឌ្ឍិជាតិដែលផ្តល់នូវក្របខណ្ឌមានរចនាសម្ព័ន្ធចម្រុះ គឺមិនមែនជាប្រភេទក្របខណ្ឌថ្មីឡើយ។ នៅប្រទេសអាហ្វ្រិកខាងត្បូងមានអាជ្ញាធរតែមួយដែលទទួលបន្ទុកក្របខណ្ឌគុណវុឌ្ឍិជាតិ។ ដោយឡែកមានប្រទេសផ្សេងទៀត វិស័យមួយក្នុងចំណោមវិស័យទាំងបីក្នុងការអប់រំ

និងបណ្តុះបណ្តាល មានអនុក្របខណ្ឌចំនួនបីដែលគ្រប់គ្រងដោយក្រុមប្រឹក្សាគុណភាពទទួលបន្ទុកការធានាគុណភាព។ វិធីសាស្ត្រស្រដៀងគ្នានេះ ត្រូវបានអនុវត្តនៅក្នុងប្រទេសថៃដែលបានបង្កើតនូវក្របខណ្ឌមានរចនាសម្ព័ន្ធចម្រុះ ដើម្បីភ្ជាប់ក្របខណ្ឌដែលមានស្រាប់ និងប្រព័ន្ធផ្សេងគ្នាទៅជាក្របខណ្ឌរួមមួយ។ តារាងខាងក្រោមបង្ហាញពីភាពបន្សុីគ្នានៃក្របខណ្ឌរួមនោះ។

**តារាងទី ៣៖ ក្របខណ្ឌគុណវុឌ្ឍិជាតិថៃ**

| គុណវុឌ្ឍិនៃការអប់រំ | | | កម្រិតនៃ ក.គ.ជ | ស្តង់ដាសមត្ថភាព/ជំនាញ | |
|---|---|---|---|---|---|
| កម្រិតមូលដ្ឋាន | អ.ប.វ | ឧត្តមសិក្សា | | TPQI | DSD |
| | | បណ្ឌិត | ៩ | | |
| | | M. +Cert | ៨ | | |
| | | អនុបណ្ឌិត | ៧ | ៧ | |
| | | B. +Cert | ៦ | ៦ | |
| | បរិញ្ញាបត្រ | បរិញ្ញាបត្រ | ៥ | ៥ | ៣* |
| | សញ្ញាបត្រ | បរិញ្ញាបត្ររង | ៤ | ៤ | ២ |
| | វិញ្ញាបនបត្រ | | ៣ | ៣ | ១ |
| មធ្យមសិក្សាទុតិយភូមិ | | | ២ | ២ | |
| មធ្យមសិក្សាបឋមភូមិ | | | ១ | ១ | |

*ប្រភព៖ ទិដ្ឋភាពទូទៅរបស់ប្រទេសថៃ សេចក្តីព្រាង ឆ្នាំ២០១៤។*

***ចំណាំ៖**

កិច្ចប្រជុំក្រុមការងារពិសេស (ខែកុម្ភៈ ឆ្នាំ២០១៦) បានបញ្ជាក់ប្រាប់ពីទិន្នន័យខាងលើ។ អ្នកតំណាងរបស់ប្រទេសថៃបានបញ្ជាក់ថា មាន៤ កម្រិត ប៉ុន្តែអនុវត្តបានពេញលេញតែ ៣ កម្រិតទេ។

### *កម្រិតនៃការផ្តល់គុណវុឌ្ឍិ*

នៅប្រទេសខ្លះ ប្រព័ន្ធផ្តល់គុណវុឌ្ឍិសមត្ថភាពបានបង្កើតពីកម្រិតសមត្ថភាព និងបានអភិវឌ្ឍការពិពណ៌នាអំពីសមត្ថភាពក្នុងកម្រិតទាំងនោះ។ ក្នុងករណីខ្លះ ដំណើរការនេះ គឺជាការរៀបចំមុនក្របខណ្ឌគុណវុឌ្ឍិជាតិ ឬបង្កើតដាច់ដោយឡែកពីក្របខណ្ឌគុណវុឌ្ឍិជាតិ។ តារាងខាងក្រោម ជាឧទាហរណ៍បង្ហាញពីកម្រិតសមត្ថភាពនៃប្រទេសជាសមាជិកអាស៊ានចំនួន ៥ ដែលបានដាក់បញ្ចូលក្នុងប្រព័ន្ធផ្តល់គុណវុឌ្ឍិសមត្ថភាព។

### តារាងទី ៤៖ កម្រិតជំនាញ

| ប្រទេស | កម្រិតជំនាញ |
|---|---|
| ឡាវ | ៤ (+basic) |
| ម៉ាឡេស៊ី | ៥ |
| ភូមា (មីយ៉ាន់ម៉ា) | ៤ |
| ហ្វីលីពីន | ៥ |
| ថៃ | |
| • ជំនាញ (Skills) | ៤* |
| • វិជ្ជាជីវៈអាជីព (Professionals) | ៧ |
| វៀតណាម | ៥ |

*ប្រភព៖ ការបញ្ជាក់របស់អ្នកតំណាងក្នុងកិច្ចប្រជុំក្រុមការងារពិសេសក្នុងខែកុម្ភៈ ឆ្នាំ២០១៦។*

**ចំណាំ៖**

*មាន ៤ កម្រិត ប៉ុន្តែអនុវត្តបានពេញលេញតែ ៣ កម្រិតទេ។

ប្រព័ន្ធផ្តល់គុណវុឌ្ឍិសមត្ថភាព គឺជាការពិពណ៌នាអំពីកម្រិតចំណេះដឹង និងជំនាញ ហើយការពិពណ៌នានេះមានភាពខុសគ្នាក្នុងប្រទេសជាសមាជិកអាស៊ាន។ នៅពេលដែលក្រខណ្ឌគុណវុឌ្ឍិជាតិត្រូវបានប្រើប្រាស់កាន់តែទូលំទូលាយក្នុងប្រទេសជាសមាជិកអាស៊ាន ការពិពណ៌នាអំពីកម្រិតចំណេះដឹង និងជំនាញនៃប្រព័ន្ធផ្តល់គុណវុឌ្ឍិសមត្ថភាពអាចត្រូវបានដាក់បញ្ចូល ឬរំលាយចូលគ្នាទៅក្នុងការពិពណ៌នាសមត្ថភាពក្នុងកម្រិតនីមួយៗនៃក្របខណ្ឌគុណវុឌ្ឍិជាតិ។

គំរូខាងក្រោមនេះ បានពីប្រទេសវៀតណាម បង្ហាញពីការពិពណ៌នានៃកម្រិតចំនួនប្រាំ និងភាពទាក់ទងគ្នានៃវិញ្ញាបនបត្រជាតិ។

### តារាងទី ៥៖ កម្រិតគុណវុឌ្ឍិជំនាញជាតិរបស់ប្រទេសវៀតណាម

| កម្រិតគុណវុឌ្ឍិជំនាញជាតិ | | |
|---|---|---|
| **កម្រិត** | **លក្ខខណ្ឌតម្រូវ** | **គុណវុឌ្ឍិ** |
| កម្រិត ១ | ក) មានសមត្ថភាពក្នុងការអនុវត្តកិច្ចការងាយៗ ហើយកិច្ចការដដែលៗក្នុងមុខរបរមួយ<br>ខ) យល់ដឹង និងមានចំណេះដឹងមូលដ្ឋានក្នុងដែនប្រតិបត្តិការតូចៗនៃមុខរបរណាមួយនៃវិស័យមួយចំនួនអាចអនុវត្តចំណេះដឹងជាក់លាក់មួយចំនួនពេលអនុវត្តកិច្ចការ<br>គ) មានសមត្ថភាពទទួលធ្វើកំណត់ត្រា និងបញ្ជូនព័ត៌មានតាមតម្រូវការ ការទទួលខុសត្រូវមានកម្រិតលើលទ្ធផលរបស់ខ្លួន | វិញ្ញាបនបត្រ ១ |
| កម្រិត ២ | ក) មានសមត្ថភាពក្នុងការអនុវត្តកិច្ចការងាយៗ ដដែលៗ និងមានកិច្ចការស្មុគស្មាញមួយចំនួននៅក្នុងដែននៃស្ថានភាពដែលបានកំណត់ទុក និងស្ថិតក្រោមការណែនាំ<br>ខ) យល់ដឹង និងមានចំណេះដឹងមូលដ្ឋានមួយចំនួននៃប្រតិបត្តិការលើមុខជំនាញណាមួយ ដែលអាចអនុវត្តចំណេះដឹងវិជ្ជាជីវៈខ្លះៗ និងអាចមានដំណោះស្រាយមួយចំនួន ចំពោះបញ្ហាធម្មតានៅក្នុងការងាររបស់ពួកគេ<br>គ) មានសមត្ថភាពពិចារណា ព្យាករណ៍ និងពន្យល់ព័ត៌មាន អាចធ្វើការជាក្រុម អាចធ្វើការដោយឯករាជ្យនៅក្នុងករណីខ្លះ និងមានទំនួលខុសត្រូវភាគច្រើនចំពោះលទ្ធផលដោយខ្លួនឯង | វិញ្ញាបនបត្រ ២ |
| កម្រិត ៣ | ក) មានសមត្ថភាពក្នុងការអនុវត្តកិច្ចការផ្សេងៗគ្នា ភាគច្រើនមានលក្ខណៈស្មុគស្មាញនៅក្នុងលំដាប់ជ្រើសរើស អាចធ្វើកិច្ចការដោយឯករាជ្យ ដោយគ្មានការណែនាំ | វិញ្ញាបនបត្រ ៣ |

| | | |
|---|---|---|
| | ខ) យល់ដឹង និងមានចំណេះដឹង គំនិតទ្រឹស្តីមូលដ្ឋាន ចំណេះដឹងវិជ្ជាជីវៈនៃមុខរបរអាចអនុវត្តចំណេះដឹងវិជ្ជាជីវៈ និងអាចកំណត់ ក្នុងការអនុវត្តចំណេះដឹង ដើម្បីដោះស្រាយបញ្ហាធម្មតានៅក្នុងបរិបទផ្សេងៗ<br>គ) អាចកំណត់ ចាត់ចំណាត់ថ្នាក់ វិភាគ និងវាយតម្លៃព័ត៌មានពីប្រភពផ្សេងៗ អាចផ្តល់ការណែនាំដល់អ្នកផ្សេងៗនៅក្នុងក្រុមការងារនានា មានទំនួលខុសត្រូវចំពោះលទ្ធផលរបស់ខ្លួនឯង ជាមួយស្តង់ដាគុណភាពដែលបានកំណត់ និងមានការទទួលខុសត្រូវដែលបានកំណត់លើលទ្ធផលរបស់អ្នកផ្សេងនៅក្នុងក្រុមការងារនានា។ | |
| កម្រិត ៤ | ក) មានសមត្ថភាពក្នុងការអនុវត្តកិច្ចការផ្សេងៗក្នុងរូបភាពទូលំទូលាយ ដែលភាគច្រើនមានសភាពស្មុគ្រស្មាញ និងមានជម្រើសច្រើនផ្សេងៗគ្នា អាចធ្វើការដោយឯករាជ្យ ដោយគ្មានការត្រួតពិនិត្យ និងការដឹកនាំឡើយ<br>ខ) យល់ដឹង និងមានចំណេះដឹងទូលំទូលាយលើទ្រឹស្តីជាមូលដ្ឋាន និងមានចំណេះដឹងស៊ីជម្រៅលើវិជ្ជាជីវៈក្នុងជំនាញផ្សេងៗគ្នានៃមុខរបរ អាចផ្ទេរ អនុវត្តចំណេះដឹង និងជំនាញប្រកបដោយភាពច្នៃប្រឌិតដើម្បីដោះស្រាយបញ្ហាបច្ចេកទេសដែលស្មុគ្រស្មាញក្នុងបរិបទផ្សេងៗ<br>គ) អាចវិភាគ វាយតម្លៃព័ត៌មាន និងប្រើប្រាស់ការវិភាគ ដើម្បីលើកជាគំនិត អនុសាសន៍សម្រាប់ការស្រាវជ្រាវ និងការគ្រប់គ្រង។ អាចចាត់ចែង និងធ្វើការជាក្រុមនៅពេលប្រតិបត្តិការងារ មានទំនួលខុសត្រូវចំពោះលទ្ធផលផ្ទាល់ខ្លួនឱ្យត្រូវតាមស្តង់ដាគុណ ភាពជាក់លាក់ដែលបានកំណត់ និងមានការទទួលខុសត្រូវក្នុងដែនកំណត់សម្រាប់លទ្ធផល និងទិន្នផលនៃការងារជាក្រុម | វិញ្ញាបនបត្រ ៤ |
| កម្រិត ៥ | ក) មានសមត្ថភាពក្នុងការប្រតិបត្តិគ្រប់កិច្ចការផ្សេងៗគ្នាទាំងអស់នៃមុខរបរបានយ៉ាងស្ទាត់ និងប៉ិនប្រសប់ ធ្វើការដោយមានឯករាជ្យភាពខ្ពស់ មានស្វ័យត្រួតពិនិត្យខ្ពស់<br>ខ) មានចំណេះដឹងទូលំទូលាយលើទ្រឹស្តីជាមូលដ្ឋាន និងមានចំណេះដឹងស៊ីជម្រៅលើវិជ្ជាជីវៈក្នុងជំនាញផ្សេងៗគ្នានៃមុខរបរ មានបច្ចេកទេសចំពោះការវិភាគ ការព្យាករណ៍ ការរចនា ការពិចារណាក្នុងការដោះស្រាយទាំងបញ្ហាបច្ចេកទេស និងការគ្រប់គ្រង នៅក្នុងវិសាលភាពទូលំទូលាយ<br>គ) អាចវិភាគ វាយតម្លៃ និងអាចបញ្ចេញមតិយោបល់ដោយឈរលើព័ត៌មានទូទៅដែលបានផ្តល់ និងគំនិតច្នៃប្រឌិត គ្រប់គ្រង និងធ្វើការជាក្រុមនៅពេលប្រតិបត្តិការងារ មានទំនួលខុសត្រូវចំពោះលទ្ធផលខ្លួនឯងឱ្យត្រូវតាមស្តង់ដាគុណភាពជាក់លាក់ដែលបានកំណត់ និងមានទំនួលខុសត្រូវចំពោះលទ្ធផលនៃការងារជាក្រុមឱ្យស្របនឹងស្តង់ដាជាក់លាក់ និងលក្ខខណ្ឌបច្ចេក-ទេស លម្អិតដែលបានកំណត់។ | វិញ្ញាបនបត្រ ៥ |

*ប្រភព៖ ស្តង់ដាជំនាញជាតិ អគ្គនាយកដ្ឋានបណ្តុះបណ្តាលជំនាញ ក្រសួងការងារ ជនពិការ និងសង្គមកិច្ច។*

### និយមន័យសមត្ថភាព

ការស្រាវជ្រាវថ្មីៗ (សេចក្តីព្រាងរបស់ក្រុមស្រាវជ្រាវធនាគារពិភពលោក ឆ្នាំ២០១៥) បង្ហាញថាក្នុងភាសានៃការអប់រំ និងបណ្តុះបណ្តាល សមត្ថភាពមាននិយមន័យខុសៗគ្នា ហើយជារឿយៗ វិធីសាស្ត្រនៃការកំណត់និយមន័យនៃពាក្យសមត្ថភាព អាចមានការប្រែប្រួលទៅតាមរបៀបដែលឯកសារត្រូវបានគេកត់ត្រា និងវាយតម្លៃ។ ការរកឃើញនេះ ឆ្លុះបញ្ចាំងពីនិយមន័យនានា ដែលមានស្រាប់នៅក្នុងប្រទេសជាសមាជិកអាស៊ាន។ តារាងខាងក្រោមសង្ខេបនូវនិយមន័យសមត្ថភាពរបស់ប្រទេសនីមួយៗ។

**តារាងទី ៦៖ និយមន័យនៃវាក្យសព្ទសមត្ថភាព**

| ប្រទេស | និយមន័យ |
|---|---|
| កម្ពុជា | ស្តង់ដាជំនាញ "ការតម្រូវសម្រាប់ការប្រតិបត្តិកិច្ចការប្រកបដោយប្រសិទ្ធភាពនៅ កន្លែងការងារ ជាលក្ខខណ្ឌតម្រូវចំណេះដឹង ជំនាញ និងឥរិយាបថជាក់លាក់ ដែលជាការកំណត់កម្រិតប្រតិបត្តិរបស់ពលករជំនាញនៅក្នុងមុខរបរជាក់លាក់ មួយដែលត្រូវតែសម្រេចឱ្យបាន"។ |
| ឥណ្ឌូនេស៊ី | សមត្ថភាពផ្នែកចំណេះដឹង ជំនាញ និងឥរិយាបថដែលត្រូវអនុវត្តនៅកន្លែងការងារ |
| ឡាវ | សមត្ថភាព គឺជាចំណេះដឹង ជំនាញ និងឥរិយាបថពាក់ព័ន្ធ ដែលត្រូវអនុវត្តចំពោះ ស្តង់ដាប្រតិបត្តិដែលរំពឹងទុកនៅក្នុងកន្លែងការងារ។ សមត្ថភាពត្រូវបានពណ៌នាពីកិច្ចការនៃមុខរបរនៅក្នុងតួនាទីការងារ នៃមុខរបរណាមួយជាក់លាក់ |
| ម៉ាឡេស៊ី | សមត្ថភាព ត្រូវបានកត់សម្គាល់ថា ជាលទ្ធភាពដែលទទួលបាន និងបានអនុវត្តប្រកបដោយភាពប៉ិនប្រសប់លើកិច្ចការ ឬមុខរបរណាមួយ |
| ភូមា (មីយ៉ាន់ម៉ា) | ចំណេះដឹង ជំនាញ និងភាពប៉ិនប្រសប់ |
| ហ្វីលីពីន | សមត្ថភាពត្រូវបានកត់សម្គាល់ថាជា «ភាពអាចធ្វើបាន ឬភាពប៉ិនប្រសប់ និងផ្តោតចំពោះការអនុវត្ត ចំណេះដឹង ជំនាញ និងឥរិយាបថដែលត្រូវការបំពេញសកម្មភាពការងារក្នុងលំដាប់នៃបរិបទ និង បរិស្ថាន ចំពោះស្តង់ដាដែលរំពឹងទុកនៅកន្លែងធ្វើការងារ" (TESDA) |
| សិង្ហបុរី | សមត្ថភាព គឺជាសំណុំនៃចំណេះដឹង ជំនាញ និងឥរិយាបថដែលអាចវាស់វែងបាន ដែលជំរុញឱ្យការបំពេញការងាររបស់បុគ្គលម្នាក់ៗ អនុវត្តការងារប្រកបដោយប្រសិទ្ធភាព |
| ថៃ | វិស័យវិជ្ជាជីវៈ និងជំនាញ៖ សមត្ថភាព គឺជាកម្រិតនៃការរំពឹងទុក និងការទទួលយកតាមការតម្រូវលើគុណភាពនៃដំណើរការ ឬផលិតផលនៃការសម្តែងរបស់បុគ្គល ឬ/ និងការដោះស្រាយបញ្ហា ការបង្ហាញការអនុវត្តដោយដៃនូវសមត្ថភាពរបស់ពួកគាត់បន្ទាប់ពីការសិក្សារបទពិសោធន៍ការងារ |
| | វិស័យវិជ្ជាជីវៈអាជីព៖ សមត្ថភាពគឺជាការអនុវត្តចំណេះដឹង និងបទពិសោធន៍ការងារ។ |
| វៀតណាម | សមត្ថភាព គឺជាចំណេះដឹង ជំនាញ និងឥរិយាបថដ៏សំខាន់សម្រាប់ការបំពេញកិច្ចការនៃមុខរបរមួយ។ |

*ប្រភព៖ សេចក្តីព្រាងអត្ថបទ ដោយក្រុមការងារធនាគារពិភពលោក ឆ្នាំ២០១៥។*

នៅពេលថ្មីៗនេះ ប្រទេសជាសមាជិកអាស៊ានបានបញ្ជាក់ពីការឯកភាពគ្នាលើវាក្យសព្ទបច្ចេកទេស ដែលប្រើថ្នាក់តំបន់ តាមរយៈក្របខណ្ឌគុណវុឌ្ឍិយោងអាស៊ាន ដូចកំណត់ខាងក្រោម៖

សមត្ថភាព គឺជាលទ្ធភាពក្នុងការពង្រីកនូវចំណេះដឹង និងជំនាញដែលមាន រួមបញ្ចូលនូវ៖

*i) សមត្ថភាពក្នុងការគិត គឺជាការប្រើប្រាស់ទ្រឹស្តី និងគោលគំនិត ព្រមទាំងចំណេះដឹងក្រៅផ្លូវការដែលទទួលបានតាមរយៈបទពិសោធន៍*

*ii) សមត្ថភាពផ្នែកមុខងារ (ជំនាញ ឬយល់ដឹងរបៀបធ្វើ) ដែលមុខងារទាំងនោះ បុគ្គលម្នាក់ៗមានសមត្ថភាពធ្វើបានលើការងារជាជំនាញរបស់ខ្លួនដែលគេប្រគល់ឱ្យ*

*iii) សមត្ថភាពផ្ទាល់ខ្លួន គឺជាការយល់ដឹងពីរបៀបដឹកនាំខ្លួនឯងនៅក្នុងស្ថានភាពជាក់លាក់*

*iv) សមត្ថភាពខាងក្រមសីលធម៌ គឺការប្រកាន់ខ្ជាប់គុណតម្លៃផ្ទាល់ខ្លួននិងវិជ្ជាជីវៈជាក់លាក់។*[22]

កិច្ចព្រមព្រៀងលើនិយមន័យនេះ មិនមានន័យថា ប្រទេសជាសមាជិកអាស៊ានត្រូវការផ្លាស់ប្តូរនូវនិយមន័យរបស់ប្រទេសខ្លួននោះទេ ប៉ុន្តែនៅក្នុងកិច្ចពិភាក្សា និងគំនិតផ្តួចផ្តើមនានាថ្នាក់តំបន់ និយមន័យនេះត្រូវបានអនុវត្ត។

### ***ការធានាគុណភាពក្នុងការផ្តល់គុណវុឌ្ឍិ***[23]

ប្រទេសជាសមាជិកអាស៊ាននីមួយៗបានអនុវត្តដំណើរការធានាគុណភាពសំខាន់ៗតាមវិធីផ្សេងៗគ្នា ដូចខាងក្រោមនេះ៖

១. ការអភិវឌ្ឍស្តង់ដាសមត្ថភាព
២. សមត្ថភាពអ្នកវាយតម្លៃ
៣. សមត្ថភាពអ្នកផ្តល់សេវា
៤. ការវាយតម្លៃសមត្ថភាព
៥. ទំនុកចិត្តក្នុងការសម្រេចចិត្តលើការវាយតម្លៃសមត្ថភាព។

### **១. ការអភិវឌ្ឍ និងទម្រង់ស្តង់ដាសមត្ថភាព**

ប្រទេសជាសមាជិកអាស៊ាន ភាគច្រើនកំពុងអភិវឌ្ឍស្តង់ដាសមត្ថភាព ឬស្តង់ដាមុខរបរនៅក្នុងវិស័យ អប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ប៉ុន្តែនៅក្នុងករណីភាគច្រើន ប្រទេសនានាប្រើប្រាស់វាក្យសព្ទ ស្តង់ដាសមត្ថភាព ឬស្តង់ដាមុខរបរ ជំនួសគ្នាទៅវិញទៅមកបាន។ ក្នុងការអភិវឌ្ឍស្តង់ដាសមត្ថភាពនៅក្នុងប្រទេសជាសមាជិកអាស៊ាន ភាគច្រើនអនុវត្តដំណើរការប្រហាក់ប្រហែលគ្នា។ ប្រទេសជាសមាជិកអាស៊ាន ភាគច្រើន កំពុងរៀបចំជាឯកសារណែនាំ ឬគោលការណ៍ណែនាំជាផ្លូវការអំពីដំណើរការអភិវឌ្ឍស្តង់ដាសមត្ថភាព ហើយរដ្ឋាភិបាលជាអ្នកទទួលបន្ទុកទាំងស្រុង។ ប្រទេសជាសមាជិកអាស៊ានទាំងអស់ប្រើប្រាស់តំណាងឧស្សាហកម្មផ្នែកឯកជនក្នុងដំណើរការអភិវឌ្ឍស្តង់ដាសមត្ថភាព ក្នុងទម្រង់មួយចំនួន (ឧទាហរណ៍៖ ក្រុមការងារបច្ចេកទេស កិច្ចប្រជុំអនុម័តដោយវិស័យឧស្សាហកម្ម ក្រុមនិយោជក ក្រុមអ្នកឯកទេស) និងជារឿយៗ បានប្រើប្រាស់គ្រូបច្ចេកទេសជំនាញ ឬស្ថាប័ន/អង្គភាពបណ្តុះបណ្តាល។ ដំណើរការអភិវឌ្ឍ រួមបញ្ចូលទាំងការអភិវឌ្ឍកម្មវិធីសិក្សា (DACUM) និងការវិភាគមុខងារ (Functional Analysis) និងការវិភាគកិច្ចការនៃមុខរបរ (Job Task Analysis) រួមទាំងការស្រាវជ្រាវពីស្តង់ដាអន្តរជាតិ និងកម្មវិធីបណ្តុះបណ្តាលពាក់ព័ន្ធដែលមានស្រាប់។ ការអនុម័តស្តង់ដាសមត្ថភាពចុងក្រោយ ជាទូទៅធ្វើឡើងដោយស្ថាប័ន/អង្គភាពមានសមត្ថកិច្ច ប៉ុន្តែក្នុងករណីខ្លះ ការអនុម័តចុងក្រោយ ត្រូវធ្វើឡើងដោយគណៈកម្មាធិការមួយដែលរួមមានតំណាងវិស័យឧស្សាហកម្ម (ឧទាហរណ៍៖ ប្រទេសឡាវ)។[24]

ជាធម្មតា ទម្រង់ស្តង់ដាសមត្ថភាពមានលក្ខណៈស្រដៀងៗគ្នានៅក្នុងវិស័យអប់រំបណ្តុះបណ្តាបច្ចេកទេសនិងវិជ្ជាជីវៈ។ ជាទូទៅ ប្រទេសអាស៊ានភាគច្រើនមាននិន្នាការតម្រូវតាមទម្រង់ស្តង់ដាសមត្ថភាព ឬមុខរបរទៅនឹងគំរូស្តង់ដាសមត្ថភាពថ្នាក់តំបន់របស់អង្គការអន្តរជាតិខាងការងារ (ILO)។[25] ទម្រង់របស់ស្តង់ដាសមត្ថភាព ជាទូទៅរួមមាន៖

- ព័ត៌មានអំពីសាវតារនៃមុខរបរ
- លេខកូដ និងចំណងជើងផ្នែកសមត្ថភាព
- ការពណ៌នា អំពីផ្នែកសមត្ថភាព
- ផ្នែកនៃសមត្ថភាព
    - ធាតុសមត្ថភាព និងលក្ខណវិនិច្ឆ័យនៃការប្រតិបត្តិ
    - លក្ខខណ្ឌនៃលំដាប់អថេរ និងសេចក្តីថ្លែងអំពីដែនកំណត់
    - ការណែនាំក្នុងការកំណត់ភស្តុតាង

[22] Coles & Werquin (2006). p.23.
[23] Coles & Werquin (2006). p.23.
[24] World Bank Group draft 2015
[25] Updated guidelines for development of Regional Model Competency Standards, 2016

តាមបណ្ដាប្រទេសអាស៊ានភាគច្រើន ស្តង់ដាសមត្ថភាពត្រូវបានចែកចេញជា សមត្ថភាពស្នូល និងសមត្ថភាពបន្ទាប់បន្សំដែលគ្របដណ្ដប់លើសមត្ថភាពបច្ចេកទេសជំនាញ និងសមត្ថភាពទូទៅ។

នៅក្នុងកម្រងសមត្ថភាពសម្រាប់ការផ្ដល់គុណវុឌ្ឍិ[26] អាចទទួលលទ្ធផលជាគុណវុឌ្ឍិពេញលេញ ឬជាផ្នែកនៃគុណវុឌ្ឍិ។ តែទោះបីយ៉ាងណា ក្នុងករណីទាំងពីរនេះ កម្រងនៃស្តង់ដាសមត្ថភាព ឬស្តង់ដាមុខរបរត្រូវបានចងក្រងជាចង្កោមមុខងារនៅក្នុងមុខរបរ ឬគុណវុឌ្ឍិ។ បណ្ដាប្រទេសមួយចំនួន បានប្រើវាក្យសព្ទផ្សេងៗរបស់កម្រងនៃស្តង់ដា និងបទប្បញ្ញត្តិពេញលេញ ដែលជារឿយៗគាំទ្រដោយព័ត៌មានបន្ថែម មានដូចជា៖

- ក្របខណ្ឌសមត្ថភាព (ប្រទេសប្រ៊ុយណេ)
- បទប្បញ្ញត្តិបណ្តុះបណ្តាល (ប្រទេសហ្វីលីពីន)
- ក្របខណ្ឌគុណវុឌ្ឍិជំនាញការងារ (Workforce Skills Qualifications (WSQ) Frameworks) (ប្រទេសសិង្ហបុរី)

## ២. អ្នកវាយតម្លៃសមត្ថភាព

ប្រព័ន្ធផ្តល់គុណវុឌ្ឍិសមត្ថភាពអាចរួមបញ្ចូលទាំងការបណ្តុះបណ្តាល និងការវាយតម្លៃសមត្ថភាព ក៏ប៉ុន្តែប្រព័ន្ធមួយចំនួនមានតែការវាយតម្លៃសមត្ថភាពសុទ្ធសាធ។ លក្ខខណ្ឌតម្រូវសម្រាប់អ្នកវាយតម្លៃសមត្ថភាព នៃប្រទេសជាសមាជិកអាស៊ាន ជាទូទៅ ត្រូវបានបញ្ចូលទៅក្នុងស្តង់ដាគុណភាព (ប្រទេសសិង្ហបុរី និងឥណ្ឌូនេស៊ី) ឬទៅក្នុងគោលនយោបាយ និងគោលការណ៍ណែនាំនានា (ប្រទេសហ្វីលីពីន និងម៉ាឡេស៊ី)។ ទោះបីលក្ខខណ្ឌតម្រូវជាក់លាក់អាចខុសក្នុងសេចក្តីលម្អិតក៏ដោយ ជាទូទៅលក្ខខណ្ឌតម្រូវអប្បបរមាសម្រាប់ទាំងគ្រូបណ្តុះបណ្តាល និង/ឬអ្នកវាយតម្លៃសមត្ថភាព យ៉ាងហោចណាស់ត្រូវមានសមត្ថភាពដូចមានចែងក្នុងមាតិកាវិជ្ជាជីវៈ និងជំនាញ ដូចជាគុណវុឌ្ឍិផ្នែកគរុកោសល្យ ហើយក្នុងករណីខ្លះត្រូវមានបទពិសោធន៍ពីកន្លែងការងារ។ ករណីខ្លះទៀត តម្រូវឱ្យអ្នកវាយតម្លៃសមត្ថភាព ត្រូវមានសំណុំសមត្ថភាពជាក់លាក់ពាក់ព័ន្ធនឹងការវាយតម្លៃផ្អែកលើសមត្ថភាព។ នៅប្រទេសខ្លះ លក្ខខណ្ឌតម្រូវសម្រាប់គ្រូបណ្តុះបណ្តាល/អ្នកវាយតម្លៃសមត្ថភាព គឺថ្មី ហើយមិនទាន់បានអនុវត្តពេញលេញ។

នៅប្រទេសអាស៊ានមួយចំនួន មានចុះបញ្ជិកាទទួលស្គាល់គ្រូបណ្តុះបណ្តាលថ្នាក់ជាតិ (ឧទាហរណ៍មាននៅប្រទេសហ្វីលីពីន និងប្រទេសថៃ [OVEC]) ហើយមានការចុះបញ្ជិកាទទួលស្គាល់អ្នកវាយតម្លៃមានលក្ខណសម្បត្តិគ្រប់គ្រាន់ (ឧទាហរណ៍៖ ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈហ្វីលីពីន និងប្រព័ន្ធផ្តល់គុណវុឌ្ឍិសមត្ថភាពរបស់ប្រទេសឥណ្ឌូនេស៊ី) ដែលជាកន្លែងសម្រាប់ត្រួតពិនិត្យកណ្តាលលើការវាយតម្លៃ។ នៅប្រទេសហ្វីលីពីន និងឥណ្ឌូនេស៊ី នៅក្នុងប្រព័ន្ធផ្តល់គុណវុឌ្ឍិសមត្ថភាពមានដំណើរការត្រួតពិនិត្យតាមដានលើអ្នកវាយតម្លៃសមត្ថភាព។

## ៣. សមត្ថភាពអ្នកផ្តល់សេវា

ការធានាគុណភាពដល់អ្នកផ្តល់សេវា[27] នៅតាមប្រទេសជាសមាជិកអាស៊ាន ជាទូទៅអាចទទួលខុសត្រូវដោយក្រសួងមួយ ឬពីរ។ ឧទាហរណ៍៖ ក្រសួងអប់រំ ឬក្រសួងការងារ។ ការរៀបចំចាត់ចែងការធានាគុណភាពអាចមានលក្ខណៈខុសៗគ្នា និងមិនចាំបាច់ត្រូវមានសង្គតិភាពក្នុងការអនុវត្តគ្រប់ប្រភេទនៃអ្នកផ្តល់សេវា អ.ប.វ ឡើយ។ ដំណើរការអនុម័តអាច៖

- មិនមានអណត្តិច្បាស់លាស់សម្រាប់ក្រុមអ្នកផ្តល់សេវា ប៉ុន្តែអាចទាមទារដោយក្រុមពិសេសណាមួយ
- សន្មត់សម្រាប់អ្នកផ្តល់សេវាដោយឡែកណាមួយ ឧទាហរណ៍៖ អ្នកផ្តល់សេវារបស់រដ្ឋាភិបាល
- មានអណត្តិសម្រាប់គ្រប់អ្នកផ្តល់សេវាទាំងអស់ ដើម្បីផ្តល់ការទទួលស្គាល់ក្នុងក្របខណ្ឌគុណវុឌ្ឍិជាតិ

ប្រទេសជាសមាជិកអាស៊ានភាគច្រើន លក្ខខណ្ឌតម្រូវសម្រាប់អនុម័ត (ចុះបញ្ជិកាទទួលស្គាល់គុណភាព) អ្នកផ្តល់សេវាត្រូវបានរៀបចំជាឯកសារដែលចែងក្នុងច្បាប់ ឬបទប្បញ្ញត្តិរបស់រដ្ឋាភិបាល ឬនៅក្នុងស្តង់ដាគុណភាព។

ការអនុវត្តនៃការត្រួតពិនិត្យតាមដានអ្នកផ្តល់សេវា និងទិន្នផលអ្នកផ្តល់សេវានៅក្នុងប្រព័ន្ធផ្តល់គុណវុឌ្ឍិសមត្ថភាពរបស់ប្រទេសជាសមាជិកអាស៊ាន ដែលបានបង្កើតឡើងនៅមានកម្រិតនៅឡើយ។ ភ្នាក់ងារទទួលខុសត្រូវរបស់ប្រទេសជាសមាជិកអាស៊ានមិនទាំងអស់ ដែលបានចុះបញ្ជិកាជាសាធារណៈ អមដោយគុណវុឌ្ឍិដែលពួកគេត្រូវបានយល់ព្រមផ្តល់ឱ្យ ឬវាយតម្លៃ។

---

[26] គ្រោងការផ្តល់គុណវុឌ្ឍិ គឺសមត្ថភាព និងលក្ខខណ្ឌតម្រូវផ្សេងៗទាក់ទងនឹងប្រភេទមុខរបរជាក់លាក់។ គ្រោងការផ្តល់គុណវុឌ្ឍិ អាចជាលទ្ធផលវិញ្ញាបនបត្រ ដែលបង្ហាញថា បុគ្គលម្នាក់អាចបំពេញបានតាមលក្ខខណ្ឌតម្រូវ ឬអាចរួមបញ្ចូលនៅក្នុងគុណវុឌ្ឍិ។

[27] អង្គភាពផ្តល់សេវាបណ្តុះបណ្តាល ការបណ្តុះបណ្តាល និងវាយតម្លៃសមត្ថភាព អង្គភាពផ្តល់សេវាវាយតម្លៃសមត្ថភាព

## ៤. ការវាយតម្លៃសមត្ថភាព

សមត្ថភាព អាចត្រូវទទួលបានតាមរយៈ៖

- ការបណ្តុះបណ្តាល
- បទពិសោធន៍ការងារ
- បទពិសោធន៍ក្នុងជីវិតរស់នៅ

ការវាយតម្លៃសមត្ថភាព ត្រូវបានប្រើសម្រាប់បញ្ជាក់ពីសមត្ថភាព។ ការវាយតម្លៃសមត្ថភាពអាចធ្វើឡើងនៅក្នុងស្ថាប័ន/អង្គភាពផ្តល់ការបណ្តុះបណ្តាល និងការវាយតម្លៃសមត្ថភាព ឬក៏នៅតែក្នុងអង្គភាពផ្តល់ការវាយតម្លៃសមត្ថភាព។ នៅប្រទេសជាសមាជិកអាស៊ានមួយចំនួន គេចាត់ទុកការចែកដាច់ពីគ្នារវាងការផ្តល់ការបណ្តុះបណ្តាល និងការវាយតម្លៃសមត្ថភាព ជាធាតុដ៏សំខាន់មួយដែលធ្វើឱ្យប្រព័ន្ធផ្តល់គុណវុឌ្ឍិសមត្ថភាពកាន់តែរឹងមាំ។ វិធីសាស្ត្របែបនេះ ចែកដាច់ពីគ្នា ក៏ដោយសារតែស្ថាប័នផ្តល់គុណវុឌ្ឍិមួយចំនួនប្រកាន់យកស្តង់ដានៃអង្គការអន្តរជាតិសម្រាប់ស្តង់ដានីយកម្ម/គណៈកម្មការបច្ចេកវិទ្យាអេឡិចត្រូនិចអន្តរជាតិស្តីពីភាពអនុលោមនៃការវាយតម្លៃសមត្ថភាព (ISO/EC17024:2012 Conformity Assessment) មានជាអាទិ៍លក្ខខណ្ឌតម្រូវទូទៅសម្រាប់ស្ថាប័ន/អង្គភាពអនុវត្តការផ្តល់គុណវុឌ្ឍិ។ ស្តង់ដានេះ សង្កត់ធ្ងន់លើតម្រូវការចាំបាច់សម្រាប់ភាពមិនលម្អៀងនៃសកម្មភាពផ្តល់គុណវុឌ្ឍិ ដែលការចែកដាច់រវាងការបណ្តុះបណ្តាល និងការវាយតម្លៃសមត្ថភាព គេចាត់ទុកថាជាការបញ្ជាក់ពីលក្ខខណ្ឌតម្រូវ។

នៅតាមប្រទេសជាសមាជិកអាស៊ាន សេវាវាយតម្លៃសមត្ថភាព ជាទូទៅមិនត្រូវបានគេមើលឃើញថា ជាការវាយតម្លៃទទួលស្គាល់សមត្ថភាពនៃការសិក្សាដែលមានពីមុននោះទេ ទោះបីតាមន័យបច្ចេកទេស សេវាវាយតម្លៃសមត្ថភាព និងការវាយតម្លៃទទួលស្គាល់សមត្ថភាពនៃការសិក្សាដែលមានពីមុន គឺតែមួយ និងមានភាពដូចគ្នាក៏ដោយ។ ដំណើរការទាំងពីរនេះពាក់ព័ន្ធនឹងការវាយតម្លៃសមត្ថភាពរបស់បុគ្គលម្នាក់ដោយអ្នកវាយតម្លៃសមត្ថភាព នោះមិនចាំបាច់ជាអ្នកនៅក្នុងការសិក្សារបស់គេឡើយ (ដោយមិនគិតថាការសិក្សាសម្រេចផលបានតាមមធ្យោបាយសិក្សាក្នុងប្រព័ន្ធ ក្រៅប្រព័ន្ធ ឬមិនផ្លូវការនោះទេ)។

## ៥. ការលើកកម្ពស់ទំនុកចិត្តនៅក្នុងការសម្រេចចិត្តលើការវាយតម្លៃសមត្ថភាព

ជាទូទៅ គេទទួលស្គាល់ថាការសម្រេចចិត្តលើការវាយតម្លៃសមត្ថភាព គឺត្រូវមានសុពលភាព និងជឿជាក់បាន។

*សុពលភាព ជាទូទៅពាក់ព័ន្ធជាមួយនឹងការសន្និដ្ឋាន ដែលទទួលបានពីលទ្ធផលនិងការប្រើប្រាស់សមស្របនៃការវាយតម្លៃសមត្ថភាព។ ក្នុងន័យសាមញ្ញថា វាជាការពាក់ព័ន្ធទៅនឹងវិសាលភាពនៃការសម្រេចចិត្តមួយលើការវាយតម្លៃសមត្ថភាពចំពោះបេក្ខជន (ឧទាហរណ៍៖ មានសមត្ថភាព ឬមិនទាន់មានសមត្ថភាព ចំណាត់ថ្នាក់ និង/ឬពិន្ទុ) ផ្អែកលើភស្តុតាងនៃការប្រតិបត្តិដែលផ្តល់ឱ្យដោយបេក្ខជនប្រកបដោយភាពត្រឹមត្រូវ។ ភាពជឿជាក់ ជាទូទៅ គឺជាការប៉ាន់ប្រមាណនូវភាពត្រឹមត្រូវ ឬភាពសុក្រឹតនៃកិច្ចការប្រតិបត្តិតាមរយៈឧបករណ៍វាស់/ប្រមូលភស្តុតាង។ ភាពជឿជាក់ ពាក់ព័ន្ធនឹងថាតើមានកំហុសប៉ុន្មានដែលត្រូវរាប់បញ្ចូលនៅក្នុងភស្តុតាង។*
***ប្រភព៖ Gillis & Bateman 2015, p. 26***

នៅតាមប្រទេសជាសមាជិកអាស៊ាន របៀបនៃការលើកកម្ពស់ទំនុកចិត្តក្នុងការសម្រេចចិត្តលើការវាយតម្លៃសមត្ថភាពអាចប្រែប្រួលទៅតាមវិធីសាស្ត្រ និងកម្រិតនៃការអនុវត្តតាមរយៈយុទ្ធសាស្ត្រដូចខាងក្រោម៖

- ការអនុម័តលើបរិធាន ឬឧបករណ៍វាយតម្លៃសមត្ថភាព (ឧទាហរណ៍៖ នាយកដ្ឋានអភិវឌ្ឍន៍ជំនាញនៃប្រទេសម៉ាឡេស៊ី)
- ការធ្វើសវនកម្ម និងការប្រើប្រាស់ការផ្ទៀងផ្ទាត់ពីផ្នែកខាងក្រៅ ( ទីភ្នាក់ងារជាតិផ្តល់គុណវុឌ្ឍិវិជ្ជាជីវៈអាជីពនៃប្រទេសឥណ្ឌូនេស៊ី)
- ការអនុម័តនិងការតាមដានអ្នកវាយតម្លៃសមត្ថភាព (ឧទាហរណ៍៖ អាជ្ញាធរអភិវឌ្ឍន៍ការអប់រំ និងជំនាញបច្ចេកទេស [TESDA] នៃប្រទេសហ្វីលីពីន)
- ការប្រើអ្នកតំណាងឧស្សាហកម្ម ឬសហគ្រាសនៅក្នុងដំណើរការវាយតម្លៃសមត្ថភាព ឬការត្រួតពិនិត្យកែលម្អក្រោយពេលវាយតម្លៃសមត្ថភាព

ក្នុងករណីជាច្រើន ការធានាគុណភាពលើការសម្រេចចិត្តការវាយតម្លៃសមត្ថភាព គឺជាការប្រឈមមួយដ៏ធំបំផុតសម្រាប់ការផ្តល់គុណវុឌ្ឍិផ្អែកលើសមត្ថភាពរបស់ប្រទេសជាសមាជិកអាស៊ាន។

***គំនិតផ្តួចផ្តើមថ្នាក់តំបន់ ឬអន្តរជាតិ***

ចំពោះប្រទេសជាសមាជិកអាស៊ានជាច្រើន សម្ពាធនៃការចល័តកម្លាំងពលកម្មជំនាញ និងនិស្សិត បានបញ្ជាក់ពីតម្រូវការសម្រាប់ការទទួលស្គាល់គុណវុឌ្ឍិជាលក្ខណៈអន្តរជាតិ រួមទាំងការសម្របសម្រួល ដើម្បីឱ្យមានការទទួលស្គាល់ប្រជាពលរដ្ឋរបស់ខ្លួន នៅក្នុងប្រទេសផ្សេងទៀត។

យុទ្ធសាស្ត្រដែលអាចសម្របសម្រួលការទទួលស្គាល់ រួមមាន ៖

- ការអភិវឌ្ឍក្របខណ្ឌគុណវុឌ្ឍិយោងអាស៊ាន (AQRF) ថ្មីៗនេះ បានផ្តោតសំខាន់ទៅលើក្របខណ្ឌគុណវុឌ្ឍិជាតិនៃប្រទេសសមាជិកអាស៊ាន និងអត្ថប្រយោជន៍ដ៏មានសក្តានុពលដែលទទួលបានមកពីការផ្ទៀងផ្ទាត់។ ទោះជាយ៉ាងណាក៏ដោយ ប្រទេសជាសមាជិកអាស៊ានជាច្រើន ទើបតែចាប់ផ្តើមធ្វើការផ្ទៀងផ្ទាត់រវាងក្របខណ្ឌគុណវុឌ្ឍិជាតិរបស់ខ្លួន ជាមួយបណ្តាក្របខណ្ឌគុណវុឌ្ឍិជាតិនៃប្រទេសដទៃ ឬជាមួយក្របខណ្ឌគុណវុឌ្ឍិយោងអាស៊ាន។ [28]
- ប្រទេសជាសមាជិកអាស៊ានបានផ្តោតលើកិច្ចព្រមព្រៀងការទទួលស្គាល់ជំនាញគ្នាទៅវិញទៅមក(MRA) (ឧទាហរណ៍៖ វិជ្ជាជីវៈវិស្វកម្ម គិលានុបដ្ឋាក ស្ថាបត្យកម្ម ការវាស់ស្ទង់ដី វេជ្ជសាស្ត្រ ទន្តសាស្ត្រ គណនេយ្យ និងទេសចរណ៍)
- ប្រទេសនីមួយៗបានឈានដល់កិច្ចព្រមព្រៀងជាមួយប្រទេសផ្សេងៗស្តីពីការផ្ទៀងផ្ទាត់ ឬការចរចារចុះអនុស្សរណៈយោគយល់គ្នា
- នៅក្នុងលក្ខខណ្ឌនៃការវាយតម្លៃគុណវុឌ្ឍិតាមការចង់បានរបស់ប្រទេសជាសមាជិកអាស៊ាន នីមួយៗប្រទេសជាសមាជិកអាស៊ានភាគច្រើន បានផលិតឯកសារនៃដំណើរការវាយតម្លៃគុណវុឌ្ឍិ ក្នុងករណីជាច្រើនទៀតត្រូវបានអនុវត្តបណ្តើរកសាងឯកសារបណ្តើរ។

លើសពីនេះ គំនិតផ្តួចផ្តើមថ្នាក់តំបន់មួយចំនួនមានបំណងសម្របសម្រួលការទទួលស្គាល់ជាបុគ្គល និង ឬជាប្រព័ន្ធ៖

- អនុសញ្ញាតំបន់អាស៊ីប៉ាស៊ីហ្វិក ស្តីពីការទទួលស្គាល់គុណវុឌ្ឍិនៅឧត្តមសិក្សា ២០១១ (UNESCO 2012) មានគោលបំណងដើម្បី "ធានាថា ការសិក្សា សញ្ញាបត្រ កម្រិតសិក្សានៅឧត្តមសិក្សាត្រូវបានទទួលស្គាល់យ៉ាងទូលំទូលាយតាមដែលអាចធ្វើបាន ដោយសារភាពសម្បូរ បែបនៃប្រព័ន្ធអប់រំនៅតំបន់អាស៊ីប៉ាស៊ីហ្វិក និងភាពសម្បូរបែបនៃវប្បធម៌ សង្គម នយោបាយ សាសនា និងសេដ្ឋកិច្ចរបស់ប្រទេសរៀងៗខ្លួន"។[29] អនុសញ្ញាទាក់ទងនឹងឧត្តមសិក្សាត្រូវបានកំណត់ថា "ការអប់រំបណ្តុះបណ្តាលក្រោយមធ្យមសិក្សា ឬការស្រាវជ្រាវណាដែលបានទទួលស្គាល់ដោយអាជ្ញាធរពាក់ព័ន្ធនៃភាគីជាកម្មសិទ្ធរបស់ប្រព័ន្ធអប់រំឧត្តមសិក្សា'។[30] អនុសញ្ញានោះ អាចក្តោបលើការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និងការអប់រំឧត្តមសិក្សា (ឬកម្មវិធីកម្រិតសាកលវិទ្យាល័យ) ទៅតាមវិធីសាស្ត្រនៃការអនុវត្តអនុសញ្ញារបស់ប្រទេសនីមួយៗ។ អនុសញ្ញានោះ ផ្តោតលើការបង្កើតគោលការណ៍មូលដ្ឋានសម្រាប់ការផ្តល់ព័ត៌មាន និងការអនុវត្តអនុសញ្ញា។ មាត្រាទី៣ បានចែងអំពីដំណើរការសម្រាប់ការវាយតម្លៃសមត្ថភាព និងការទទួលស្គាល់គុណវុឌ្ឍិ។ [31]

- កិច្ចសហការដៃគូក្នុងតំបន់ប៉ាស៊ីហ្វិក មានបំណងដើម្បី៖ បង្កើតកិច្ចព្រមព្រៀងថ្នាក់តំបន់មួយ ដែលលើកកម្ពស់ដល់ការធ្វើសមាហរណកម្មសេដ្ឋកិច្ច ដែលនាំមកនូវកំណើនសេដ្ឋកិច្ច និងអត្ថប្រយោជន៍សង្គម បង្កើតឱកាសការងារថ្មីសម្រាប់ពលករជំនាញ និងអាជីវកម្ម រួមចំណែកដល់ការលើកកម្ពស់ស្តង់ដារស់នៅ ផ្តល់អត្ថប្រយោជន៍ដល់អ្នកប្រើប្រាស់ កាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់កំណើនសេដ្ឋកិច្ចប្រកបដោយនិរន្តរភាព។ [32]

---

[28] ពោលចំពោះផ្នែកទី៦ នៃគោលការណ៍ទាំងនេះសម្រាប់ការបង្ហាញលម្អិតបន្ថែម

[29] Http://www.unescobkk.org/education/higher-education/promotion-of-academic-mobility/asia-pacific-regional-convention-on-the-recongnition-of-qualifications-in-higher-education-an-overview/

[30] UNESCO 2012, p. 3

[31] UNESCO 2012

[32] ASEAN countries that are part of this agreement include: Brunei Darussalam, Malaysia, Singapore, and Viet Nam; http://dfat.gov.au/tradel agreements tpp/official documents/Documents/preamble.pdf

# ផ្នែកទី៣៖
# ទិដ្ឋភាពសំខាន់ៗ នៃការធានាគុណភាព

## ផ្នែកទី ៣៖ ទិដ្ឋភាពសំខាន់ៗនៃការធានាគុណភាព

ដំណើរការផ្ដល់គុណវុឌ្ឍិ រួមមានការចេញវិញ្ញាបនបត្រ សញ្ញាបត្រ ឬបញ្ជីលទ្ធផលសិក្សាដែលជាសក្ខីកម្មបញ្ជាក់ថា បេក្ខជនត្រូវបានទទួលការវាយតម្លៃសមត្ថភាព និងផ្ដល់សុពលភាពដោយស្ថាប័ន/អង្គភាពមានសមត្ថកិច្ច ដោយផ្អែកលើស្តង់ដាដែលបានកំណត់ទុកជាមុន។ ការសន្មត់នៅក្នុងដំណើរការនេះ គឺថាបេក្ខជនម្នាក់ដែលបានទទួលការសិក្សាផ្លូវការ ឬការសិក្សាមិនផ្លូវការ ដូចជាតាមរយៈសកម្មភាពធ្វើការងារ ឬ សកម្មភាពផ្ទាល់ខ្លួន។ ចំណុចសំខាន់ចំពោះនិយមន័យនេះ គឺ៖

- ចំណេះដឹង ជំនាញ និងសមត្ថភាពទូលំទូលាយរបស់បុគ្គលម្នាក់ ត្រូវបានវិនិច្ឆ័យដោយផ្អែកលើលក្ខណវិនិច្ឆ័យ ដូចជាលទ្ធផលសិក្សា ឬស្តង់ដាសមត្ថភាព
- គុណវុឌ្ឍិ ដែលចេញដោយស្ថាប័ន/អង្គភាពមានសមត្ថភាព ដែលបានទទួលការទុកចិត្តជាសាធារណៈ និងមានសមត្ថភាព
- គុណវុឌ្ឍិដែលបានចេញត្រូវបានទទួលស្គាល់ និងជឿទុកចិត្តដោយភាគីផ្សេងៗក្នុងទីផ្សារការងារ និង/ឬយកទៅប្រើប្រាស់ដើម្បីបន្តការសិក្សា ឬការបណ្ដុះបណ្ដាលទៅកម្រិតខ្ពស់បន្ថែមទៀតនៅក្នុងវិស័យអប់រំ និងបណ្ដុះបណ្ដាល

មូលដ្ឋាននៃទំនុកចិត្តចំពោះគុណវុឌ្ឍិដែលបានចេញ ត្រូវមានការរៀបចំការធានាគុណភាពដែលត្រូវដាក់ឱ្យអនុវត្តដោយស្ថាប័ន/អង្គភាពមានសមត្ថកិច្ច។

### *គោលការណ៍នៃការធានាគុណភាព*

ប្រព័ន្ធធានាគុណភាពអាចមានគោលការណ៍ជាក់លាក់ ឬទូទៅដែលផ្ដល់ព័ត៌មានអំពីដំណើរការធានាគុណភាពដោយអ្នកបង្កើតគោលនយោបាយ និង/ឬស្ថាប័ន/អង្គភាពមានសមត្ថកិច្ច។

ក្របខណ្ឌធានាគុណភាពនៃការអប់រំបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈនៃកិច្ចប្រជុំកំពូលអាស៊ីបូព៌ា (EAS TVET QAF, 2012) បង្ហាញថាការពិចារណាអំពីគោលការណ៍សម្រាប់ការធានាគុណភាពនៃប្រព័ន្ធអប់រំបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈ គួរឆ្លើយតបនឹងគោលការណ៍៖

- *តម្លាភាព និងគណនេយ្យភាព៖*

តម្លាភាព និងគណនេយ្យភាព គឺជាគោលការណ៍សំខាន់ពីរនៃអភិបាលកិច្ចល្អ។ គណនេយ្យភាព សំដៅទៅលើលក្ខខណ្ឌតម្រូវផ្អែកច្បាប់ និងរបាយការណ៍ ចំណែកឯតម្លាភាពពាក់ព័ន្ធនឹងរបាយការណ៍ ដំណើរការ និងការប្រតិបត្តិទាន់ពេលវេលា អាចជឿជាក់បាន ច្បាស់លាស់ និងឆ្លើយតបជាសាធារណៈ។

- *ភាពអាចប្រៀបធៀបបាន៖*

ភាពអាចប្រៀបធៀបបាន សំដៅដល់ការទទួលស្គាល់ថា វិធានការ និងប្រព័ន្ធធានាគុណភាពផ្ទៃក្នុងនៅតាមប្រទេសនីមួយៗអាចមានភាពខុសៗគ្នា។ តែទោះបីជាយ៉ាងណា វិធានការនេះចាំបាច់ត្រូវផ្អែកលើស្តង់ដា និងការរំពឹងទុកដែលអាចធ្វើការប្រៀបធៀបបាន។

- *ភាពបត់បែន និងភាពឆ្លើយតប៖*

ភាពបត់បែន និងការឆ្លើយតប សំដៅចំពោះវិធានការធានាគុណភាពដែលអាចបត់បែនបានគ្រប់ជ្រុងជ្រោយ ដើម្បីលើកកម្ពស់ការច្នៃប្រឌិត និងភាពបត់បែននៃការផ្ដល់ជូននូវការធានាគុណភាព និងមិនត្រូវបង្កើតកំហុសដោយផ្អែកលើគំរូអនុលោមតាមច្បាប់ ឬការពិន័យឡើយ។

- *តុល្យភាព និងសមាហរណកម្ម៖*

តុល្យភាព និងសមាហរណកម្ម សំដៅចំពោះស្តង់ដាដែលបានកំណត់សម្រាប់ប្រព័ន្ធធានាគុណភាពតុល្យភាព និងការការពារផលប្រយោជន៍របស់ភាគីពាក់ព័ន្ធ ដោយលើកទឹកចិត្តឱ្យមានការធ្វើឱ្យប្រសើរឡើង និងការច្នៃប្រឌិតជាបន្តបន្ទាប់។

- *ភាពជាប់លាប់ និងសង្គតិភាព៖*

ភាពជាប់លាប់ និងសង្គតិភាព សំដៅចំពោះការផ្ដល់ភាពជាប់លាប់ក្នុងការថែរក្សាទំនុកចិត្តរបស់ភាគីពាក់ព័ន្ធ និងការធ្វើឱ្យមានសង្គតិភាពក្នុងការអនុវត្ត។

- *ស្តង់ដាអប្បបរមា៖*

សំដៅចំពោះប្រព័ន្ធអប់រំបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈ ដោយប្រើប្រាស់កម្រងស្តង់ដាសម្រាប់ទាំងធាតុចូល និងលទ្ធផល។

- *ការធានា និងការធ្វើឱ្យគុណភាពប្រសើរឡើង៖*

ការធានា និងការធ្វើឱ្យគុណភាពប្រសើរឡើង សំដៅចំពោះប្រព័ន្ធគុណភាពដែលផ្តល់នូវស្តង់ដាធានាគុណភាព និងលើកកម្ពស់ការធ្វើឱ្យប្រសើរឡើង នៅក្នុងដំណើរការ និងលទ្ធផលបណ្តុះបណ្តាល។

- *ឯករាជ្យភាព៖*

អភិបាលកិច្ចល្អ ក៏រួមបញ្ចូលនូវឯករាជ្យភាពនៃការសម្រេចចិត្ត និងសកម្មភាពផងដែរ ហើយជៀសវាងទំនាស់ផលប្រយោជន៍។

- *ការគាំទ្រនៃការធានាគុណភាព៖*

ការគាំទ្រនៃការធានាគុណភាព សំដៅដល់សកម្មភាពធានាគុណភាព និងការវិនិច្ឆ័យយ៉ាងជិតស្និទ្ធចំពោះដំណើរការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ។

ទោះជាយ៉ាងណា ប្រការនេះជាការទទួលខុសត្រូវរបស់ប្រទេសជាសមាជិកអាស៊ាននីមួយៗ ដើម្បីកំណត់គោលការណ៍ធានាគុណភាពសំខាន់ៗបន្ថែមទៀត ដែលគោលការណ៍នោះនឹងធានាគុណភាព ប្រព័ន្ធផ្តល់គុណវុឌ្ឍិសមត្ថភាពរបស់ប្រទេសខ្លួន។ ការបញ្ជាក់លម្អិតពីគោលការណ៍ធានាគុណភាព នៅក្នុងសេចក្តីថ្លែងចក្ខុវិស័យ និងបេសកកម្មស្ថាប័ន/អង្គភាពមានសមត្ថកិច្ច ការធ្វើសេចក្តីថ្លែងស្តីពីគោលនយោបាយ និងការសម្រេចជាសាធារណៈ ហើយនិងការធ្វើឱ្យប្រាកដពីការចូលរួមរបស់ភាគីពាក់ព័ន្ធសំខាន់ៗក្នុងការតម្រង់ទិសគោលនយោបាយនឹងជួយដល់ការអនុម័ត និងការប្រាស្រ័យទាក់ទងសម្រាប់គោលការណ៍ធានាគុណភាព (Ws) ទាំងនេះ។

## ធាតុផ្សំនៃការធានាគុណភាព

ប្រទេសនានាមានបទពិសោធន៍ និងវិធីសាស្ត្រផ្សេងៗគ្នាលើការធានាគុណភាព។ ទោះជាយ៉ាងណាក៏ដោយ ក្របខណ្ឌធានាគុណភាពការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ នៃកិច្ចប្រជុំកំពូលអាស៊ីបូព៌ា ឆ្នាំ២០១២ កត់សម្គាល់ថា ជាទូទៅធាតុផ្សំនៃការធានាគុណភាពអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈរួមមាន៖

១. ផលិតផលនៃការអប់រំបណ្តុះបណ្តាល បច្ចេកទេសនិងវិជ្ជាជីវៈ (អ.ប.វ) តាមរយៈការអនុម័តស្តង់ដា (ដូចជាស្តង់ដាអប់រំ និង/ឬស្តង់ដាសមត្ថភាព ព្រមទាំងស្តង់ដាសម្រាប់ការផ្តល់គុណវុឌ្ឍ)
២. អង្គភាពផ្តល់ការបណ្តុះបណ្តាល និង/ឬ ការវាយតម្លៃសមត្ថភាពតាមរយៈដំណើរការអនុម័តទទួលស្គាល់គុណភាព[33] គឺផ្អែកលើហេដ្ឋារចនាសម្ព័ន្ធ អង្គភាពផ្តល់ការបណ្តុះបណ្តាល និង/ឬការវាយតម្លៃសមត្ថភាពសុចរិតភាពផ្នែកហិរញ្ញវត្ថុ គុណវុឌ្ឍ និងបទពិសោធន៍បុគ្គលិក ប្រព័ន្ធគ្រប់គ្រង ប្រព័ន្ធដំណើរការបណ្តុះបណ្តាល និងការវាយតម្លៃសមត្ថភាព និងប្រព័ន្ធគាំទ្រសិស្ស
៣. ដំណើរការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ តាមរយៈការធ្វើសវនកម្មលើដំណើរការទិន្នផលរបស់អ្នកផ្តល់សេវា រួមទាំងលទ្ធផលសិក្សា និងការទទួលបានការងារធ្វើរបស់និស្សិត ព្រមទាំងកម្រិតពេញចិត្តរបស់និស្សិត និងអ្នកប្រើប្រាស់
៤. ទិន្នផលអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ តាមរយៈការគ្រប់គ្រង ការត្រួតពិនិត្យ ឬការតាមដានលើនីតិវិធី និងលទ្ធផល នៃការវាយតម្លៃសមត្ថភាព និងបញ្ចប់ការសិក្សារបស់និស្សិត
៥. អ្នកផ្តល់ការបណ្តុះបណ្តាល ឬភាពទូលាយនៃប្រព័ន្ធវាយតម្លៃគុណភាពអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ រួមទាំងការវាយតម្លៃដោយភ្នាក់ងារពីខាងក្រៅ
៦. ការផ្តល់ព័ត៌មានជាសាធារណៈពីការប្រតិបត្តិរបស់អ្នកផ្តល់សេវាមានដូចជា កម្មវិធីបណ្តុះបណ្តាល និងការបញ្ចប់ផ្នែកសមត្ថភាព ការពេញចិត្តរបស់និស្សិត និងនិយោជក។

គ្រប់ទិដ្ឋភាពទាំងអស់នេះជានិច្ចកាលមិនសុទ្ធតែស្ថិតក្រោមការទទួលខុសត្រូវដោយស្ថាប័ន/អង្គភាពមានសមត្ថកិច្ចតែមួយទេ ប៉ុន្តែទោះជាយ៉ាងណា មុខងារភាគច្រើនដែលបានរៀបរាប់ខាងលើនឹងត្រូវទទួលខុសត្រូវដោយស្ថាប័ន/អង្គភាពមានសមត្ថកិច្ចតាមមុខងារនីមួយៗរៀងខ្លួន។ ស្ថាប័ន/អង្គភាពមានសមត្ថកិច្ចសម្រាប់ធាតុផ្សំផ្សេងៗ គួរបង្ហាញពីអ្វីដែលមានដូចខាងក្រោម៖

- ការរៀបចំអភិបាលកិច្ចរឹងមាំ អាចត្រូវបានកំណត់ជា "សំណុំនៃការទទួលខុសត្រូវ និងការអនុវត្តនយោបាយ និងនីតិវិធីអនុវត្តដោយនាយកប្រតិបត្តិរបស់ទីភ្នាក់ងារមួយ ការផ្តល់ទិសដៅយុទ្ធសាស្ត្រធានាសម្រេចបានគោលដៅដែលបានកំណត់ គ្រប់គ្រងហានិភ័យ និងប្រើប្រាស់ធនធាន ដោយមានទំនួលខុសត្រូវ និងមានគណនេយ្យភាព"។[34]

---

[33] តាមរយៈតំបន់មួយចំនួន ដំណើរការនៃការយល់ព្រមលើភាពត្រឹមត្រូវ សមត្ថភាព និងដំណើរការរបស់អង្គភាពផ្តល់ការបណ្តុះបណ្តាល គឺសំដៅលើ “ការចុះបញ្ជិកា” ឬ “ការទទួលស្គាល់គុណភាព”។ ដំណើរការអនុម័តនេះ ក៏សន្មត់ផងដែរនូវទស្សនៈនៃការពិនិត្យឡើងវិញ និងការអនុម័តជាបន្តបន្ទាប់។

[34] រដ្ឋាភិបាលនៃប្រទេសអូស្ត្រាលី ឆ្នាំ២០០៧, p. 1.

- ប្រព័ន្ធគ្រប់គ្រងគុណភាព ដែលអនុវត្តចំពោះគ្រប់មុខងាររបស់ធាតុផ្សំនៃការធានាគុណភាព ឧទាហរណ៍ការអនុម័តគុណវុឌ្ឍិ ឬកម្រងសមត្ថភាព សម្រាប់ផ្ដល់គុណវុឌ្ឍិសមត្ថភាព ការអនុម័ត អង្គភាពផ្ដល់សេវាវាយតម្លៃសមត្ថភាព។
- មធ្យោបាយសម្រាប់ដោះស្រាយពាក្យបណ្ដឹងរបស់ភាគីពាក់ព័ន្ធ។

ស្ថាប័ន/អង្គភាពមានសមត្ថកិច្ចនៅក្នុងប្រទេសជាសមាជិកអាស៊ាន ចាំបាច់ត្រូវធ្វើការពិចារណាពីរបៀបដែលប្រព័ន្ធធានាគុណភាពរបស់ខ្លួនបង្ហាញពីធាតុផ្សំទាំង៦ដូចបានរៀបរាប់ខាងលើ ឬក៏របៀបដាក់បញ្ចូលធាតុផ្សំទាំង៦នេះទៅក្នុងប្រព័ន្ធធានាគុណភាពដែលត្រូវបានបង្កើតថ្មី ឬត្រូវបានរៀបចំឡើងវិញសម្រាប់ការអប់រំបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈ ឬប្រព័ន្ធផ្ដល់គុណវុឌ្ឍិសមត្ថភាព។

**១. ការអភិវឌ្ឍផលិតផល អ.ប.វ**

នៅក្នុងប្រព័ន្ធ អ.ប.វ មានជម្រើសជាច្រើនសម្រាប់ការបង្កើតស្តង់ដាសមិទ្ធផល អ.ប.វ ដែលរួមមាន៖

- ស្តង់ដាសមត្ថភាព គឺជាសេចក្ដីថ្លែងពីចំណេះដឹង ជំនាញ និង/ឬសមត្ថភាពដែលផ្សារភ្ជាប់នឹងមុខរបរណាមួយ
- ស្តង់ដាមុខរបរ គឺជាសេចក្ដីថ្លែងពីសកម្មភាពការងារ និងកិច្ចការទាក់ទងនឹងមុខរបរជាក់លាក់ និងការអនុវត្តសកម្មភាពការងារ និងកិច្ចការទាំងនោះ
- ស្តង់ដាវាយតម្លៃសមត្ថភាព គឺជាសេចក្ដីថ្លែងពីលទ្ធផលសិក្សាដែលត្រូវវាយតម្លៃ និងវិធីសាស្ត្រវាយតម្លៃសមត្ថភាពដែលត្រូវប្រើ
- ស្តង់ដាផ្ដល់គុណវុឌ្ឍិ គឺជាវិធានច្បាប់សម្រាប់ការទទួលបានគុណវុឌ្ឍិនិងសិទ្ធិក្នុងការប្រគល់។
- ស្តង់ដាអប់រំ គឺជាសេចក្ដីថ្លែងពីគោលដៅសិក្សា មាតិកាសិក្សាដែលបានកំណត់ លក្ខខណ្ឌតម្រូវក្នុងការសិក្សា និងធនធានសិក្សាដែលត្រូវមាន

ប្រព័ន្ធអប់រំបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈ របស់ប្រទេសមួយអាចប្រើស្តង់ដាទាំងនេះបញ្ចូលគ្នា ឬផ្ដោតទៅលើតែស្តង់ដាមួយ ឬពីរ ឧទាហរណ៍ ៖ ស្តង់ដាសមត្ថភាព ឬស្តង់ដាមុខរបរ។ អ្នកអភិវឌ្ឍស្តង់ដាទាំងនេះ នឹងត្រូវទទួលខុសត្រូវលើការបង្កើតស្តង់ដាទោល ឬស្តង់ដាចម្រុះ និងរួមបញ្ចូលនូវ៖

- អង្គភាពផ្ដល់សេវាបណ្ដុះបណ្ដាលសាធារណៈ
- ភ្នាក់ងារទោល ឬភ្នាក់ងារចម្រុះ
- សហគ្រាស គ្រឹះស្ថាន ឬភ្នាក់ងារចម្រុះ

ចំពោះស្ថាប័ន/អង្គភាពមានសមត្ថកិច្ច ដែលគោរពតាមស្តង់ដាអន្តរជាតិស្ដីពីភាពអនុលោមនៃការវាយតម្លៃសមត្ថភាព *(ISO/IEC 17024:2012 Conformity Assessment)* ជាលក្ខខណ្ឌតម្រូវទូទៅសម្រាប់ស្ថាប័ន/អង្គភាព ឬបុគ្គលអនុវត្តការផ្ដល់គុណវុឌ្ឍិ ហើយស្តង់ដាការផ្ដល់គុណវុឌ្ឍិត្រូវបានកំណត់ថាជា "កម្រងសមត្ថភាពនៃការផ្ដល់គុណវុឌ្ឍិ"។ នៅក្នុងស្តង់ដា ISO នេះ កម្រងសមត្ថភាពសម្រាប់ការផ្ដល់គុណវុឌ្ឍិ រួមបញ្ចូលនូវវិសាលភាពនៃការផ្ដល់គុណវុឌ្ឍិ ការពិពណ៌នាមុខរបរ ឬកិច្ចការសមត្ថភាពដែលត្រូវមាន និងលក្ខខណ្ឌតម្រូវក្នុងការទទួលបានគុណវុឌ្ឍិ។ លើសពីនេះ ស្តង់ដា ISO តម្រូវឱ្យមានការអភិវឌ្ឍកម្រងសមត្ថភាពសម្រាប់ការផ្ដល់គុណវុឌ្ឍិ ដើម្បីបញ្ចូលនូវជំនាញសមស្រប លក្ខខណ្ឌតម្រូវក្នុងការទទួលបានគុណវុឌ្ឍិ ការវិភាគមុខរបរ គោលការណ៍ណែនាំក្នុងការវាយតម្លៃ និងមាតិកាប្រឡង ព្រមទាំងលក្ខខណ្ឌតម្រូវក្នុងការផ្ដល់គុណវុឌ្ឍិឡើងវិញ។ លក្ខខណ្ឌតម្រូវចុងក្រោយ គឺជាភាពខុសគ្នារវាងប្រព័ន្ធគុណវុឌ្ឍិ និងប្រព័ន្ធផ្ដល់គុណវុឌ្ឍិសមត្ថភាពដែលអនុវត្តតាមស្តង់ដានៃអង្គការស្តង់ដាអន្តរជាតិ/គណៈកម្មការបច្ចេកវិទ្យាអេឡិចត្រូនិចអន្តរជាតិ ស្ដីពីភាពអនុលោមនៃការវាយតម្លៃសមត្ថភាព (ISO/IEC 17024:2012 Conformity Assessment) មានជាអាទិ៍ *លក្ខខណ្ឌតម្រូវទូទៅសម្រាប់ស្ថាប័ន/អង្គភាព ឬបុគ្គលអនុវត្តការផ្ដល់គុណវុឌ្ឍិ*។ លក្ខខណ្ឌតម្រូវសម្រាប់ការផ្ដល់គុណវុឌ្ឍិឡើងវិញត្រូវប្រកាន់ខ្ជាប់តាមស្តង់ដាអន្តរជាតិ ISO ដែលលក្ខខណ្ឌតម្រូវនេះ ជារឿយៗ គឺជាទំនួលខុសត្រូវរបស់ស្ថាប័ន/អង្គភាពផ្ដល់អាជ្ញាប័ណ្ណ និង/ឬសមាគម ឬស្ថាប័ន/អង្គភាពវិជ្ជាជីវៈអាជីពជាជាងប្រព័ន្ធផ្ដល់គុណវុឌ្ឍិ។ ចំពោះស្ថាប័ន/អង្គភាពមានសមត្ថកិច្ចទាំងនោះដែលគោរពតាមស្តង់ដាអន្តរជាតិស្ដីពីភាពអនុលោមនៃការវាយតម្លៃសមត្ថភាព *(ISO/IEC 17024:2012 Conformity assessment) លក្ខខណ្ឌតម្រូវទូទៅសម្រាប់អង្គភាព ឬបុគ្គលអនុវត្តការផ្ដល់គុណវុឌ្ឍិ* ការពិចារណាលើភាពចាំបាច់ធ្វើអោយមានតុល្យភាពរវាងការវាយតម្លៃសមត្ថភាព និងអ្នកទទួលបន្ទុកក្នុងការវាយតម្លៃសមត្ថភាព និងលទ្ធផលដែលទទួលបានសម្រាប់ក្រុមការងារជាតិ។

ចំណុចសំខាន់ៗដែលត្រូវផ្ដោតលើការអភិវឌ្ឍស្តង់ដា គឺធានាថាស្តង់ដាដែលបានអភិវឌ្ឍនោះ មានការឆ្លើយតបទៅនឹងឧស្សាហកម្ម និងបានធ្វើបច្ចុប្បន្នភាព។ ទោះបីស្តង់ដាដែលបានប្រើនៅក្នុងប្រព័ន្ធអប់រំបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈ យ៉ាងណាក៏ដោយ អ្នកអភិវឌ្ឍន៍ត្រូវមានការចូលរួមពីអ្នកតំណាងឧស្សាហកម្មវិស័យឯកជនក្នុងការអភិវឌ្ឍស្តង់ដា ហើយចងក្រងឯកសារស្តង់ដាទាំងនេះនៅក្នុងទម្រង់មួយដែលមានសង្គតិភាព និងត្រូវរួមបញ្ចូលជំហានការអនុម័តស្តង់ដានៅក្នុងដំណើរការអភិវឌ្ឍ។

## ២. ការអនុម័តស្ថាប័ន/អង្គភាពបណ្ដុះបណ្ដាល និង/ឬស្ថាប័ន/អង្គភាពវាយតម្លៃសមត្ថភាព

ការអនុម័តទទួលស្គាល់ស្ថាប័ន/អង្គភាពបណ្ដុះបណ្ដាល និង/ឬស្ថាប័ន/អង្គភាពវាយតម្លៃសមត្ថភាព គឺជាតួនាទីមួយរបស់ស្ថាប័ន/អង្គភាពមានសមត្ថកិច្ច។ តែទោះជាយ៉ាងណា ដំណើរការអនុម័តអាចជាការស្ម័គ្រចិត្ត ឬជាកាតព្វកិច្ច លើកលែងចំពោះ៖

- អ្នកផ្ដល់សេវាផ្នែកឯកជន ជាពិសេសប្រសិនបើការអនុម័តលើអ្នកផ្ដល់សេវាសាធារណៈត្រូវបានតម្រូវ
- អ្នកផ្ដល់សេវាវាយតម្លៃសមត្ថភាព ត្រូវបានផ្ដល់សិទ្ធិជាអ្នកផ្ដល់សេវាបណ្ដុះបណ្ដាលផងដែរ។

លក្ខខណ្ឌតម្រូវក្នុងការអនុម័តអាចត្រូវចងក្រងជាគោលការណ៍ណែនាំ បទប្បញ្ញត្តិ បទបញ្ជា ឬស្ដង់ដាគុណភាព។ ដំណើរការអនុម័តត្រូវភ្ជាប់មកជាមួយនូវភស្តុតាងសំខាន់ៗ និង/ឬរបាយការណ៍សវនកម្ម ឬរបាយការណ៍របស់ក្រុមត្រួតពិនិត្យ។

លើសពីនេះទៀត មានករណីមួយចំនួននៅក្នុងប្រព័ន្ធគុណវុឌ្ឍ ឬប្រព័ន្ធផ្ដល់គុណវុឌ្ឍសមត្ថភាពដែលសេវាវាយតម្លៃសមត្ថភាព ត្រូវបានអនុម័តបន្ថែមទៀតដោយភាគីទី៣ ឧទាហរណ៍ នីតិបុគ្គល ឬរូបវន្តបុគ្គល។ ការអនុវត្តបែបនេះ ត្រូវបានគេហៅឈ្មោះផ្សេងៗគ្នាថា សេវាឧបត្ថម្ភគាំទ្រខាងក្រៅ (Auspice) សេវាទិញសិទ្ធិក្នុងអនុវត្ត (Franchising) និងសេវាពីស្ថាប័ន/អង្គភាពខាងក្រៅ (Outsourcing)។[35]

ចំពោះប្រទេសខ្លះដែលអនុវត្តនូវការរៀបចំទាំងនេះ លក្ខខណ្ឌតម្រូវអាចត្រូវបានកំណត់នៅក្នុងបទប្បញ្ញត្តិ គោលការណែនាំ ឬស្ដង់ដាគុណភាព។ ឧទាហរណ៍ នៅប្រទេសអូស្ត្រាលី ចាប់តាំងពីការចាប់ផ្ដើមមកលក្ខខណ្ឌតម្រូវនេះ ត្រូវបានសរសេរនៅក្នុងស្ដង់ដាគុណភាពអប់រំបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈ ហើយបច្ចុប្បន្នបានចងក្រងជាឯកសារបទប្បញ្ញត្តិច្បាប់។

ចំពោះស្ថាប័ន/អង្គភាពមានសមត្ថកិច្ចទាំងនោះដែលប្រកាន់យកស្ដង់ដាអន្តរជាតិស្ដីពីភាពអនុលោមនៃការវាយតម្លៃសមត្ថភាព *(ISO/IEC 17024: 2012)* - លក្ខខណ្ឌតម្រូវទូទៅសម្រាប់ស្ថាប័ន/អង្គភាព ឬបុគ្គលអនុវត្តការផ្ដល់គុណវុឌ្ឍ ដំណើរការនៃការប្រើសេវាខាងក្រៅ (Outsourcing) រួមបញ្ចូលនូវកិច្ចព្រមព្រៀងតាមផ្លូវច្បាប់ដែលអាចអនុវត្តបាន និងទីភ្នាក់ងារផ្ដល់គុណវុឌ្ឍ គឺដើម្បី៖

- ទទួលខុសត្រូវលើការប្រើគ្រប់សេវាខាងក្រៅ
- ធានាថា ស្ថាប័ន/អង្គភាពដែលប្រើសេវាខាងក្រៅត្រូវមានសមត្ថភាព និងអនុលោមតាមលក្ខខណ្ឌតម្រូវដែលបានកំណត់
- ត្រួតពិនិត្យ និងវាយតម្លៃការប្រតិបត្តិរបស់ស្ថាប័ន/អង្គភាពដែលបានប្រើសេវាខាងក្រៅទាំងនោះ
- រក្សាកំណត់ត្រាដើម្បីបង្ហាញថាស្ថាប័ន/អង្គភាពដែលបានប្រើប្រាស់សេវាខាងក្រៅឆ្លើយតបទៅនឹងគ្រប់លក្ខខណ្ឌតម្រូវ
- រក្សាបញ្ជីស្ថាប័ន/អង្គភាពប្រើសេវាខាងក្រៅ

## ៣. ការត្រួតពិនិត្យដំណើរការ និងការផ្ដល់ការអប់រំបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈ

ការត្រួតពិនិត្យដំណើរការ និងការផ្ដល់ការអប់រំបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈ អាចរួមបញ្ចូលនូវការវាយតម្លៃលើទិន្នន័យសូចនាករគុណភាព (ដូចជា អត្រាយេនឌ័រ អត្រាគ្រូ និងសិស្ស លទ្ធផលផ្សេងៗតាមរយៈការត្រួតពិនិត្យ និងវាយតម្លៃ សមត្ថភាពនិស្សិត ព្រមទាំងវឌ្ឍនភាពនៃការផ្ដល់គុណវុឌ្ឍ និងអត្រានៃការបញ្ចប់ការសិក្សា លទ្ធផលការរកការងារបានធ្វើ ការពេញចិត្តរបស់អ្នកប្រើប្រាស់ និងការបន្តការសិក្សាបន្ថែម) និងវិធីសាស្ត្រសវនកម្ម ឬការត្រួតពិនិត្យឡើងវិញទៅលើប្រព័ន្ធគ្រប់គ្រងអ្នកផ្ដល់សេវា និងការអនុវត្ត។ ការត្រួតពិនិត្យសវនកម្មអាចត្រូវបានរៀបចំឡើងដោយឈរលើមូលដ្ឋានជាវដ្តទៀងទាត់ អាស្រ័យទៅតាមប្រភេទនៃអ្នកផ្ដល់សេវាផ្សេងៗគ្នា។ សវនកម្មអាចត្រូវបានធ្វើឡើងតាមតារាងកាលវិភាគផ្សេងៗ ឧទាហរណ៍ ការត្រួតពិនិត្យឡើងវិញតែមួយដង ឬត្រូវបានអនុវត្តក្នុងរយៈពេលខ្លីៗណាមួយ។

ស្ថាប័ន/អង្គភាពមានសមត្ថកិច្ច ត្រូវមានគោលការណ៍ណែនាំច្បាស់លាស់ទៅលើ៖

- ទិន្នន័យត្រូវបានប្រមូល ដែលរួមមានស្ដង់ដាទិន្នន័យ
- លក្ខណៈវិនិច្ឆ័យ ឬស្ដង់ដាគុណភាពសម្រាប់ស្ថាប័ន/អង្គភាពផ្ដល់សេវាវាយតម្លៃសមត្ថភាព (អាចរួមទាំងការផ្ដល់សេវាបណ្ដុះបណ្ដាល) ដែលអាចធ្វើសវនកម្មបាន
- ការរៀបចំត្រួតពិនិត្យតាមដាន និងបញ្ជីសកម្មភាពដែលត្រូវវាយតម្លៃស្ថាប័ន/អង្គភាពផ្ដល់សេវាមិនត្រូវតាមលក្ខខណ្ឌតម្រូវ ឧទាហរណ៍៖ ការដាក់ទណ្ឌកម្ម និងការបិទដំណើរការផ្ដល់សេវា

---

[35] ISO/IEC 17024:2012

### ៤. លទ្ធផលនៃការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ តាមរយៈនីតិវិធីនៃការត្រួតពិនិត្យ ការគ្រប់គ្រង ឬការតាមដាននៅលើការវាយតម្លៃសមត្ថភាព និងការបញ្ចប់ការសិក្សា និងលទ្ធផល

ការធានាគុណភាពក្នុងការវាយតម្លៃសមត្ថភាព អាចអនុវត្តតាមវិធីសាស្រ្តផ្សេងៗគ្នា ហើយប្រទេសជាសមាជិកអាស៊ាននីមួយៗ អាចប្រើវិធីសាស្រ្តទាំងនេះ តាមមធ្យោបាយដូចខាងក្រោម៖

- ការត្រួតពិនិត្យមើលការវាយតម្លៃសមត្ថភាព៖
  - បង្កើតឧបករណ៍វាយតម្លៃសមត្ថភាពនៅថ្នាក់កណ្តាល និងចាត់ចែងគ្រប់គ្រងក្នុងការវាយតម្លៃសមត្ថភាពនៅថ្នាក់កណ្តាល
  - បង្កើតឧបករណ៍វាយតម្លៃសមត្ថភាពនៅថ្នាក់កណ្តាល និងចាត់ចែងគ្រប់គ្រងដោយអង្គភាពបណ្តុះបណ្តាល/វាយតម្លៃសមត្ថភាព ដែលបានចុះបញ្ជិកាទទួលស្គាល់គុណភាព ប៉ុន្តែមានការវិនិច្ឆ័យលើលទ្ធផលវាយតម្លៃពីផ្នែកខាងក្រៅ
  - ការរួមបញ្ចូលគ្នានៃការអភិវឌ្ឍនិងគ្រប់គ្រងក្នុងការវាយតម្លៃសមត្ថភាពរបស់អង្គភាពបណ្តុះបណ្តាល/វាយតម្លៃសមត្ថភាពដែលបានចុះបញ្ជិកាទទួលស្គាល់គុណភាព និងស្ថាប័ន/អង្គភាពវាយតម្លៃខាងក្រៅ

- ការត្រួតពិនិត្យលើការសម្រេចចិត្តក្នុងការវាយតម្លៃសមត្ថភាព៖
  - ការប្រមូលភស្តុតាងការវាយតម្លៃសមត្ថភាព និងការសម្រេចចិត្តលើការវាយតម្លៃសមត្ថភាពដោយថ្នាក់កណ្តាល
  - ស្វ័យត្រួតពិនិត្យ និងរបាយការណ៍ដោយស្ថាប័ន/អង្គភាពផ្តល់សេវាវាយតម្លៃសមត្ថភាព

- ការគ្រប់គ្រងអ្នកវាយតម្លៃសមត្ថភាព៖
  - លក្ខណវិនិច្ឆ័យសមស្រប និងការអភិវឌ្ឍវិជ្ជាជីវៈអាជីពសម្រាប់អ្នកវាយតម្លៃសមត្ថភាព
  - ការចុះបញ្ជិកាទទួលស្គាល់អ្នកវាយតម្លៃសមត្ថភាព
  - ការផ្តល់គុណវុឌ្ឍអ្នកវាយតម្លៃសមត្ថភាពឡើងវិញ

ចុងបញ្ចប់ ពិធីសារសម្រាប់ការផ្តល់វិញ្ញាបនបត្រ ឬគុណវុឌ្ឍអាចប្រែប្រួលទៅតាម៖

- ស្ថាប័ន/អង្គភាពមានសមត្ថកិច្ចផ្តល់/បញ្ជាក់គុណវុឌ្ឍ ជាអ្នកចេញវិញ្ញាបនបត្រ ឬគុណវុឌ្ឍ
- ស្ថាប័ន/អង្គភាពមានសមត្ថកិច្ចផ្តល់/បញ្ជាក់គុណវុឌ្ឍ អនុម័តអោយអ្នកផ្តល់សេវាមានសិទ្ធិជាតំណាងចេញវិញ្ញាបនបត្រ ឬគុណវុឌ្ឍ ដោយមានកំណត់ត្រាលទ្ធផលនិស្សិតដែលរក្សាទុកនៅស្ថាប័ន/អង្គភាពផ្តល់សេវា ឬនៅស្ថាប័ន/អង្គភាពមានសមត្ថកិច្ចផ្តល់/បញ្ជាក់គុណវុឌ្ឍ
- ស្ថាប័ន/អង្គភាពមានសមត្ថកិច្ចផ្តល់/បញ្ជាក់គុណវុឌ្ឍ អនុម័តឱ្យស្ថាប័ន/អង្គភាពផ្តល់សេវាចេញវិញ្ញាបនបត្រ ឬគុណវុឌ្ឍ។

ចំពោះស្ថាប័ន/អង្គភាពទាំងឡាយណាដែលអនុវត្តស្តង់ដាអន្តរជាតិ ស្តីពីភាពអនុលោមនៃការវាយតម្លៃសមត្ថភាព (ISO/IEC 17024:2012) – លក្ខខណ្ឌតម្រូវទូទៅសម្រាប់ស្ថាប័ន/អង្គភាព ឬបុគ្គលអនុវត្តការផ្តល់គុណវុឌ្ឍស្តង់ដាទាមទារឱ្យ៖

- ចងក្រងឯកសារវិធីសាស្រ្ត និងយន្តការវាយតម្លៃសមត្ថភាព បំពេញតម្រូវការពិសេសរបស់បេក្ខជនធានាថា ការវាយតម្លៃសមត្ថភាព ប្រកាន់ខ្ជាប់នូវគោលការណ៍វាយតម្លៃសមត្ថភាពមានសុពលភាព និងភាពជឿជាក់បាន
- បង្កើតលក្ខខណ្ឌតម្រូវសម្រាប់ការអនុម័តអ្នកវាយតម្លៃសមត្ថភាពនិងសម្រាប់ការត្រួតពិនិត្យតាមដានដំណើរការប្រតិបត្តិរបស់អ្នកវាយតម្លៃសមត្ថភាព
- ទទួលខុសត្រូវចំពោះការចេញគុណវុឌ្ឍ និងធានាថាភស្តុតាងមានគ្រប់គ្រាន់ពាក់ព័ន្ធក្នុងការផ្តល់គុណវុឌ្ឍ។[36]

ស្ថាប័ន/អង្គភាពមានសមត្ថកិច្ចផ្តល់គុណវុឌ្ឍ តម្រូវឱ្យមានឯកសារពិធីសារច្បាស់លាស់សម្រាប់ដំណើរការ ដែលពាក់ព័ន្ធនឹងការរៀបចំត្រួតពិនិត្យ ការវាយតម្លៃសមត្ថភាព និងការចេញគុណវុឌ្ឍ។

### ៥. ការវាយតម្លៃគុណភាពអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ

នៅក្នុងប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ មានតម្រូវការ និងការទាក់ទងគ្នាទៅវិញទៅមកប្រកបដោយការប្រកួតប្រជែង ហើយភ្នាក់ងារដែលទទួលបន្ទុកនីមួយៗគួរត្រូវត្រួតពិនិត្យឡើងវិញ និងឆ្លុះបញ្ចាំងពីគោលដៅទៅលើប្រព័ន្ធនោះ ដើម្បីកំណត់បញ្ហា និងរាយការណ៍បញ្ហាដែលខ្វះចន្លោះ។ ប្រទេសខ្លះ បានបង្កើតភ្នាក់ងារដើម្បីផ្តល់យោបល់ដល់រដ្ឋមន្ត្រីជាន់ខ្ពស់ពីបញ្ហាថ្នាក់ជាតិ (ឬកង្វល់) ដែលពាក់ព័ន្ធនឹងប្រព័ន្ធបណ្តុះបណ្តាលរបស់ប្រទេសនោះ។

ការវាយតម្លៃទាមទារនូវលទ្ធភាពក្នុងការស្នើសុំ ឬទទួលទិន្នន័យសូចនាករគុណភាព ផ្តល់របាយការណ៍ និងព័ត៌មានដល់ក្រសួងពាក់ព័ន្ធ ព្រមទាំងទីភ្នាក់ងារផ្សេងៗទៀត។ ការវាយតម្លៃគុណភាពលើប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ផ្តល់ដល់ភាគីពាក់ព័ន្ធនូវព័ត៌មានថាតើគោល

[36] This is known as traceability.

នយោបាយ អ.ប.វ ឆ្លើយតបទៅនឹងគោលដៅថ្នាក់ជាតិ ឬតាមវិស័យ ឬតាមតម្រូវការដៃរបួទ។ ការវាយតម្លៃអាចត្រូវបានអនុវត្តដោយភ្នាក់ងារពីខាងក្រៅ។ អង្គភាពមានសមត្ថកិច្ច ត្រូវធ្វើរបាយការណ៍សង្ខេបបញ្ជាក់ពីការរកឃើញជាទូទៅអំពីការត្រួតពិនិត្យឡើងវិញ ការវាយតម្លៃ និងការវាយតម្លៃសមត្ថភាពរបស់ខ្លួន។

## ៦. ការផ្តល់ព័ត៌មានជាសាធារណៈ

ចំពោះស្ថាប័ន/អង្គភាពមានសមត្ថកិច្ច តម្លាភាព គឺជាគោលការណ៍សំខាន់នៃអភិបាលកិច្ចល្អ។ ការផ្តល់ព័ត៌មានជាសាធារណៈអំពីការប្រតិបត្តិរបស់ស្ថាប័ន/អង្គភាពមានសមត្ថកិច្ច និងការប្រតិបត្តិរបស់អ្នកផ្តល់សេវា និងផ្តល់នូវទំនុកចិត្តនៅក្នុងប្រព័ន្ធធានាគុណភាព។

ស្ថាប័ន/អង្គភាពមានសមត្ថកិច្ចត្រូវរាយការណ៍ពីសកម្មភាពតាមរយៈ យុទ្ធសាស្ត្រនានា ដូចជារបាយការណ៍ប្រចាំឆ្នាំ បញ្ជីសកម្មភាពសមត្ថភាព ដែលត្រូវអនុវត្តធៀបនឹងអង្គភាពផ្តល់សេវា និងការធ្វើបច្ចុប្បន្នភាពគេហទំព័រ។ លើសពីនេះទៀត សម្រាប់ស្ថាប័ន/អង្គភាពដែលអនុវត្ត*ស្តង់ដាអន្តរជាតិស្តីពីភាពអនុលោមនៃការវាយតម្លៃសមត្ថភាព (IS0/IEC 17024:2012) – លក្ខខណ្ឌតម្រូវទូទៅសម្រាប់ស្ថាប័ន/អង្គភាព ឬបុគ្គលអនុវត្តការផ្តល់គុណវុឌ្ឍិ* ស្តង់ដាតម្រូវសម្រាប់ការផ្តល់ព័ត៌មានសាធារណៈ ពាក់ព័ន្ធនឹងដំណើរការការផ្តល់គុណវុឌ្ឍិ វិសាលភាពនៃកម្រងសមត្ថភាពសម្រាប់ការផ្តល់គុណវុឌ្ឍិសមត្ថភាព និងលក្ខខណ្ឌតម្រូវទទួលបាននូវកម្រងសមត្ថភាពសម្រាប់គុណវុឌ្ឍិដែលបានកំណត់។

### *សូចនាករទិន្នន័យគុណភាព*

ការធានាគុណភាពអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ពឹងផ្អែកមួយផ្នែកធំទៅលើ ទិន្នន័យដែលមានស្រាប់ ប្រកបដោយសុពលភាព ភាពជឿជាក់អំពីការអនុវត្ត និងលទ្ធផលនៃការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ (ក្របខណ្ឌធានាគុណភាពការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ នៃកិច្ចប្រជុំកំពូលអាស៊ីបូព៌ា ២០១២ (EAS TVET QAF ២០១២)។ ដើម្បីអាចតាមដានការប្រតិបត្តិ និងការផ្តល់របាយការណ៍វាយតម្លៃពឹងផ្អែកទាំងស្រុងទៅលើប្រព័ន្ធដែលមានការប្រមូលផ្តុំទិន្នន័យច្បាស់លាស់ និងមានស្តង់ដាត្រឹមត្រូវ។

ជាទូទៅ សូចនាករគុណភាពត្រូវបានធ្វើចំណាត់ថ្នាក់ដោយផ្អែកលើធាតុចូល និងលទ្ធផល។ ក្របខណ្ឌ ធានាគុណភាពការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈនៃកិច្ចប្រជុំកំពូលអាស៊ីបូព៌ា ២០១២ (EAS TVET QAF ២០១២) បានកត់សម្គាល់ថា សូចនាករធាតុចូលរួមមាន៖

- ក្រុមឧស្សាហកម្ម វិជ្ជាជីវៈអាជីព និងអ្នកជំនាញឯកទេសមុខរបរពាក់ព័ន្ធ ផ្តល់ការយល់ព្រមលើកម្រិតស្តង់ដាសមិទ្ធផលនៃការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ
- ស្ថាប័ន/អង្គភាពផ្តល់សេវាផ្តល់ការយល់ព្រមលើគុណភាព និងប្រើប្រាស់ស្តង់ដាសមិទ្ធផលនៃការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ
- ព័ត៌មានស្តីពីសមត្ថភាព និងបទពិសោធន៍របស់បុគ្គលិកស្ថាប័ន/អង្គភាពផ្តល់សេវា ប្រសិទ្ធភាពនៃប្រព័ន្ធគ្រប់គ្រង និងហិរញ្ញវត្ថុព្រមទាំងគុណភាព និងភាពឆ្លើយតបនៃអគារសិក្សា សម្ភារបរិក្ខារ និងបរិក្ខាររបស់អង្គភាពផ្តល់សេវាដែលមាន
- ព័ត៌មានស្តីពីមាតិកាសិក្សា រចនាបទ និងគុណភាពនៃដំណើរការបណ្តុះបណ្តាលរបស់ស្ថាប័ន/អង្គភាពផ្តល់សេវាការអប់រំបណ្តុះបណ្តាលបច្ចេក-ទេស និងវិជ្ជាជីវៈ
- ព័ត៌មានស្តីពីសេវាគាំទ្រ សិស្ស និស្សិត សម្ភារបរិក្ខារ អគារសិក្សា និងប្រព័ន្ធរបស់ស្ថាប័ន/អង្គភាពផ្តល់សេវា
- ព័ត៌មានស្តីពីលក្ខខណ្ឌតម្រូវ និងនីតិវិធីចុះឈ្មោះសិក្សា
- គំរូនៃការចុះឈ្មោះសិស្សចូលសិក្សា ដែលទាក់ទងនឹងគោលបំណងនៃគោលនយោបាយស្ថាប័ន/អង្គភាពផ្តល់សេវា
- ការវិនិយោគដោយស្ថាប័ន/អង្គភាពផ្តល់សេវាអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និងបុគ្គលក្នុងការអភិវឌ្ឍវិជ្ជាជីវៈអាជីព ការកែលម្អអគារសិក្សា សម្ភារបរិក្ខារ ប្រព័ន្ធធានាគុណភាព និងការច្នៃប្រឌិតផ្សេងៗទៀត
- កម្រិត និងគំរូនៃការចុះឈ្មោះសិស្សចូលសិក្សាសម្រាប់ស្ថាប័ន/អង្គភាពផ្តល់សេវា
- ភាពទូលំទូលាយ ភាពពាក់ព័ន្ធ និងភាពអាចចូលយកបានលើប្រព័ន្ធព័ត៌មាន
- យន្តការក្នុងការកំណត់វិស័យ និងប្រភេទនៃជំនាញដែលត្រូវការដោយឧស្សាហកម្ម (ទំព័រ ១៨-១៩)

សូចនាករលទ្ធផលត្រូវបានកត់សម្គាល់ដូចខាងក្រោម៖

- លទ្ធផលវាយតម្លៃសមត្ថភាព និងលទ្ធផលសវនកម្មលើការវាយតម្លៃសមត្ថភាពសម្រាប់ផ្នែកសមត្ថភាពនិងគុណវុឌ្ឍិ
- កំណត់ត្រានៃដំណើរការកម្មវិធីបណ្តុះបណ្តាល សកម្មភាពសិស្ស និស្សិត និងការវាយតម្លៃសមត្ថភាពសិស្ស និស្សិត
- អត្រាបញ្ចប់ការសិក្សា កម្រិតនៃការពេញចិត្ត និងគោលដៅសិក្សាបន្តរបស់និស្សិត រួមទាំងអត្រាបានការងារធ្វើ និងអត្រាសម្រាប់ក្រុមជំនាញតាមមុខរបរ/ឧស្សាហកម្ម និងសង្គមផ្សេងៗគ្នា

- ព័ត៌មានស្តីពីការប្រើប្រាស់ជំនាញនៅកន្លែងការងារ
- ការពេញចិត្តរបស់និយោជក និងអ្នកប្រើប្រាស់ផ្សេងទៀតជាមួយនឹងលទ្ធផលរបស់អ្នកបញ្ចប់ការសិក្សា
- ភស្តុតាងនៃភាពសុក្រឹតប្រព័ន្ធព័ត៌មាន ប្រព័ន្ធកំណត់តម្រូវការជំនាញ និងកំណត់តម្រូវការក្រុមជនងាយរងគ្រោះ និង/ឬសង្គមផ្សេងៗទៀត (ទំព័រ ១៩)។

ស្ថាប័ន/អង្គភាពមានសមត្ថកិច្ច គួរមានយុទ្ធសាស្ត្រសម្រាប់ការប្រមូលទិន្នន័យដោយអនុលោមតាមស្តង់ដាទិន្នន័យដែលបានឯកភាព ដើម្បីអាចអនុវត្តមុខងារនៃការវាយតម្លៃ និងការរាយការណ៍។

## *ក្របខណ្ឌអន្តរជាតិ*

ក្របខណ្ឌគុណវុឌ្ឍយោងអាស៊ាន តម្រូវឱ្យប្រទេសជាសមាជិកត្រូវធ្វើការពណ៌នាអំពីប្រព័ន្ធធានាគុណភាពជាតិសម្រាប់ការអប់រំ និងបណ្តុះបណ្តាល ដោយផ្អែកលើក្របខណ្ឌ ឬប្រព័ន្ធគុណវុឌ្ឍជាតិ នៅពេលធ្វើការផ្ទៀងផ្ទាត់។ ក្របខណ្ឌធានាគុណភាពចំនួន៣ ដែលបានប្រើធ្វើជាមូលដ្ឋានបង្អែកសម្រាប់ដំណើរការផ្ទៀងផ្ទាត់៖

- ក្របខណ្ឌធានាគុណភាពអាស៊ាន
- ក្របខណ្ឌធានាគុណភាពការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈនៃកិច្ចប្រជុំកំពូលអាស៊ីបូព៌ា (EAS TVET QAF)
- បណ្តាញទីភ្នាក់ងារអន្តរជាតិសម្រាប់ធានាគុណភាពក្នុងការអប់រំឧត្តមសិក្សា (INQAAHE)។

ក្របខណ្ឌធានាគុណភាពអាស៊ាន នឹងប្រើជាចំណុចយោងរួមមួយសម្រាប់ភ្នាក់ងារធានាគុណភាព និងស្ថាប័នឧត្តមសិក្សាក្នុងការខិតខំរបស់គេឱ្យមានសុខដុមនីយកម្មនឹងគ្នាលើពិពិធកម្មប្រព័ន្ធអប់រំឧត្តមសិក្សា វប្បធម៌ ប្រពៃណីដែលមានភាពខុសៗគ្នានៅក្នុងតំបន់។ ក្របខណ្ឌនេះ ប្រើប្រាស់គោលការណ៍ទូទៅ និងសេចក្តីថ្លែងការណ៍ស្តីពីការអនុវត្តល្អ។

ក្របខណ្ឌធានាគុណភាពការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈនៃកិច្ចប្រជុំកំពូលអាស៊ីបូព៌ា (EAS TVET QAF) ផ្តល់ជាមូលដ្ឋានដើម្បីជួយដល់សេដ្ឋកិច្ចនៃប្រទេសសមាជិកក្នុងការត្រួតពិនិត្យកែលម្អឡើង ឬបង្កើតប្រព័ន្ធធានាគុណភាពដែលមានភាពរឹងមាំ។ ក្របខណ្ឌនេះ មានឧបករណ៍ស្វ័យវាយតម្លៃដែលរួមបញ្ចូលនូវជំហានដំណើរការសម្រាប់បង្កើតផែនការសកម្មភាពផងដែរ។

សេចក្តីណែនាំរបស់បណ្តាញទីភ្នាក់ងារអន្តរជាតិ សម្រាប់ធានាគុណភាពក្នុងការអប់រំឧត្តមសិក្សា(INQAAHE) ស្តីពីការអនុវត្តល្អក្នុងការធានាគុណភាព មានបំណងលើកកម្ពស់ការអនុវត្តល្អសម្រាប់ការធានាគុណភាពផ្ទៃក្នុង និង/ឬខាងក្រៅ។ សេចក្តីណែនាំនោះ ត្រូវបានរៀបចំ និងប្រើប្រាស់ដោយគ្រប់ភ្នាក់ងារធានាគុណភាព ដែលនេះជាជំហាននៃការអភិវឌ្ឍរបស់គេ។

ព័ត៌មានបន្ថែមអំពីក្របខណ្ឌធានាគុណភាពទាំងបីនេះ ត្រូវបានបញ្ជាក់នៅក្នុងឧបសម្ព័ន្ធ។

## *ការផ្លាស់ប្តូរខ្នាតអន្តរជាតិ*

ប្រព័ន្ធមួយចំនួន ដែលផ្តល់ព័ត៌មានច្បាស់លាស់ និងមានតម្លាភាពអំពីដំណើរការធានាគុណភាពរបស់ស្ថាប័ន/អង្គភាពមានសមត្ថកិច្ចទៅកាន់អ្នកពាក់ព័ន្ធផ្សេងទៀតទាំងថ្នាក់ជាតិ និងអន្តរជាតិ ជាចំណុចចម្បង ក្នុងការលើកកម្ពស់ការយល់ដឹង និងជំនឿជាក់នៅក្នុងប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈរបស់ប្រទេសជាសមាជិកអាស៊ាន។

វិសាលភាពនៃព័ត៌មានដែលស្ថាប័ន/អង្គភាពមានសមត្ថកិច្ចនៃប្រទេសជាសមាជិកអាស៊ាន គួរត្រូវពិចារណាដាក់បញ្ចូលនៅក្នុងគេហទំព័ររបស់គេទាំងភាសាជាតិ និងភាសាអង់គ្លេស៖[37]

- បញ្ញត្តិច្បាប់ដែលទាក់ទងនឹងភ្នាក់ងារផ្តល់គុណវុឌ្ឍ និងតួនាទីរបស់ខ្លួន បទប្បញ្ញត្តិ ឬបទបញ្ជាណាមួយ នៃសេចក្តីណែនាំពាក់ព័ន្ធនឹងដំណើរការសំខាន់ៗ
- ក្របខណ្ឌជំនាញ និងការផ្សារភ្ជាប់ទៅនឹងក្របខណ្ឌគុណវុឌ្ឍ (ប្រសិនបើអាច)

[37] ជាភាសាផ្លូវការរបស់អាស៊ាន

- កម្រងសមត្ថភាពសម្រាប់ការផ្ដល់គុណវុឌ្ឍិសមត្ថភាព (ឬក្របខណ្ឌគុណវុឌ្ឍិ) ដែលទាក់ទងនឹងស្ដង់ដា បណ្ដុះបណ្ដាល និងតម្រូវការផ្ដល់គុណវុឌ្ឍិឡើងវិញ
- ឯកសារយុទ្ធសាស្ត្រធានាគុណភាពត្រូវបានចងក្រងនៅក្នុងសេចក្ដីណែនាំ ឬទិដ្ឋភាពទូទៅរួមមានដំណើរការអភិវឌ្ឍ និងអនុម័តកម្រងសមត្ថភាពសម្រាប់ការផ្ដល់គុណវុឌ្ឍិសមត្ថភាព ដំណើរការអនុម័តស្ថាប័ន/អង្គភាពផ្ដល់សេវាបណ្ដុះបណ្ដាល និង/ឬការវាយតម្លៃសមត្ថភាព និងការរៀបចំការត្រួតពិនិត្យតាមដាន
- បញ្ជីឈ្មោះស្ថាប័ន/អង្គភាពផ្ដល់សេវាបណ្ដុះបណ្ដាល និង/ឬការវាយតម្លៃសមត្ថភាព រួមទាំងទីកន្លែងវាយតម្លៃសមត្ថភាព និងអ្នកវាយតម្លៃសមត្ថភាព ដែលសហការអនុវត្តជាមួយស្ថាប័ន/អង្គភាពផ្ដល់សេវាខាងក្រៅ (ប្រសិនបើមាន)
- របាយការណ៍ទិន្នន័យ និងសកម្មភាពរួមបញ្ចូលទាំងការដាក់ទណ្ឌកម្ម ឬការបិទដំណើរការផ្ដល់សេវា
- របាយការណ៍វាយតម្លៃប្រព័ន្ធ អ.ប.វ

លើសពីនេះទៀត ការផ្សារភ្ជាប់ទំនាក់ទំនងទិន្នន័យទីផ្សារការងារ និងដំណើរការទទួលស្គាល់ជំនាញសម្រាប់ការចល័តកម្លាំងពលកម្មជំនាញ ឬសិស្សនិស្សិតអន្តរជាតិគួរត្រូវបញ្ចូលនៅក្នុងព័ត៌មានជាសាធារណៈ។

# ផ្នែកទី៤៖
# គោលការណ៍ណែនាំ និងពិធីសារ
# សម្រាប់ការធានាគុណភាព

## ផ្នែកទី ៤៖ គោលការណ៍ណែនាំ និងពិធីសារសម្រាប់ការធានាគុណភាព

ប្រទេសជាសមាជិកអាស៊ាននឹងអនុវត្តប្រព័ន្ធធានាគុណភាពរបស់ខ្លួន សម្រាប់ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ដោយប្រើវិធីសាស្ត្រផ្សេងៗគ្នាទៅតាមកម្រិតនៃការអនុវត្តនីមួយៗ។ ដើម្បីសម្របសម្រួល ដល់ការយោគយល់ និងជឿជាក់គ្នាទៅវិញទៅមកនៅក្នុងប្រទេសជាសមាជិកអាស៊ាន ដែលវិធីសាស្ត្រនៃការធានាគុណភាពការអប់រំបណ្តុះបណ្តាល និងវិជ្ជាជីវៈ គឺជាបណ្តុំគោលការណ៍ និងពិធីសាររួមមួយដែលមានការឯកភាពគ្នាសម្រាប់៖

- ស្ថាប័ន/អង្គភាពមានសមត្ថកិច្ច។ ស្ថាប័ន/អង្គភាពមានសមត្ថកិច្ចទទួលបន្ទុកលើគ្រប់ទិដ្ឋភាពទាំងអស់ ឬទិដ្ឋភាពមួយចំនួន នៃប្រព័ន្ធផ្តល់គុណវុឌ្ឍិសមត្ថភាព។ ស្ថាប័ន/អង្គភាពមានសមត្ថកិច្ច អាចជាអាជ្ញាធរផ្តល់គុណវុឌ្ឍិ ស្ថាប័ន/អង្គភាពទទួលបន្ទុកការបង្កើត/ការអនុម័តស្តង់ដាមុខរបរ ស្ថាប័ន/អង្គភាពផ្តល់ការបញ្ជាក់ឬផ្តល់គុណវុឌ្ឍិសមត្ថភាព។
- ស្ថាប័ន/អង្គភាពផ្តល់សេវាវាយតម្លៃសមត្ថភាព។ ជាស្ថាប័ន/អង្គភាពទាំងឡាយណាដែលផ្តល់សេវាវាយតម្លៃសមត្ថភាព (និងអាចជាអ្នកផ្តល់សេវាបណ្តុះបណ្តាល) ហើយក៏អាចជាស្ថាប័ន/អង្គភាពផ្តល់នូវការបញ្ជាក់ឬផ្តល់វិញ្ញាបនបត្រសមត្ថភាពផងដែរ។

### *ស្ថាប័ន/អង្គភាពមានសមត្ថកិច្ច*

### ១. គោលការណ៍ណែនាំសម្រាប់ស្ថាប័ន/អង្គភាពមានសមត្ថកិច្ច

គោលការណ៍ណែនាំនេះ បញ្ជាក់ពីការធានាគុណភាព និងដំណើរការនៃការត្រួតពិនិត្យគុណភាពដែលត្រូវបានប្រើប្រាស់ជាបុគ្គល និងជាសមូហភាពដោយស្ថាប័ន/អង្គភាពមានសមត្ថកិច្ចនីមួយៗដូចខាងក្រោម។

*អភិបាលកិច្ច*

ស្ថាប័ន/អង្គភាពមានសមត្ថកិច្ចត្រូវមានឯកសារច្បាស់លាស់ ស្តីពីការរៀបចំចាត់ចែងអភិបាលកិច្ច ដែលកំណត់អំពីការទទួលខុសត្រូវ និងការអនុវត្តគោលនយោបាយ និងនីតិវិធីនានា ដែលអនុវត្តដោយនាយកប្រតិបត្តិរបស់ទីភ្នាក់ងារ ដើម្បីផ្តល់ទិសដៅយុទ្ធសាស្ត្រសំដៅធានាឱ្យសម្រេចបាននូវគោលដៅគ្រប់គ្រងហានិភ័យ និងប្រើប្រាស់ធនធានប្រកបដោយទំនួលខុសត្រូវ ។

*គណនេយ្យភាព*

ស្ថាប័ន/អង្គភាពមានសមត្ថកិច្ចត្រូវមានក្របខណ្ឌច្បាប់ ឬរបាយការណ៍ ដើម្បីវាយតម្លៃការអនុវត្ត និងការប្រតិបត្តិរបស់ខ្លួន ឆ្លើយតបទៅនឹងលក្ខណវិនិច្ឆ័យដែលបានកំណត់។ ស្ថាប័ន/អង្គភាពមានសមត្ថកិច្ចនានា គួរតែធានាថារាល់លទ្ធផលនៃការធានាគុណភាព និងសកម្មភាពនៃការពិនិត្យគុណភាពឡើងវិញ ត្រូវបានរាយការណ៍ជាសាធារណៈយ៉ាងហោចណាស់មួយឆ្នាំម្តង។

*តម្លាភាព*

ស្ថាប័ន/អង្គភាពមានសមត្ថកិច្ច ត្រូវផ្តល់នូវព័ត៌មានឱ្យបានត្រឹមត្រូវ និងច្បាស់លាស់ ដែលទាក់ទងនឹងមុខងារសំខាន់ៗរបស់ខ្លួន រួមមាន ដំណើរការធានាគុណភាព ស្តង់ដា និងការប្រតិបត្តិ។

*ឯករាជ្យភាព*

ស្ថាប័ន/អង្គភាពមានសមត្ថកិច្ចត្រូវមានអាណត្តិ សេចក្តីណែនាំ ដំណើរការនិងការអនុវត្ត ដែលធានាបាននូវឯករាជ្យភាព នៃធាតុផ្សេងៗក្នុងប្រព័ន្ធធានាគុណភាព ការជៀសវាងនូវទំនាស់ផលប្រយោជន៍ និងឯករាជ្យភាពនៃការធ្វើសេចក្តីសម្រេចចិត្ត។

*ទំនុកចិត្ត និងស្តង់ដា*

ស្ថាប័ន/អង្គភាពមានសមត្ថកិច្ចត្រូវមានដំណើរការ និងការអនុវត្ត ដើម្បីផ្តល់នូវទំនុកចិត្តដល់ភាគីពាក់ព័ន្ធថាលទ្ធផលនៃការធានាគុណភាពឆ្លើយតបទៅនឹងស្តង់ដា (ទាំងធាតុចូល និងលទ្ធផល) ដែលបានកំណត់។

*ការកែលម្អជាប្រចាំ*

វិធីសាស្ត្រ នៃការធានាគុណភាពរបស់ស្ថាប័ន/អង្គភាពមានសមត្ថកិច្ចត្រូវធានាបាននូវការប្រើប្រាស់តុល្យភាព នៃយុទ្ធសាស្ត្រដើម្បីបង្កើនការផ្តល់សេវាកាន់តែល្អប្រសើរឡើងឆ្លើយតបទៅនឹងការផ្លាស់ប្តូរ និងតម្រូវការនាពេលអនាគតរបស់ភាគីពាក់ព័ន្ធនានា។

*សមាមាត្រភាព*

ស្ថាប័ន/អង្គភាពមានសមត្ថកិច្ចត្រូវតែមានវិធីសាស្ត្រនៃការធានាគុណភាព និងការត្រួតពិនិត្យគុណភាពឡើងវិញ ដែលត្រូវនឹងគោលបំណង និងឆ្លុះបញ្ចាំងពីបរិបទ និងភាពចម្រុះគ្នានៃប្រទេសជាសមាជិកអាស៊ាន។

*ភាពទន់ភ្លន់នៃសេវាកម្ម*

ស្ថាប័ន/អង្គភាពមានសមត្ថកិច្ចធានាថាពិធីសារ ត្រូវបង្កើតឡើងមានលក្ខណៈជាតិ ដើម្បីសម្របសម្រួលដល់សេវាវាយតម្លៃសមត្ថភាព ឬដំណើរការទទួលស្គាល់សមត្ថភាព ទាំងបេក្ខជនជាតិ និងអន្តរជាតិ។

*ការសហការ*

ស្ថាប័ន/អង្គភាពមានសមត្ថកិច្ចត្រូវសហការជាមួយស្ថាប័ន/អង្គភាពមានសមត្ថកិច្ចផ្សេងៗទៀតទាំងថ្នាក់ជាតិ
និងអន្តរជាតិ។

## ២. ពិធីសារ ណែនាំសម្រាប់ស្ថាប័ន/អង្គភាពមានសមត្ថកិច្ច

ស្ថាប័ន/អង្គភាពមានសមត្ថកិច្ចត្រូវសង្កេតមើលនូវពិធីសារក្នុងការគ្រប់គ្រងចាត់ចែង ការធានាគុណភាព និងសកម្មភាព ត្រួតពិនិត្យគុណភាពឡើងវិញ ដូចខាងក្រោម។

១. ស្ថាប័ន/អង្គភាពមានសមត្ថកិច្ច ត្រូវរៀបចំចងក្រងឯកសារ និងអនុវត្តប្រព័ន្ធគ្រប់គ្រងគុណភាព ដោយ បញ្ជាក់គ្រប់មុខងាររបស់ខ្លួន រួមមាន៖
   - ការអនុម័ត និងត្រួតពិនិត្យតាមដានស្តង់ដាសមិទ្ធផល ដែលការងារនេះត្រូវមានការចូលរួមពីវិស័យឧស្សាហកម្ម
   - ការអនុម័ត ការត្រួតពិនិត្យតាមដាន[38] និងការវាយតម្លៃស្ថាប័ន/អង្គភាពផ្តល់សេវាបណ្តុះបណ្តាល និង/ឬការវាយតម្លៃសមត្ថភាពត្រូវផ្អែកលើលក្ខណៈវិនិច្ឆ័យ ឬស្តង់ដា
   - ការត្រួតពិនិត្យតាមដានលទ្ធផល នៃការវាយតម្លៃសមត្ថភាព
   - ការចេញគុណវុឌ្ឍិ
   - ការគ្រប់គ្រងកំណត់ត្រា រួមទាំងស្តង់ដាទិន្នន័យ
   - សុវត្ថិភាពទិន្នន័យ
   - ការប្រើប្រាស់សេវាខាងក្រៅ (Outsourcing)[39]
   - ការដោះស្រាយពាក្យបណ្តឹង
   - កាតព្វកិច្ចរាយការណ៍
   - ការកែលម្អជាប្រចាំ និងការត្រួតពិនិត្យកែលម្អផ្ទៃក្នុង។

២. ស្ថាប័ន/អង្គភាពមានសមត្ថកិច្ចត្រូវផ្សព្វផ្សាយពីដំណើរការធានាគុណភាពរបស់ខ្លួនជាសាធារណៈ ជាភាសាជាតិ និងជាភាសាអង់គ្លេស។

៣. ស្ថាប័ន/អង្គភាពមានសមត្ថកិច្ចត្រូវគ្រប់គ្រងការប្រតិបត្តិរបស់ស្ថាប័ន/អង្គភាពផ្តល់សេវាវាយតម្លៃសមត្ថភាពតាមរយៈយន្តការនានា ដូចជាការលើកទឹកចិត្ត និងការដាក់ទណ្ឌកម្មជាក់លាក់ណាមួយ។

៤. ស្ថាប័ន/អង្គភាពមានសមត្ថកិច្ចត្រូវរក្សាទុកបញ្ជីឈ្មោះស្ថាប័ន/អង្គភាព ដែលបានអនុម័តលើការផ្តល់សេវាបណ្តុះបណ្តាល និង/ឬការវាយតម្លៃសមត្ថភាព និងស្តង់ដាសមិទ្ធផល ដូចជាកម្រងសមត្ថភាពសម្រាប់ការផ្តល់គុណវុឌ្ឍិសមត្ថភាពឬផ្តល់គុណវុឌ្ឍិ។

៥. ស្ថាប័ន/អង្គភាពមានសមត្ថកិច្ចត្រូវបង្កើតពិធិសារសម្រាប់ការផ្លាស់ប្តូរថ្នាក់អន្តរជាតិ រួមទាំងការប្តេជ្ញាចិត្តក្នុងការថែរក្សា ការប្រាស្រ័យទាក់ទងជាមួយទីភ្នាក់ងារមានសមត្ថកិច្ចថ្នាក់ជាតិ និងអន្តរជាតិ ព្រមទាំងការចូលរួមក្នុងវេទិកាអន្តរជាតិ ការផ្លាស់ប្តូរការអភិវឌ្ឍសមត្ថភាព និងសកម្មភាពផ្លូវផ្គងនានា។

៦. ស្ថាប័ន/អង្គភាពមានសមត្ថកិច្ច ប្តេជ្ញាពិនិត្យមើលឡើងវិញពីផ្នែកខាងក្រៅលើការប្រតិបត្តិរបស់ខ្លួនដោយឈរលើមូលដ្ឋានវដ្តនៃការពិនិត្យឡើងវិញ ហើយផ្សព្វផ្សាយជាសាធារណៈពីរបកគំហើញនៃការពិនិត្យឡើងវិញនោះ។

---

[38] Monitoring could include: reporting of student outcomes and/or stakeholder feedback data collection and analysis, surveillance, auditing etc.

[39] Qualifications systems or competency certification schemes whereby assessment services are futher approved to parties at a third level, e.g. to individual organizations or individual sites. This application is variously temed: ការជួយឧបត្ថម្ភគាំទ្រនីតិវិធីដំណើរការ និងស្តង់ដាគុណភាព (Auspice) ការទិញសិទ្ធិក្នុងការអនុវត្ត (Franchising) ការសហការអនុវត្ត ពី/ជាមួយស្ថាប័ន/អង្គភាពផ្តល់សេវាវាយតម្លៃសមត្ថភាពក្រៅប្រទេសដែលមានការទទួលស្គាល់គុណភាពអន្តរជាតិ (Outsourcing)។

### *ស្ថាប័ន/អង្គភាពផ្តល់សេវាវាយតម្លៃសមត្ថភាព*

## ១. គោលការណ៍ណែនាំសម្រាប់ស្ថាប័ន/អង្គភាពផ្តល់សេវា

គោលការណ៍ណែនាំនេះ បញ្ជាក់ពីការធានាគុណភាព និងដំណើរការត្រួតពិនិត្យគុណភាពដែលត្រូវបានប្រើប្រាស់ដោយស្ថាប័ន/អង្គភាពផ្តល់សេវាវាយតម្លៃសមត្ថភាពនីមួយៗ ដូចជាស្ថាប័ន/អង្គភាពវាយតម្លៃសមត្ថភាព ឬស្ថាប័ន/អង្គភាពផ្តល់ការបណ្តុះបណ្តាលនិងវាយតម្លៃសមត្ថភាព មានដូចខាងក្រោមៈ

*អភិបាលកិច្ច*

ស្ថាប័ន/អង្គភាពផ្តល់សេវាត្រូវមានគោលដៅនិងគោលបំណង ការរៀបចំអភិបាលកិច្ច និងវិធានការ ដែលបានចងក្រងជាឯកសារទៅតាមតម្រូវការ និងបទប្បញ្ញត្តិនានារបស់ស្ថាប័ន/អង្គភាពមានសមត្ថកិច្ចពាក់ព័ន្ធ។
ពួកគេគួរតែមានធនធានហិរញ្ញវត្ថុជាចាំបាច់សម្រាប់ការធ្វើប្រតិបត្តិការរបស់ខ្លួន។

*គណនេយ្យភាព*

ស្ថាប័ន/អង្គភាពផ្តល់សេវាត្រូវត្រួតពិនិត្យ និងវាយតម្លៃការអនុវត្ត និងការប្រតិបត្តិរបស់ខ្លួន ដោយផ្អែកលើតម្រូវការដែលបានកំណត់របស់ស្ថាប័ន/អង្គភាពមានសមត្ថកិច្ច និងប្រើប្រាស់ព័ត៌មានត្រឡប់របស់ភាគីពាក់ព័ន្ធដែលជាអតិថិជន។ ស្ថាប័ន/អង្គភាពផ្តល់សេវាគួរតែធានាថាលទ្ធផលនៃការធានាគុណភាព និងសកម្មភាពនៃការត្រួតពិនិត្យគុណភាពត្រូវបានរាយការណ៍ជាសាធារណៈ។

*តម្លាភាព*

ស្ថាប័ន/អង្គភាពផ្តល់សេវាត្រូវមានព័ត៌មានត្រឹមត្រូវ និងច្បាស់លាស់ ទាក់ទងនឹងសេវាវាយតម្លៃសមត្ថភាព និងការគាំទ្រសម្រាប់អតិថិជន។

*ឯករាជ្យភាព*

ស្ថាប័ន/អង្គភាពផ្តល់សេវាត្រូវធានាថាពួកគេអនុវត្តសេវាកម្មរបស់ខ្លួន (ឧទាហរណ៍ៈ ការវាយតម្លៃសមត្ថភាព) ដោយមិនលម្អៀង ជៀសវាងទំនាស់ផលប្រយោជន៍ និងធានានូវឯករាជ្យភាពលើការធ្វើសេចក្តីសម្រេចចិត្ត ជាពិសេសការសម្រេចចិត្តលើលទ្ធផលនៃការវាយតម្លៃសមត្ថភាព។

*ទំនុកចិត្ត និងស្តង់ដា*

ស្ថាប័ន/អង្គភាពផ្តល់សេវាត្រូវមានដំណើរការ និងការអនុវត្តដើម្បីធានាថាសេវាកម្មនានាបានអនុវត្តដោយខ្លួនឯងឬក្នុងនាមខ្លួន ឱ្យឆ្លើយតបនឹងស្តង់ដាបានកំណត់ និងការរំពឹងទុក។ ដំណើរការ និងការអនុវត្តរបស់ស្ថាប័ន/អង្គភាពផ្តល់សេវា គួរផ្តល់ជូនស្ថាប័ន/អង្គភាពមានសមត្ថកិច្ច និងភាគីពាក់ព័ន្ធនូវការធានាចំពោះការឆ្លើយតបទៅនឹងស្តង់ដាសមិទ្ធផល។

*ការកែលម្អជាប្រចាំ*

គុណភាពនៃដំណើរការ និងការអនុវត្តរបស់ស្ថាប័ន/អង្គភាពផ្តល់សេវាត្រូវអនុលោមតាមលក្ខខណ្ឌតម្រូវ និងមានការកែលម្អជាប្រចាំ ដើម្បីធានាថាសេវាកម្មរបស់ពួកគេឆ្លើយតបនឹងតម្រូវការរបស់ភាគីពាក់ព័ន្ធ និងអតិថិជន។

*សមាមាត្រភាព*

វិធីសាស្ត្រនៃការត្រួតពិនិត្យ និងធានាគុណភាពរបស់ស្ថាប័ន/អង្គភាពផ្តល់សេវា ត្រូវឆ្លើយតបនឹងគោលបំណង និងផ្តោតលើការធានាបាននូវគុណភាពនៃលទ្ធផល។

*ភាពទន់ភ្លន់នៃសេវាកម្ម*

ស្ថាប័ន/អង្គភាពផ្តល់សេវា ត្រូវប្រាកដថាឧបសគ្គរបស់បេក្ខជនជាតិ ឬអន្តរជាតិបានកាត់បន្ថយនៅកម្រិតអប្បបរមា នៅពេលដែលខ្លួនផ្តល់សេវាវាយតម្លៃសមត្ថភាព។

## ២. ពិធីសារណែនាំសម្រាប់ស្ថាប័ន/អង្គភាពផ្តល់សេវា

ស្ថាប័ន/អង្គភាពផ្តល់សេវាត្រូវសង្កេតមើលពិធីសារ ក្នុងការគ្រប់គ្រងការធានាគុណភាព និងសកម្មភាពពិនិត្យគុណភាពឡើងវិញរបស់ខ្លួនដូចខាងក្រោម។

១. ស្ថាប័ន/អង្គភាពផ្តល់សេវាត្រូវរៀបចំចងក្រងឯកសារ និងអនុវត្តប្រព័ន្ធគ្រប់គ្រងគុណភាព ដើម្បីធានាផ្តល់សេវាវាយតម្លៃសមត្ថភាពមានគុណភាព រួមមាន៖

- ធានាថាមានធនធានវាយតម្លៃសមត្ថភាពសមស្រប ធនធានរូបវន្ត មានលក្ខណៈត្រឹមត្រូវតាមកម្រងសមត្ថភាពសម្រាប់ការផ្តល់គុណវុឌ្ឍិសមត្ថភាព ឬកម្មវិធីផ្តល់គុណវុឌ្ឍិ
- ប្រាកដថាកម្រិតសមត្ថភាពរបស់បុគ្គលិកសមស្រប សម្រាប់សេវាវាយតម្លៃសមត្ថភាព រួមទាំងការអភិវឌ្ឍវិជ្ជាជីវៈអាជីព
- ធាននូវសេវាគាំទ្រសមស្របដល់បេក្ខជនដែលត្រូវវាយតម្លៃសមត្ថភាព
- ត្រួតពិនិត្យសេវាកម្មតាមរយៈព័ត៌មានត្រឡប់របស់អតិថិជន និងភាគីពាក់ព័ន្ធ
- លទ្ធផលនៃការវាយតម្លៃសមត្ថភាពមានសុពលភាព និងអាចទុកចិត្តបាន
- ការចេញគុណវុឌ្ឍិ ឬវិញ្ញាបនបត្រ (ប្រសិនបើអាច)
- ការគ្រប់គ្រងកំណត់ត្រា
- សុវត្ថិភាពទិន្នន័យ
- ការរៀបចំប្រើប្រាស់សេវាខាងក្រៅ (Outsourcing arrangements)
- ដោះស្រាយពាក្យបណ្តឹងរបស់អតិថិជន
- កាតព្វកិច្ចក្នុងការរាយការណ៍
- ការកែលម្អជាប្រចាំ និងការត្រួតពិនិត្យផ្ទៃក្នុង។

២. ស្ថាប័ន/អង្គភាពផ្តល់សេវាត្រូវទទួលខុសត្រូវរាល់សេវាវាយតម្លៃសមត្ថភាពទាំងអស់ដែលខ្លួនបានធ្វើឡើង។ អ្នកផ្តល់សេវា ត្រូវថែរក្សាបញ្ជីទ្រព្យសម្បត្តិជាសាធារណៈ ក្នុងបរិវេណអគារ មជ្ឈមណ្ឌល ឬទីកន្លែងវាយតម្លៃសមត្ថភាពរបស់ខ្លួន និងផ្តល់ព័ត៌មានពីការប្រតិបត្តិនៃផ្នែកទាំងនេះជាសាធារណៈ។

៣. ស្ថាប័ន/អង្គភាពផ្តល់សេវាត្រូវអនុវត្តយុទ្ធសាស្ត្រប្រកបដោយសមធម៌ និងទទួលយកបាននៅក្នុងការផ្តល់សេវាកម្មនានា រួមមានលក្ខខណ្ឌតម្រូវនៃការទទួលបានសេវា ការគាំទ្រចំពោះអតិថិជនដែលជាជនពិការនៅក្នុងការសិក្សា និង/ឬការវាយតម្លៃសមត្ថភាព ការទទួលស្គាល់ការសិក្សាដែលមានពីមុន[40] និងការទទួលស្គាល់ការវាយតម្លៃសមត្ថភាព ដោយស្ថាប័ន/អង្គភាពផ្តល់សេវាធានាគុណភាព ឬស្ថាប័ន/អង្គភាពមានសមត្ថកិច្ចផ្សេងៗទៀត។

៤. ស្ថាប័ន/អង្គភាពផ្តល់សេវា ត្រូវអនុវត្តដំណើរការ និងការប្រតិបត្តិ ដើម្បីធានាថាការសម្រេចចិត្តត្រូវបានធ្វើឡើងដោយមិនលម្អៀង និងមិនមានទំនាស់ផលប្រយោជន៍ ឬឥទ្ធិពលមិនត្រឹមត្រូវ។

៥. ស្ថាប័ន/អង្គភាពផ្តល់សេវាត្រូវអនុវត្តតាមនីតិវិធី ដើម្បីកាត់បន្ថយឧបសគ្គឱ្យនៅកម្រិតអប្បបរមា នៃការផ្តល់សេវាវាយតម្លៃសមត្ថភាព រួមទាំងការ-ផ្តល់ការវាយតម្លៃសមត្ថភាពនៅពេលវេលាកំណត់ជាក់លាក់ណាមួយដែលថ្លៃសេវានេះត្រូវមានតម្លៃសមរម្យនិងមានតម្លាភាព ព្រមទាំងមិនតឹងរឹងចំពោះការទទួល ឬផ្គត់ផ្គង់សេវាវាយតម្លៃសមត្ថភាព។

៦. ស្ថាប័ន/អង្គភាពផ្តល់សេវា ត្រូវបង្កើតពិធីសារសម្រាប់រក្សាការប្រាស្រ័យទាក់ទងជាមួយស្ថាប័ន/អង្គភាពមានសមត្ថកិច្ច និងស្ថាប័ន/អង្គភាពផ្តល់សេវាផ្សេងទៀត ព្រមទាំងការចូលរួមនៅក្នុងសកម្មភាពផ្គូផ្គង និង/ឬការវាយតម្លៃសមត្ថភាពដោយមិនលម្អៀង។

៧. ស្ថាប័ន/អង្គភាពផ្តល់សេវា ត្រូវតែទទួលខុសត្រូវចំពោះការរក្សានូវភាពអនុលោមជាមួយនឹងស្តង់ដាគុណភាព។ ស្ថាប័ន/អង្គភាពផ្តល់សេវាត្រូវមានវិធីសាស្ត្រក្នុងការកែលម្អជាប្រចាំលើសេវាវាយតម្លៃសមត្ថភាពរបស់ខ្លួន។ ស្ថាប័ន/អង្គភាពផ្តល់សេវា ត្រូវមានការត្រួតពិនិត្យការប្រតិបត្តិរបស់ខ្លួនឡើងវិញពីផ្នែកខាងក្រៅ ហើយផ្សព្វផ្សាយជាសាធារណៈពីអ្វីដែលបានរកឃើញ។

[40] ករណីនេះ ក៏អាចកំណត់ថា ជាការទទួលស្គាល់សមត្ថភាពបច្ចុប្បន្នផងដែរ។

# ផ្នែកទី៥៖
# គោលការណ៍ណែនាំ និងពិធីសារសម្រាប់ ការទទួលស្គាល់ប្រព័ន្ធផ្តល់គុណវុឌ្ឍិសមត្ថភាព របស់ប្រទេសជាសមាជិកអាស៊ាន

## ផ្នែកទី ៥៖ គោលការណ៍ណែនាំ និង ពិធីសារ សម្រាប់ការទទួលស្គាល់ប្រព័ន្ធផ្តល់គុណវុឌ្ឍិសមត្ថភាពរបស់ប្រទេសជាសមាជិកអាស៊ាន

ស្ថាប័ន/អង្គភាពមានសមត្ថកិច្ចត្រូវធ្វើដូចម្តេច ដើម្បីធានាគុណភាពលើការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ដោយសារវាមានភាពខុសគ្នាយ៉ាងខ្លាំងពីប្រទេសមួយទៅប្រទេសមួយក្នុងតំបន់។ ការកើនឡើងនៃការចល័តកម្លាំងពលកម្មជំនាញ និងសិស្ស និស្សិត ជាសម្ពាធមួយនៃសមាគមអាស៊ាន ដែលពាក់ព័ន្ធតំបន់ពាណិជ្ជកម្មសេរី រួមទាំងការអំពាវនាវឱ្យមានកិច្ចព្រមព្រៀងទទួលស្គាល់គ្នាទៅវិញទៅមក និងដើម្បីជួយសម្រួលដល់ការទទួលស្គាល់សិស្ស និស្សិត និងកម្លាំងពលកម្មជំនាញដែលចល័តតាមព្រំដែន។ សម្ពាធទាំងនេះនាំឱ្យមានតម្រូវការសម្រាប់ស្ថាប័ន/អង្គភាពមានសមត្ថកិច្ច ពង្រីកការយល់ដឹងអំពីមធ្យោបាយនៃការធានាគុណភាពលើការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈនៅក្នុងប្រទេសរបស់ពួកគេ ដើម្បីសម្រេចបានលទ្ធផល ដែលអាចធៀបនឹងលទ្ធផលរំពឹងទុកសម្រាប់ការទំនាក់ទំនង និងទទួលស្គាល់ស្ថាប័ន/អង្គភាពមានសមត្ថកិច្ច នៃប្រទេសជាសមាជិកអាស៊ានផ្សេងទៀត។

បច្ចុប្បន្ននេះ ស្ថាប័ន/អង្គភាពមានសមត្ថកិច្ចរបស់ប្រទេសជាសមាជិកអាស៊ានមួយចំនួន បានធ្វើការសហការចុះអនុស្សរណៈនៃការយោគយល់គ្នាជាមួយស្ថាប័ន/អង្គភាពផ្សេងទៀត ហើយបានពង្រឹងកិច្ចសន្ទនាទូទាំងតំបន់។ ក្នុងនាមជាសមាគមមួយ ប្រទេសជាសមាជិកអាស៊ានមានបំណង ដើម្បីផ្តល់នូវរចនាសម្ព័ន្ធរួមមួយ និងមានសង្គតិភាពមួយចំនួននៅក្នុងការអនុវត្តទទួលស្គាល់ប្រព័ន្ធផ្តល់គុណវុឌ្ឍិសមត្ថភាព ហើយពីស្ថាប័ន/អង្គភាពមានសមត្ថកិច្ចមួយទៅមួយទៀត។ ទោះជាយ៉ាងណាក៏ដោយ ករណីនេះមិនមែនមានន័យថា កម្រងសមត្ថភាពជាក់លាក់សម្រាប់ការផ្តល់គុណវុឌ្ឍិសមត្ថភាពត្រូវបានទទួលស្គាល់ដោយស្វ័យប្រវត្តិនោះទេ ឬន័យម្យ៉ាងទៀតបុគ្គលដែលបានធ្វើការវាយតម្លៃសមត្ថភាពហើយចេញគុណវុឌ្ឍិដោយស្ថាប័ន/អង្គភាពមានសមត្ថកិច្ចមួយ នឹងត្រូវទទួលស្គាល់ដោយស្វ័យប្រវត្តិពីស្ថាប័ន/អង្គភាពមានសមត្ថកិច្ចផ្សេងទៀតឡើយ។
ក្នុងន័យនេះ អ្វីដែលចង់បញ្ជាក់នោះគឺថា ការវាយតម្លៃ ឬការងារដែលអនុវត្តដោយស្ថាប័ន/អង្គភាពមានសមត្ថកិច្ចនឹងត្រូវបានគេទទួលស្គាល់ ហើយបុគ្គលម្នាក់ៗចាំបាច់ត្រូវធ្វើការវាយតម្លៃបន្ថែមក្នុងគោលបំណងនៃការទទួលស្គាល់ ការផ្តល់អាជ្ញាបណ្ណ ឬការផ្តល់វិញ្ញាបនបត្រវិជ្ជាជីវៈអាជីពជាផ្លូវការ។

### *គោលការណ៍ណែនាំសម្រាប់ការទទួលស្គាល់*

គោលការណ៍ណែនាំគាំទ្រដល់ការទទួលស្គាល់ប្រព័ន្ធផ្តល់គុណវុឌ្ឍិសមត្ថភាព រួមមាន៖

***អធិបតេយ្យភាព***
ប្រទេសជាសមាជិក ត្រូវធ្វើតាមរចនាសម្ព័ន្ធ និងដំណើរការធានាគុណភាពជាក់លាក់របស់ប្រទេសនីមួយៗដែលជាការឆ្លើយតបទៅនឹងអាទិភាពរបស់ជាតិ។

***ការប្រៀបធៀប***
ប្រទេសជាសមាជិកប្រើប្រាស់ប្រព័ន្ធធានាគុណភាពជាចំណុចគោល ដើម្បីកំណត់ការប្រៀបធៀបប្រព័ន្ធធានាគុណភាព ជាជាងការស្វែងរក ឬការសន្មត់ថារចនាសម្ព័ន្ធ និងដំណើរការធានាគុណភាពមានសភាពដូចគ្នា។ ប្រព័ន្ធធានាគុណភាព ត្រូវមានភាពទន់ភ្លន់ស្របនឹងការអភិវឌ្ឍជាតិ និងពិភពលោក និងមានសង្គតិភាពនៅក្នុងការអនុវត្ត ដើម្បីជំរុញការប្រៀបធៀប និងបង្កើនការជឿទុកចិត្ត។

***តម្លាភាព***
ប្រទេសជាសមាជិកត្រូវលើកកម្ពស់តម្លាភាពនៃស្តង់ដា និងវិធានការធានាគុណភាពរបស់ខ្លួន ព្រមទាំងលទ្ធផល នៃដំណើរការនៃការផ្ទួងផ្ទាត់។

***គណនេយ្យភាព***
ប្រទេសជាសមាជិក ត្រូវលើកទឹកចិត្តចំពោះការវាយតម្លៃ និងការធ្វើរបាយការណ៍ស្តីពីការប្រតិបត្តិរបស់ស្ថាប័ន/អង្គភាពមានសមត្ថកិច្ចដោយប្រៀបធៀបនឹងគោលការណ៍អន្តរជាតិដែលបានឯកភាពគ្នា។[41] ការវាយតម្លៃរួមមាន ការពិគ្រោះយោបល់ជាមួយដៃគូ និងភាគីពាក់ព័ន្ធដែលរបាយការណ៍លទ្ធផលត្រូវធ្វើជាសាធារណៈ។

***ការកែលម្អជាប្រចាំ***
ប្រទេសជាសមាជិក ត្រូវធ្វើតាមកម្រិតនៃការអនុវត្តប្រព័ន្ធធានាគុណភាពរបស់ប្រទេសនីមួយៗ ដោយត្រូវយល់ថាប្រព័ន្ធទាំងនេះត្រូវបានផ្អែកលើវិធីសាស្ត្រនៃការកែលម្អជាប្រចាំ។

[41] INQAAHE guidelines, EAS TVET QAF, ASEAN Quality Assurance Framework

***ពិធីសារណែនាំសម្រាប់ការទទួលស្គាល់***

ដើម្បីធានាថាដំណើរការទទួលស្គាល់ប្រព័ន្ធផ្តល់គុណវុឌ្ឍិសមត្ថភាព ត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាព តម្លាភាព និងសង្គតិភាព ព្រមទាំងភាពស៊ីសង្វាក់គ្នាទូទាំងប្រទេសជាសមាជិកអាស៊ាន ពិធីសារដែលបានឯកភាពគ្នា មានដូចខាងក្រោម៖

១. ស្ថាប័ន/អង្គភាពមានសមត្ថកិច្ចរបស់ប្រទេសជាសមាជិកអាស៊ាននីមួយៗដែលបានចូលរួម ត្រូវព្រមព្រៀងលើប្រព័ន្ធទទួលស្គាល់គោល សម្រាប់ការវាយតម្លៃប្រព័ន្ធផ្តល់គុណវុឌ្ឍិសមត្ថភាពប្រទេសជាសមាជិកអាស៊ាន។

២. រចនាសម្ព័ន្ធរបស់ប្រព័ន្ធផ្តល់គុណវុឌ្ឍិសមត្ថភាពនៅក្នុងប្រទេសជាសមាជិកអាស៊ាននីមួយៗ ត្រូវបានពណ៌នាធៀបនឹងប្រព័ន្ធទទួលស្គាល់គោលដែលបានព្រមព្រៀងគ្នា។

៣. ស្ថាប័ន/អង្គភាពមានសមត្ថកិច្ចពាក់ព័ន្ធនីមួយៗ ត្រូវធ្វើការបញ្ជាក់ដោយឈរលើមូលដ្ឋានច្បាប់ និងការទទួលខុសត្រូវ។ ប្រសិនបើនៅក្នុងប្រទេសជាសមាជិកអាស៊ាន មានស្ថាប័ន/អង្គភាពមានសមត្ថកិច្ចលើសពីមួយ នោះទំនាក់ទំនងរវាងស្ថាប័ន/អង្គភាពមានសមត្ថកិច្ចនីមួយៗ ត្រូវធ្វើការពន្យល់បន្ថែម។

៤. ស្ថាប័ន/អង្គភាពមានសមត្ថកិច្ចរបស់ប្រទេសជាសមាជិកអាស៊ាននីមួយៗ ដែលបានចូលរួមត្រូវមានភាពច្បាស់លាស់ និងបង្ហាញពីភាពបន្សីគ្នានៃកម្រងសមត្ថភាពសម្រាប់ការផ្តល់គុណវុឌ្ឍិសមត្ថភាព ដែលពាក់ព័ន្ធនៃប្រព័ន្ធផ្តល់គុណវុឌ្ឍិសមត្ថភាព ទៅនឹងការពិពណ៌នាអំពីសមត្ថភាពក្នុងកម្រិតនីមួយៗ (បើអាចធ្វើបាន)។ ក្របខណ្ឌគុណវុឌ្ឍិជាតិ និងការពិពណ៌នាអំពីសមត្ថភាពក្នុងកម្រិតនីមួយៗនៃក្របខណ្ឌគុណវុឌ្ឍិយោងអាស៊ានត្រូវបានពន្យល់ពីការបន្សីគ្នា (បើអាចធ្វើបាន)។

៥. វិធីសាស្ត្រនៃការធានាគុណភាពរបស់ស្ថាប័ន/អង្គភាពមានសមត្ថកិច្ចពាក់ព័ន្ធនីមួយៗ ត្រូវធ្វើការបន្សីគ្នាទៅនឹងលក្ខណវិនិច្ឆ័យដែលបានឯកភាព។ លក្ខណៈវិនិច្ឆ័យដូចបានបញ្ជាក់នៅក្នុងវិធីសាស្ត្រគោល ដែលបានព្រមព្រៀងគ្នានឹងប្រើជាមូលដ្ឋានសម្រាប់សកម្មភាពនានា។ ឧទាហរណ៍៖

- ស្ថាប័ន/អង្គភាពមានសមត្ថកិច្ចនីមួយៗ ត្រូវធ្វើការបញ្ជាក់អំពីនីតិវិធីនៃការអនុម័តលើកម្រងសមត្ថភាព សម្រាប់ផ្តល់គុណវុឌ្ឍិសមត្ថភាព និងការអនុម័ត ព្រមទាំងការត្រួតពិនិត្យតាមដានលើអង្គភាពផ្តល់សេវាបណ្តុះបណ្តាល និង/ឬការវាយតម្លៃសមត្ថភាព។
- ការគ្រប់គ្រង និងត្រួតពិនិត្យតាមដានអ្នកវាយតម្លៃសមត្ថភាព និងការសម្រេចចិត្តលើការវាយតម្លៃសមត្ថភាព។

៦. ការធានាគុណភាពលើកម្រងសមត្ថភាពសម្រាប់ផ្តល់គុណវុឌ្ឍិសមត្ថភាព ត្រូវអនុវត្តសកម្មភាពជាសមូហភាព និងត្រូវមានអ្នកចូលរួមឯករាជ្យដែលមានបទពិសោធន៍។

៧. លទ្ធផលនៃដំណើរការលើរបាយការណ៍ដែលបានឯកភាពគ្នាតែមួយ រួមមាន៖

- ការរៀបចំដំណើរការ របកគំហើញនៃសកម្មភាពទទួលស្គាល់ កំណត់កម្រិតការប្រៀបធៀប និងកម្រិតការទទួលស្គាល់ដែលបានឯកភាពគ្នា
- ធ្វើការចងក្រងជាឯកសារ និងការឯកភាពគ្នាទៅវិញទៅមកលើសកម្មភាព សម្រាប់បង្កើនការប្រៀបធៀបរវាងប្រព័ន្ធផ្តល់គុណវុឌ្ឍិសមត្ថភាពរបស់ប្រទេសជាសមាជិកអាស៊ានដែលចូលរួម។
- ប្រសិនបើលទ្ធផលសកម្មភាពទទួលស្គាល់ស្ថិតក្នុងកម្រិតនៃការប្រៀបធៀបខ្ពស់ ស្ថាប័ន/អង្គភាពមានសមត្ថកិច្ចនីមួយៗ ត្រូវមានឆន្ទៈទទួលយកការទទួលស្គាល់ជាសាធារណៈ។

៨. របាយការណ៍នៃការទទួលស្គាល់ត្រូវផ្សព្វផ្សាយជាសាធារណៈ ក្នុងបណ្តាប្រទេសជាសមាជិកអាស៊ាន ដែលបានចូលរួមនីមួយៗ។ របាយការណ៍បច្ចុប្បន្នភាព ត្រូវប្រគល់តាមពេលកំណត់។

# ផ្នែកទី៦៖
# ការចូលរួមនៅក្នុងសកម្មភាពផ្ដល់ផ្ដលថ្នាក់ជាតិ

## ផ្នែកទី ៦៖ ការចូលរួមនៅក្នុងសកម្មភាពផ្ទៀងផ្ទាត់ថ្នាក់ជាតិ

### *សាវតារ*

ក្របខណ្ឌគុណវុឌ្ឍិយោងអាស៊ាន (AQRF) គឺជាក្របខណ្ឌយោងរួមមួយក្នុងតំបន់។ ក្របខណ្ឌគុណវុឌ្ឍិយោងអាស៊ាន ជាឧបករណ៍មួយក្នុងការជំរុញការប្រៀបធៀបគុណវុឌ្ឍិទូទាំងប្រទេសជាសមាជិកអាស៊ាន។

ដំណើរការផ្ទៀងផ្ទាត់ គឺជាដំណើរការស្វ័យតរបស់ជាតិ ដែលភាគីពាក់ព័ន្ធ និងអាជ្ញាធរជាតិឯកភាពគ្នាលើការបន្សុីគ្នារវាងកម្រិតគុណវុឌ្ឍិជាតិនីមួយៗ និងកម្រិតគុណវុឌ្ឍិក្នុងក្របខណ្ឌគុណវុឌ្ឍិយោងអាស៊ាន។ ការបន្សុីគ្នារវាងកម្រិតគុណវុឌ្ឍិជាតិ និងកម្រិតគុណវុឌ្ឍិយោងអាស៊ាន គឺជាលទ្ធផលមួយនៃដំណើរការផ្ទៀងផ្ទាត់ និងតាមរយៈក្របខណ្ឌគុណវុឌ្ឍិយោងអាស៊ាននឹងបង្កើនការបន្សុីគ្នាបន្ថែមទៀត ចំពោះកម្រិតគុណវុឌ្ឍិនៅក្នុង ប្រទេសជាសមាជិកអាស៊ាន។ ឧទាហរណ៍៖ ដំណើរការបន្សុីគ្នានេះ អាចនឹងឃើញគ្រប់កម្រិតគុណវុឌ្ឍិជាតិឱ្យសុីគ្នាទៅនឹងកម្រិតជាក់លាក់ក្នុងក្របខណ្ឌគុណវុឌ្ឍិយោងអាស៊ាន និងអាចប្រៀបធៀបជាមួយគុណវុឌ្ឍិប្រទេសផ្សេងៗទៀត ដែលមានកម្រិតដូចគ្នានៃក្របខណ្ឌគុណវុឌ្ឍិយោងអាស៊ាន។

ជាពិសេស ដំណើរការផ្ទៀងផ្ទាត់ដែលរំពឹងទុក ត្រូវរួមបញ្ចូលនូវការប្រឹក្សាយោបល់ជាមួយភាគីពាក់ព័ន្ធពីសំណើនៃការបន្សុីគ្នារវាងកម្រិតក្របខណ្ឌគុណវុឌ្ឍិជាតិ និងកម្រិតក្របខណ្ឌគុណវុឌ្ឍិយោងអាស៊ាននៅក្នុងប្រទេសជាសមាជិកអាស៊ាននីមួយៗ រាយការណ៍ពីលទ្ធផលនៃការផ្ទៀងផ្ទាត់ថ្នាក់ជាតិចំពោះគណៈកម្មាធិការក្របខណ្ឌគុណវុឌ្ឍិយោងអាស៊ាន ដំណើរការត្រួតពិនិត្យរបាយការណ៍លទ្ធផលផ្ទៀងផ្ទាត់ជាមួយសមាជិកនីមួយៗ នៃគណៈកម្មាធិការក្របខណ្ឌគុណវុឌ្ឍិជាតិជាមួយនឹងក្របខណ្ឌគុណវុឌ្ឍិយោងអាស៊ាន និងចុងក្រោយទទួលបានរបាយការណ៍ផ្លូវការមួយនៃការបន្សុីគ្នារវាងក្របខណ្ឌគុណវុឌ្ឍិជាតិរបស់ប្រទេសជាសមាជិកជាមួយនឹងក្របខណ្ឌគុណវុឌ្ឍិយោងអាស៊ាន។ ដំណើរការនេះ អាចមានភាពស្មុគស្មាញ និងពាក់ព័ន្ធនឹងការងារបច្ចេកទេសដែលមានផ្នែកសង្គម-នយោបាយយ៉ាងសំខាន់។

ដើម្បីធានាថា ដំណើរការផ្ទៀងផ្ទាត់នេះ ត្រូវបានអនុវត្តដោយប្រសិទ្ធភាព តម្លាភាព និងក្នុងមធ្យោបាយដែលមានសង្គតិភាព និងសុីសង្វាក់គ្នាទូទាំងសហគមន៍អាស៊ាន ក្របខណ្ឌគុណវុឌ្ឍិយោងអាស៊ាន រួមបញ្ចូលនូវលក្ខណវិនិច្ឆ័យចំនួនដប់មួយ (១១) ដែលបានឯកភាពគ្នា ដើម្បីលើកកម្ពស់ដំណើរការផ្ទៀងផ្ទាត់រួម។ លក្ខណៈវិនិច្ឆ័យទាំងនេះ មានដូចខាងក្រោម។

១. ត្រូវពណ៌នាពីរចនាសម្ព័ន្ធនៃប្រព័ន្ធអប់រំ និងបណ្ដុះបណ្ដាល។
២. ត្រូវកំណត់ឱ្យច្បាស់លាស់ពីការទទួលខុសត្រូវ និងមូលដ្ឋានច្បាប់នៃគ្រប់ស្ថាប័នជាតិទាំងអស់ ដែលពាក់ព័ន្ធនៅក្នុងដំណើរការផ្ទៀងផ្ទាត់ ហើយបោះពុម្ពផ្សាយជាសាធារណៈដោយអាជ្ញាធរមានសមត្ថកិច្ចដែលទទួលបន្ទុកដំណើរការផ្ទៀងផ្ទាត់នោះ។
៣. ត្រូវមានតម្លាភាពលើនីតិវិធីនៃការដាក់បញ្ចូលគុណវុឌ្ឍិនៅក្នុងក្របខណ្ឌគុណវុឌ្ឍិជាតិ ឬការពណ៌នាអំពីទីតាំងគុណវុឌ្ឍិនៅក្នុងប្រព័ន្ធគុណវុឌ្ឍិជាតិ។
៤. ត្រូវបង្ហាញ និងមានភាពច្បាស់លាស់ពីការបន្សុីគ្នារវាងការពណ៌នាអំពីសមត្ថភាពក្នុងកម្រិតនីមួយៗ នៅក្នុងក្របខណ្ឌ ឬប្រព័ន្ធគុណវុឌ្ឍិជាតិ និងការពណ៌នាអំពីសមត្ថភាពកក្នុងកម្រិតនីមួយៗ នៃក្របខណ្ឌគុណវុឌ្ឍិយោងអាស៊ាន។
៥. ត្រូវពណ៌នាពីមូលដ្ឋានស្តង់ដានៃក្របខណ្ឌ ឬប្រព័ន្ធគុណវុឌ្ឍិជាតិ និងគុណវុឌ្ឍិដែលបានឯកភាពគ្នា។
៦. ត្រូវពណ៌នាពីប្រព័ន្ធធានាគុណភាពជាតិសម្រាប់ការអប់រំ និងបណ្ដុះបណ្ដាល ដោយផ្ដោតចំពោះក្របខណ្ឌ ឬប្រព័ន្ធគុណវុឌ្ឍិជាតិ។ ត្រូវបញ្ជាក់ឱ្យច្បាស់លាស់ពីការគាំទ្រគ្រប់ស្ថាប័ន/អង្គភាពទាំងអស់ដែលទទួលបន្ទុកក្នុងការធានាគុណភាពចំពោះលទ្ធផលនៃការផ្ទៀងផ្ទាត់។
៧. ដំណើរការនៃការផ្ទៀងផ្ទាត់ត្រូវបានបង្កើតឡើង ដោយអាជ្ញាធរមានសមត្ថកិច្ចសាធារណៈទទួលបន្ទុក និងត្រូវយល់ព្រមដោយភាគីពាក់ព័ន្ធសំខាន់ៗនៅក្នុងប្រព័ន្ធគុណវុឌ្ឍិ។
៨. ត្រូវមានការចូលរួមដោយអ្នកជំនាញមានបទពិសោធន៍លើផ្នែកគុណវុឌ្ឍិមកពីប្រទេសជាសមាជិកអាស៊ានផ្សេងទៀត ដែលមានបទពិសោធន៍នៅក្នុងដំណើរការផ្ទៀងផ្ទាត់ និងការធ្វើរបាយការណ៍។
៩. ត្រូវបោះពុម្ពផ្សាយរបាយការណ៍ទូលំទូលាយមួយ ដែលបង្ហាញពីការផ្ទៀងផ្ទាត់ និងភស្តុតាងគាំទ្របញ្ជាក់ដោយឡែកពីគ្នាទៅតាមលក្ខណវិនិច្ឆ័យនៃការផ្ទៀងផ្ទាត់នីមួយៗ ដោយស្ថាប័ន/អង្គភាពមានសមត្ថកិច្ចជាតិ។
១០. លទ្ធផលនៃការផ្ទៀងផ្ទាត់ ត្រូវបោះពុម្ពផ្សាយដោយលេខាធិការដ្ឋានអាស៊ាន និងដោយស្ថាប័ន/អង្គភាព មានសមត្ថកិច្ចសាធារណៈថ្នាក់ជាតិ។
១១. បន្ទាប់ពីដំណើរការផ្ទៀងផ្ទាត់រួចហើយ គ្រប់ស្ថាប័ន/អង្គភាពផ្តល់គុណវុឌ្ឍិ និងផ្តល់វិញ្ញាបនបត្រទាំងអស់ ត្រូវបានលើកទឹកចិត្តឱ្យបង្ហាញឯកសារយោងជាក់លាក់ ស្តីពីការផ្តល់គុណវុឌ្ឍិថ្មី វិញ្ញាបនបត្រ និងសញ្ញាបត្រដែលត្រូវនឹងកម្រិតក្របខណ្ឌគុណវុឌ្ឍិយោងអាស៊ាន។

ក្របខណ្ឌគុណវុឌ្ឍិយោងអាស៊ាន ពិតជាផ្តល់នូវភាសារួមមួយដែលត្រូវប្រើប្រាស់សម្រាប់ដំណើរការផ្ទៀងផ្ទាត់ និងស្វែងរកការយោគយល់គ្នាទៅវិញទៅមក នៃគុណវុឌ្ឍិ និងប្រព័ន្ធផ្តល់គុណវុឌ្ឍិសមត្ថភាពនីមួយៗ។ ស្ថាប័ន/អង្គភាព មានសមត្ថកិច្ចចាំបាច់ត្រូវផ្តល់ការបន្សុីគ្នានៃវាក្យសព្ទបច្ចេកទេសដែលត្រូវប្រើប្រាស់នៅក្នុងប្រព័ន្ធផ្តល់គុណវុឌ្ឍិសមត្ថភាពរបស់ខ្លួន និងក្របខណ្ឌគុណវុឌ្ឍិយោងអាស៊ានដែលគេចូលរួមក្នុងដំណើរការផ្ទៀងផ្ទាត់។

***បរិបទ***

ប្រព័ន្ធផ្តល់គុណវុឌ្ឍិសមត្ថភាពរបស់ប្រទេសជាសមាជិកអាស៊ានត្រូវបានបន្សុីគ្នា ឬដាក់បញ្ចូលនៅក្នុងក្របខណ្ឌគុណវុឌ្ឍិ និងប្រព័ន្ធគុណវុឌ្ឍិជាតិរបស់ប្រទេសជាសមាជិកអាស៊ាននីមួយៗ។ ទោះបីជា ប្រព័ន្ធផ្តល់គុណវុឌ្ឍិសមត្ថភាពរបស់ប្រទេសសមាជិកអាស៊ាននៅក្នុងគោលការណ៍ណែនាំទាំងនេះទាក់ទងនឹងរចនាសម្ព័ន្ធវិស័យសាធារណៈក៏ដោយ ក៏មិនរារាំងដល់រចនាសម្ព័ន្ធវិស័យឯកជន (ឧទាហរណ៍៖ សហគ្រាស) ក្នុងការចូលរួមក្នុងដំណើរការទទួលស្គាល់ឡើយ។

សម្រាប់ប្រទេសជាសមាជិកអាស៊ានដែលគ្មានក្របខណ្ឌគុណវុឌ្ឍិជាតិ ត្រូវបានទទួលស្គាល់ថាប្រព័ន្ធផ្តល់គុណវុឌ្ឍិសមត្ថភាពនេះ មានតួនាទីច្បាស់លាស់មួយនៅក្នុងការអភិវឌ្ឍធនធានមនុស្សរបស់ប្រទេសជាសមាជិកអាស៊ាននីមួយៗ។ ចំពោះប្រព័ន្ធទាំងនេះ លក្ខខណ្ឌតម្រូវសំខាន់នៃបរិបទចាំបាច់ដែលត្រូវបង្កើត ដើម្បីអាចចូលរួមនៅក្នុងដំណើរការផ្ទៀងផ្ទាត់បាន មានដូចជា៖

- ចំពោះក្របខណ្ឌជំនាញ តើមានការពិពណ៌នាអំពីសមត្ថភាពក្នុងកម្រិតនីមួយៗដែលបង្ហាញនូវភាពលំបាកនៃចំណេះដឹង និងជំនាញឬទេ?
- តើកម្រងសមត្ថភាពសម្រាប់ផ្តល់គុណវុឌ្ឍិត្រូវបានផ្តោតលើលទ្ធផលសិក្សាឬទេ?
- តើមានស្ថាប័ន/អង្គភាពមានសមត្ថកិច្ចមួយ ឬច្រើន ដែលត្រូវគ្រប់គ្រង ត្រួតពិនិត្យមើលប្រព័ន្ធផ្តល់គុណវុឌ្ឍិសមត្ថភាពឬទេ? ប្រសិនបើមានស្ថាប័ន/អង្គភាពមានសមត្ថកិច្ចលើសពីមួយ តើស្ថាប័ន/អង្គភាពមួយណានឹងដឹកនាំដំណើរការនោះ?
- តើប្រព័ន្ធធានាគុណភាពមានឯកសារច្បាស់លាស់ និងអនុវត្តបាន ដែលភាគីពាក់ព័ន្ធអាចយល់បានដែរឬទេ?
- តើអាចបង្កើតការបន្សុីគ្នារវាងក្របខណ្ឌជំនាញ និងក្របខណ្ឌគុណវុឌ្ឍិជាតិឬទេ?

គោលការណ៍ផ្ទៀងផ្ទាត់នៃក្របខណ្ឌគុណវុឌ្ឍិយោងអាស៊ាន (សេចក្តីព្រាងនៅឆ្នាំ២០១៥) បញ្ជាក់អំពីបុរេលក្ខខណ្ឌនៃការផ្ទៀងផ្ទាត់សំខាន់ៗមួយចំនួន ដែលចាំបាច់ត្រូវធ្វើការពិចារណាដោយប្រទេសជាសមាជិកនីមួយៗ មុននឹងអនុវត្តការផ្ទៀងផ្ទាត់ជាផ្លូវការ រួមមាន៖

- នៅក្នុងប្រទេសនីមួយៗមើលឃើញថា ក្របខណ្ឌគុណវុឌ្ឍិយោងអាស៊ាន ជំរុញឱ្យមានការបង្កើនកិច្ចសហប្រតិបត្តិការក្នុងតំបន់ ដែលកំពុងដំណើរការផ្សព្វផ្សាយ និងធ្វើកោសល្យវិច្ច័យលើទស្សនៈ និងគុណតម្លៃរបស់ក្របខណ្ឌគុណវុឌ្ឍិយោងអាស៊ាន។
- ការកសាងសមត្ថភាពកំពុងដំណើរការទាក់ទងនឹងការយល់ដឹង និងការប្រើប្រាស់ក្របខណ្ឌ គុណវុឌ្ឍិយោងអាស៊ាន រួមទាំងការបង្កើតច្រក និងកម្រិតនៃការពិគ្រោះយោបល់ផ្លូវការជាមួយទីភ្នាក់ងារ និងអង្គភាពពាក់ព័ន្ធនានា។
- រចនាសម្ព័ន្ធអភិបាលកិច្ច និងការគ្រប់គ្រងត្រូវបានបង្កើតឡើង ឬកំពុងបង្កើត ដែលរួមបញ្ចូលទាំងការកំណត់ទំនួលខុសត្រូវចំពោះការធ្វើការផ្ទៀងផ្ទាត់ ព្រមទាំងការបង្កើតគណៈកម្មការមានសមត្ថកិច្ច។
- ប្រសិទ្ធភាពការធានាគុណភាពក្នុងប្រព័ន្ធគុណវុឌ្ឍិ ការត្រួតពិនិត្យឡើងវិញលើប្រព័ន្ធធានាគុណភាពបច្ចុប្បន្ន ដើម្បីដាក់បញ្ចូលការប្រើប្រាស់លទ្ធផលសិក្សា និងក្របខណ្ឌគុណវុឌ្ឍិជាតិ។
- ប្រាកដថា ការបន្សុីគ្នាជាមួយបរិបទផ្សេងៗសម្រាប់ការធានាគុណភាព មានលក្ខណៈច្បាស់លាស់ដោយពិចារណានូវរបៀបដែលប្រព័ន្ធធានាគុណភាពជាតិ ប្រទាក់ក្រឡាជាមួយនឹងរចនាសម្ព័ន្ធ និងគោលការណ៍ក្របខណ្ឌគុណវុឌ្ឍិយោងអាស៊ាន ឧទាហរណ៍៖ ស្តង់ដាជាចំណុចគោលសម្រាប់ការរៀបចំកម្មវិធីសិក្សា។
- បំផុសចំណេះដឹងអំពីគម្រោងបន្សុីគ្នា ដែលតម្រូវឱ្យមានវិសាលភាព និងការយល់ដឹង ឧទាហរណ៍៖ កិច្ចព្រមព្រៀងទទួលស្គាល់ជំនាញគ្នាទៅវិញទៅមក (MRA) និងការតម្រូវគ្នាផ្សេងៗទៀត រួមទាំងការយល់ដឹងអំពីភាពឯករាជ្យនៃក្របខណ្ឌគុណវុឌ្ឍិយោងអាស៊ាន ជាមួយគម្រោងពាក់ព័ន្ធនានា។

ស្ថាប័ន/អង្គភាពមានសមត្ថកិច្ច ត្រូវធ្វើការពិចារណានូវរបៀបដែលពួកគេត្រូវបានដាក់បញ្ចូលនៅក្នុងដំណើរការផ្ទៀងផ្ទាត់ជាផ្លូវការ ដើម្បីផ្តល់នូវការទទួលស្គាល់ និងអត្ថប្រយោជន៍ច្រើនបំផុតដល់អតិថិជនរបស់ពួកគេ។

### *តើសេចក្តីណែនាំទាំងនេះ បន្សុីទៅនឹងក្របខណ្ឌគុណវុឌ្ឍិយោងអាស៊ាន និងការធ្វើសុខដុមនីយកម្មយ៉ាងដូចម្តេច?*

ប្រទេស ឬតំបន់មួយ ត្រូវប្រើប្រាស់លំដាប់នៃយុទ្ធសាស្ត្រ ដើម្បីសម្របសម្រួលការទទួលស្គាល់ជំនាញក្នុងការចល័តកម្លាំងពលកម្មជំនាញ និងសិស្ស/និស្សិត។ យុទ្ធសាស្ត្រទាំងនេះ ត្រូវរួមបញ្ចូលគ្នាដើម្បីផ្តល់នូវទំនុកចិត្តក្នុងការសម្រេចចិត្តដែលត្រូវធ្វើឡើងដោយអង្គភាពផ្តល់សេវាវាយតម្លៃសមត្ថភាព។

១. ចំពោះក្របខណ្ឌគុណវុឌ្ឍិយោងអាស៊ាន សកម្មភាពផ្ទៀងផ្ទាត់ និងរបាយការណ៍ថ្នាក់ជាតិនឹងផ្តល់ជំហានដំបូងផ្តើមនៅក្នុងការកសាងទំនុកចិត្តជាមួយប្រទេសជាសមាជិកអាស៊ាន។ របាយការណ៍នៃការផ្ទៀងផ្ទាត់របស់ប្រទេសជាសមាជិកអាស៊ានមួយ រួមមាន៖ ព័ត៌មាននៃក្របខណ្ឌគុណវុឌ្ឍិជាតិ ឬក្របខណ្ឌគុណវុឌ្ឍិវិស័យអប់រំ ការបន្សុីគ្នានៃកម្រិតក្នុងក្របខណ្ឌគុណវុឌ្ឍិជាតិទៅនឹងក្របខណ្ឌគុណវុឌ្ឍិយោងអាស៊ាន និងផ្តល់នូវទិដ្ឋភាពទូទៅមួយលើការរៀបចំអនុវត្តការធានាគុណភាពធៀបទៅនឹងគោលការណ៍គោល ដែលបានឯកភាពគ្នា។ ស្ថាប័ន/អង្គភាពមានសមត្ថកិច្ច គ្រឹះស្ថាន និងក្រុមនិយោជកដែលមានចំណាប់អារម្មណ៍ អាចប្រើប្រាស់ព័ត៌មាននេះ ដើម្បីផ្តល់ព័ត៌មានអំពីការអនុវត្តការទទួលស្គាល់របស់ពួកគេឱ្យកាន់តែប្រសើរ។

២. ប្រទេសជាសមាជិកអាស៊ាន ក៏កំពុងអភិវឌ្ឍផងដែរនូវកិច្ចព្រមព្រៀងការទទួលស្គាល់គ្នាទៅវិញទៅមកសម្រាប់មុខរបរ និងជំនាញផ្សេងៗ។ កិច្ចព្រមព្រៀងទាំងនេះ រួមមានស្តង់ដាមុខរបរថ្នាក់តំបន់សម្រាប់ប្រទេសជាសមាជិកអាស៊ានប្រើប្រាស់ជាចំណុចយោងមួយដើម្បីអភិវឌ្ឍស្តង់ដាសមត្ថភាព និងគុណវុឌ្ឍិ។ កិច្ចព្រមព្រៀងទទួលស្គាល់គ្នាទៅវិញទៅមក ផ្តល់នូវការប្រៀបធៀបស្តង់ដាសមត្ថភាព ដែលបានប្រើប្រាស់នៅក្នុងប្រទេសជាសមាជិកអាស៊ាននីមួយៗ និងកម្មវិធីសិក្សាដែលពាក់ព័ន្ធ (ឧទាហរណ៍៖ គុណវុឌ្ឍិ)។

៣. គោលការណ៍ណែនាំទាំងនេះ បង្កើតជាមូលដ្ឋាននៃការយល់ដឹងលើការធានាគុណភាពតាមរយៈស្ថាប័ន/អង្គភាពមានសមត្ថកិច្ច។ គោលការណ៍ណែនាំនេះ បានបញ្ជាក់លម្អិតពីគោលការណ៍ និងពិធីសារសម្រាប់ទីភ្នាក់ងារមានសមត្ថកិច្ច និងស្ថាប័ន/អង្គភាពផ្តល់សេវាវាយតម្លៃសមត្ថភាព។ គោលការណ៍ទាំងនេះ តម្រូវឱ្យស្ថាប័ន/អង្គភាព មានសមត្ថកិច្ចនៃប្រទេសជាសមាជិកអាស៊ានអនុវត្តការវាយតម្លៃផ្ទៃក្នុង និងពីផ្នែកខាងក្រៅ និងការធានាគុណភាពការផ្តល់សេវាវាយតម្លៃសមត្ថភាពតាមរយៈស្ថាប័ន/អង្គភាពផ្តល់សេវាវាយតម្លៃរបស់ពួកគេ។

ជាមួយយុទ្ធសាស្ត្រទាំងនេះ និងព័ត៌មានត្រូវបានផ្សព្វផ្សាយជាសាធារណៈ បណ្តាស្ថាប័ន/អង្គភាពមានសមត្ថកិច្ច គ្រឹះស្ថានសិក្សា និងនិយោជកកាន់តែមានទំនុកចិត្តខ្លាំងឡើងនៅក្នុងការធ្វើសេចក្តីសម្រេចចិត្តលើការទទួលស្គាល់។

## ឧបសម្ព័ន្ធ៖ ក្របខណ្ឌធានាគុណភាពអន្តរជាតិ

លក្ខណៈវិនិច្ឆ័យទី៦ នៃការផ្ទៀងផ្ទាត់ក្របខណ្ឌគុណវុឌ្ឍិយោងអាស៊ាន តម្រូវឱ្យបញ្ជាក់ពីប្រព័ន្ធធានាគុណភាពជាតិសម្រាប់ការអប់រំ និងបណ្តុះបណ្តាល ដែលផ្តោតទៅលើការបរិយាយពីក្របខណ្ឌគុណវុឌ្ឍិជាតិ ឬប្រព័ន្ធគុណវុឌ្ឍិជាតិ។ របាយការណ៍នៃការផ្ទៀងផ្ទាត់ចាំបាច់ត្រូវពន្យល់ពីប្រព័ន្ធធានាគុណភាពជាតិសំខាន់ៗ ដែលប្រតិបត្តិការនៅក្នុងប្រព័ន្ធអប់រំបណ្តុះបណ្តាល និងការផ្តល់គុណវុឌ្ឍិ។ ក្របខណ្ឌគុណវុឌ្ឍិយោងអាស៊ានស្នើឡើងនូវក្របខណ្ឌធានាគុណភាពចំនួនបី ដែលអាចត្រូវបានប្រើជាចំណុចគោល សម្រាប់ដំណើរការផ្ទៀងផ្ទាត់៖

- **សេចក្តីណែនាំរបស់បណ្តាញទីភ្នាក់ងារអន្តរជាតិសម្រាប់ការធានាគុណភាពក្នុងការអប់រំឧត្តមសិក្សា (INQAAHE) ស្តីពីការអនុវត្តល្អ នៅក្នុងការធានាគុណភាព**
- **ក្របខណ្ឌធានាគុណភាពការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈក្នុងកិច្ចប្រជុំកំពូលអាស៊ីបូព៌ា (EAS TVET QAF)**
- **ក្របខណ្ឌធានាគុណភាពអាស៊ាន។**

### *សេចក្តីណែនាំរបស់បណ្តាញទីភ្នាក់ងារអន្តរជាតិសម្រាប់ធានាគុណភាពក្នុងការអប់រំឧត្តមសិក្សា ស្តីពីការអនុវត្តល្អនៅក្នុងការធានាគុណភាព*

សេចក្តីណែនាំរបស់បណ្តាញទីភ្នាក់ងារអន្តរជាតិ សម្រាប់ធានាគុណភាពក្នុងការអប់រំឧត្តមសិក្សាមានបំណងលើកកម្ពស់ការអនុវត្តល្អ សម្រាប់ការធានាគុណភាពផ្ទៃក្នុង និង/ឬពីផ្នែកខាងក្រៅ។ ក្របខណ្ឌនេះត្រូវបានរៀបចំឡើងសម្រាប់គ្រប់ទីភ្នាក់ងារធានាគុណភាពទាំងអស់ប្រើប្រាស់។ សេចក្តីណែនាំរបស់បណ្តាញទីភ្នាក់ ងារអន្តរជាតិសម្រាប់ការធានាគុណភាពក្នុងការអប់រំឧត្តមសិក្សា ផ្តោតលើតួនាទីរបស់ទីភ្នាក់ងារធានាគុណភាពពីខាងក្រៅដោយបញ្ជាក់នូវកិច្ចការដូចខាងក្រោម៖

- ទីភ្នាក់ងារធានាគុណភាពពីខាងក្រៅ (EQAA)៖ គណនេយ្យភាព តម្លាភាព និងធនធាន
    - អភិបាលកិច្ច
    - ធនធាន
    - ការធានាគុណភាពទីភ្នាក់ងារធានាគុណភាពពីខាងក្រៅ
    - ការរាយការណ៍ព័ត៌មានជាសាធារណៈ។
- គ្រឹះស្ថានឧត្តមសិក្សា និងទីភ្នាក់ងារធានាគុណភាពពីខាងក្រៅ៖ ភាពទាក់ទងគ្នា ស្តង់ដាគុណភាព និងការត្រួតពិនិត្យផ្ទៃក្នុង
    - ទំនាក់ទំនងរវាងទីភ្នាក់ងារធានាគុណភាពពីខាងក្រៅ និងគ្រឹះស្ថានឧត្តមសិក្សា
    - លក្ខខណ្ឌតម្រូវរបស់ទីភ្នាក់ងារធានាគុណភាពពីខាងក្រៅ សម្រាប់ការប្រតិបត្តិរបស់គ្រឹះស្ថាន/កម្មវិធីអប់រំឧត្តមសិក្សា
    - លក្ខខណ្ឌតម្រូវរបស់ទីភ្នាក់ងារធានាគុណភាពពីខាងក្រៅសម្រាប់គ្រឹះស្ថានឧត្តមសិក្សា ស្វ័យវាយតម្លៃ និងការរាយការណ៍ទៅទីភ្នាក់ងារធានាគុណភាពពីខាងក្រៅ
- ការត្រួតពិនិត្យរបស់ទីភ្នាក់ងារធានាគុណភាពពីខាងក្រៅទៅលើគ្រឹះស្ថានឧត្តមសិក្សា៖ការវាយតម្លៃ ការសម្រេចចិត្ត និងបណ្តឹងតវ៉ា
    - ការវាយតម្លៃរបស់ទីភ្នាក់ងារធានាគុណភាពពីខាងក្រៅទៅលើគ្រឹះស្ថានឧត្តមសិក្សា និង/ឬកម្មវិធីអប់រំឧត្តមសិក្សា
    - ការសម្រេចចិត្ត
    - បណ្តឹងតវ៉ា
    - សកម្មភាពខាងក្រៅ៖ ការសហការជាមួយទីភ្នាក់ងារផ្សេងទៀត និងការអប់រំឆ្លងដែន/ឆ្លងកាត់ ព្រំដែន
    - ការសហការ
    - ការអប់រំឧត្តមសិក្សាឆ្លងដែន/ឆ្លងកាត់ព្រំដែន។

### *ក្របខណ្ឌធានាគុណភាព អ.ប.វ នៃកិច្ចប្រជុំកំពូលអាស៊ីបូព៌ា*

ក្របខណ្ឌធានាគុណភាពអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈនៃកិច្ចប្រជុំកំពូលអាស៊ីបូព៌ាមានមុខងារជាក្របខណ្ឌធានាគុណភាពយោងរួមមួយ។ ក្របខណ្ឌនេះ មិនជំនួស ឬប៉ុនប៉ងកំណត់ប្រព័ន្ធធានាគុណភាពថ្នាក់ជាតិនោះទេ ផ្ទុយទៅវិញ មានបំណងគាំទ្រ និងជាមគ្គុទ្ទេសក៍គំនិតផ្តួចផ្តើមនៅក្នុងការទំនាក់ទំនងគ្នាទៅនឹងការធានាគុណភាពនៅកម្រិតទីភ្នាក់ងារជាតិ។

ស្តង់ដាគុណភាពនៃក្របខណ្ឌធានាគុណភាពអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈនៃកិច្ចប្រជុំកំពូលអាស៊ីបូព៌ាត្រូវបានគាំទ្រដោយគោលការណ៍សំខាន់ៗចំនួនប្រាំដូចខាងក្រោម៖

- តម្លាភាព
- គណនេយ្យភាព
- វិធីសាស្ត្រនៃការកែលម្អជាប្រចាំ
- ភាពទន់ភ្លន់ និងភាពឆ្លើយតប
- ភាពអាចប្រៀបធៀបបាន

ស្តង់ដាគុណភាពនៃក្របខណ្ឌធានាគុណភាពអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈនៃកិច្ចប្រជុំកំពូលអាស៊ីបូព៌ា ត្រូវអនុវត្តនៅពីរកម្រិត និងរួមបញ្ចូលលក្ខខណ្ឌតម្រូវរបស់ទីភ្នាក់ងារ និងលក្ខខណ្ឌតម្រូវរបស់ស្ថាប័ន/អង្គភាពផ្តល់សេវា ដែលបានសំណូមពរ។ ក្របខណ្ឌនោះ រួមមាន៖

- ស្តង់ដាធានាគុណភាពសម្រាប់ទីភ្នាក់ងារ
- គំរូស្តង់ដាធានាគុណភាពសម្រាប់អង្គភាពផ្តល់សេវា

ទាំងស្តង់ដាគុណភាពរបស់ទីភ្នាក់ងារ និងស្តង់ដាធានាគុណភាពសម្រាប់ស្ថាប័ន/អង្គភាពផ្តល់សេវា ត្រូវបានពណ៌នា ក្នុងវាក្យសព្ទបច្ចេកទេស ដូចខាងក្រោម៖

- អភិបាលកិច្ច
- ការអនុម័ត និងការត្រួតពិនិត្យលើអង្គភាពផ្តល់សេវា និង
- ការអនុម័ត និងការត្រួតពិនិត្យតាមដានលើស្តង់ដាសមិទ្ធផល ឧទាហរណ៍៖ គុណវុឌ្ឍិ កម្រងសមត្ថភាពសម្រាប់ផ្តល់គុណវុឌ្ឍិ

ក្របខណ្ឌនោះ ក៏រួមបញ្ចូលផងដែរនូវសូចនាករគុណភាពដើម្បីគាំទ្រដល់ដំណើរការវាយតម្លៃ និងការកែលម្អជាប្រចាំរបស់ទីភ្នាក់ងារ និងស្ថាប័ន/អង្គភាពផ្តល់សេវា។ សូចនាករអាចត្រូវបានប្រើដើម្បីវាយតម្លៃការប្រតិបត្តិវិស័យ អ.ប.វ ទាំងកម្រិតជាតិ និងកម្រិតអង្គភាពផ្តល់សេវា។

ក្របខណ្ឌធានាគុណភាពអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈនៃកិច្ចប្រជុំកំពូលអាស៊ីបូព៌ាផ្តល់នូវលក្ខខណ្ឌតម្រូវសម្រាប់សូចនាករគុណភាពដូចខាងក្រោម។

**តារាងទី ៧៖ សូចនាករគុណភាពនៃក្របខណ្ឌធានាគុណភាព អ.ប.វ នៃកិច្ចប្រជុំកំពូលអាស៊ីបូព៌ា**

| | ទិដ្ឋភាព (Aspect) | | | |
|---|---|---|---|---|
| | បរិបទ (Context) | ធាតុចូល (Input) | ដំណើរការ (Process) | លទ្ធផល/ផលិតផល (Output/Product) |
| ប្រធានបទ | ប.១ ចរិតលក្ខណៈរបស់អ្នកសិក្សា<br>ប.២ ចរិតលក្ខណៈ របស់អង្គភាពផ្តល់សេវា<br>ប.៣ ច្រក/ផ្លូវសម្រាប់អ្នកសិក្សា<br>ប.៤ ការទទួលស្គាល់ការសិក្សាដែលមានពីមុននៅក្នុងគ្រប់បរិបទ<br>ប.៥ ឥទ្ធិពលទីផ្សារការងារ | ធ.១ ធនធាន និងការគាំទ្រការសិក្សា<br>ធ.២ ការរៀបចំកម្មវិធី និងការអភិវឌ្ឍកម្មវិធីសិក្សា<br>ធ.៣ គុណភាពនៃបុគ្គលិកបង្រៀន | ដ.១ ការបណ្តុះបណ្តាល និងការវាយតម្លៃសមត្ថភាព | ល.១ វឌ្ឍនភាព និងការសម្រេចបានរបស់អ្នកសិក្សា<br>ល.២ ភាពអាចប្រៀបធៀបបាននៃស្តង់ដាសមិទ្ធផល<br>ល.៣ គោលដៅរបស់អ្នកបញ្ចប់ការសិក្សា<br>ល.៤ ការពេញចិត្តរបស់ភាគីពាក់ព័ន្ធ |

*ប្រភព៖* ***EAS TVET QAF 2012***

## *ក្របខណ្ឌធានាគុណភាពអាស៊ាន*

ក្របខណ្ឌធានាគុណភាពអាស៊ាន នឹងបម្រើជាចំណុចយោងរួមសម្រាប់ទីភ្នាក់ងារធានាគុណភាព និងគ្រឹះស្ថានសិក្សា ខណៈដែលពួកគេខំប្រឹងប្រែង ដើម្បីធ្វើឱ្យប្រព័ន្ធធានាគុណភាព វប្បធម៌ និងប្រពៃណីផ្សេងៗគ្នានៅក្នុងតំបន់មានសុខដុមនីយកម្ម។

ក្របខណ្ឌនេះ ប្រើប្រាស់គោលការណ៍ទូទៅ និងសេចក្ដីថ្លែងការណ៍ស្ដីពីការអនុវត្តល្អ។ ក្របខណ្ឌនោះមិនមែនជាការដាក់បញ្ញត្តិនោះទេ គោលបំណង គឺដើម្បីលើកកម្ពស់ការអនុវត្តការធានាគុណភាពផ្ទៃក្នុងនិងពីផ្នែក
ខាងក្រៅឱ្យកាន់តែល្អប្រសើរ។

ក្របខណ្ឌធានាគុណភាពនេះ បានផ្អែកទៅលើបួនចំណុច គឺ៖

១. ទីភ្នាក់ងារធានាគុណភាពពីខាងក្រៅ (EQAA)
២. ដំណើរការធានាគុណភាពពីខាងក្រៅ (EQA)
៣. ការធានាគុណភាពក្នុងគ្រឹះស្ថានសិក្សា
៤. ក្របខណ្ឌគុណវុឌ្ឍិជាតិ

ចំណុចទាំងនេះ ត្រូវបានលម្អិតបន្ថែមទៀតនៅក្នុងលក្ខណវិនិច្ឆ័យ។

## ឯកសារយោង


អាស៊ាន (២០០៧) *ផែនការសហគមន៍សេដ្ឋកិច្ចអាស៊ាន ខែសីហា ឆ្នាំ២០១៥ តាមរយៈគេហទំព័រ៖* http://www.asean.org/archieve/5187-10.pdf

អាស៊ាន(២០០៧) *ធម្មនុញ្ញរបស់សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍*

*ក្របខណ្ឌគុណវុឌ្ឍិយោងអាស៊ាន (២០១៥)* លេខាធិការដ្ឋានអាស៊ាន ទីក្រុងហ្សាការតា។

*គោលការណ៍ណែនាំយោងតាមក្របខណ្ឌគុណវុឌ្ឍិយោងអាស៊ាន* (សេចក្តីព្រាងឆ្នាំ ២០១៥) លេខាធិការដ្ឋានអាស៊ាន ទីក្រុងហ្សាការតា។

រដ្ឋាភិបាលអូស្ត្រាលី ឆ្នាំ២០០៧ *ស្តីពីការពង្រឹងអភិបាលកិច្ច* ប្រព័ន្ធច្បាប់នៃប្រទេសអូស្ត្រាលី នៃទីក្រុងកង់បារ៉ា (Canberra)។

ស្តង់ដាអូស្ត្រាលី/ញូហ្ស៊ីលែន (AS/NZS) *ISO 9000:2006 ប្រព័ន្ធគ្រប់គ្រងគុណភាព – មូលដ្ឋានគ្រឹះ និងវាក្យសព្ទ* ខែមិថុនា ឆ្នាំ២០០៦។

លោកស្រី Bateman, A & លោក Coles, M 2015 *ក្របខណ្ឌគុណវុឌ្ឍិយោងអាស៊ាន និងក្របខណ្ឌគុណវុឌ្ឍិជាតិ៖ State of play*, SHARE-ASEAN Secretariat, ទីក្រុងហ្សាការតា។

អត្ថបទទស្សនទាន របស់លោកស្រី Bateman, A, Keating, J, Gillis, S, Dyson, C, Burke, G & Coles, M (ឆ្នាំ ២០១២) *Concept Paper: ក្របខណ្ឌធានាគុណភាពអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈនៃកិច្ចប្រជុំកំពូលអាស៊ីបូព៌ា ច្បាប់ទី២* រដ្ឋាភិបាលអូស្ត្រាលី ទីក្រុងកង់បារ៉ា (Canberra)។

CEDEFOP (២០១១) *សទ្ទានុក្រម៖ គុណភាពក្នុងការអប់រំ និងបណ្តុះបណ្តាល* នៃការិយាល័យសហគមន៍ អឺរ៉ុប ប្រទេសលុចសំបួរ។

Coles, M, Keevy, J, Bateman, A and Keating, J, (2014), 'Flying Blind: សនិទានភាពគោលនយោបាយសម្រាប់ក្របខណ្ឌគុណវុឌ្ឍិជាតិ និងរបៀបដែលពួកគេមានទំនោរទៅរកការវិវត្ត' *ទិនានុប្បវត្តិអន្តរជាតិនៃការអប់រំបន្តនិងការសិក្សាពេញមួយជីវិត* ភាគ ៧ លេខ ១ (២០១៤)។

លោក Coles, M. and Werquin, P. (២០០៦) *ប្រព័ន្ធគុណវុឌ្ឍិ៖ ស្ពានចម្លងសម្រាប់ការសិក្សាពេញមួយជីវិតរបស់* OECD នៅទីក្រុងប៉ារីស។

Gillis, S & Bateman, A (២០១៥) *ក្រមនៃការអនុវត្តវិជ្ជាជីវៈ ចំពោះការគ្រប់គ្រងគុណភាពនៃការវាយតម្លៃសមត្ថភាព* របស់រដ្ឋាភិបាលអូស្ត្រាលី ទីក្រុងកង់បារ៉ា។

*គោលការណ៍ណែនាំរបស់ INQAAHE ស្តីពីការអនុវត្តល្អ ក្នុងការធានាគុណភាព* (២០០៧) លេខាធិការដ្ឋានរបស់ INQAAHE។

ការិយាល័យអន្តរជាតិខាងការងារ (២០១៦) *គោលការណ៍គំរូសម្រាប់ការអភិវឌ្ឍគំរូស្តង់ដាសមត្ថភាពតំបន់* នៃការិយាល័យអង្គការអន្តរជាតិខាងការងារ (ILO) ទីក្រុងហ្សឺណែវ។

*ISO/IEC 17024:2012 អនុលោមភាពនៃការវាយតម្លៃ – លក្ខខណ្ឌតម្រូវទូទៅសម្រាប់ស្ថាប័ន/អង្គភាព ផ្តល់វិញ្ញាបនបត្រ* របស់អង្គការស្តង់ដាអន្តរជាតិ (ISO) ប្រទេសស្វីស។

*គោលការណ៍ និងសេចក្តីថ្លែងការណ៍នៃក្របខណ្ឌធានាគុណភាពអាស៊ាន* (សេចក្តីព្រាង ឆ្នាំ២០១៥) លេខាធិការដ្ឋានអាស៊ាន ទីក្រុងហ្សាការតា។

អង្គការយូណេស្កូ (២០១២) *អនុសញ្ញាតំបន់អាស៊ីប៉ាស៊ីហ្វិក ស្តីពីការទទួលស្គាល់គុណវុឌ្ឍិក្នុងការអប់រំឧត្តមសិក្សា* របស់អង្គការយូណេស្កូ ទីក្រុងបាងកក។

ក្រុមការងារធនាគារពិភពលោក (សេចក្តីព្រាងឆ្នាំ (២០១៥) *ក្របខណ្ឌគុណវុឌ្ឍិជាតិ និងស្តង់ដាជាតិ សមត្ថភាព នៅក្នុងតំបន់អាស៊ីបូព៌ា-ប៉ាស៊ីហ្វិក៖ របាយការណ៍សំយោគ* របស់ក្រុមធនាគារពិភពលោកទីក្រុងវ៉ាស៊ីនតោន។

# ស្ថាប័ន/អង្គភាពមានសមត្ថកិច្ចរបស់ប្រទេសជាសមាជិកអាស៊ាន

***ប្រទេសប្រ៊ុយណេ***
ក្រសួងអប់រំ - http://moe.gov.bn/bdnac

***ប្រទេសកម្ពុជា***
គណៈកម្មាធិការជាតិបណ្ដុះបណ្ដាល - http://www.ntb.gov.kh/

***ប្រទេសឥណ្ឌូនេស៊ី***
អាជ្ញាធរផ្ដល់វិញ្ញាបនបត្រវិជ្ជាជីវៈអាជីពប្រទេសឥណ្ឌូនេស៊ី /Badan Nasional Sertifikasi Profesi (BNSP) www.bnsp.go.id
ក្រសួងធនធានមនុស្ស (សម្របសម្រួលលើការអភិវឌ្ឍស្តង់ដាជាតិសមត្ថភាព) www.naker.go.id

***ប្រទេសឡាវ***
នាយកដ្ឋានអភិវឌ្ឍន៍ជំនាញ និងមុខរបរ (DoSDE)
ក្រសួងការងារ និងសុខមាលភាពសង្គមនៃប្រទេសឡាវ - www.molsw.gov.la/

***ប្រទេសម៉ាឡេស៊ី***
ទីភ្នាក់ងារគុណវុឌ្ឍិម៉ាឡេស៊ី (MQA) - www.mqa.gov.my
នាយកដ្ឋានអភិវឌ្ឍន៍ជំនាញ (DSD) - www.dsd.gov.my

***ប្រទេសភូមា (មីយ៉ាន់ម៉ា)***
អាជ្ញាធរជាតិស្តង់ដាជំនាញ - www.nesdmyanmar.org

***ប្រទេសហ្វីលីពីន***
អាជ្ញាធរអប់រំបច្ចេកទេស និងអភិវឌ្ឍជំនាញ (TESDA) - http://www.tesda.gov.ph/

***ប្រទេសសិង្ហបុរី***
ក្រសួងអប់រំនៃប្រទេសសិង្ហបុរី - www.moe.gov.sg

***ប្រទេសថៃ***
នាយកដ្ឋានអភិវឌ្ឍន៍ជំនាញ - www.dsd.go.th

***ប្រទេសវៀតណាម***
នាយកដ្ឋានអភិវឌ្ឍន៍ជំនាញ នៃអគ្គនាយកដ្ឋានបណ្ដុះបណ្ដាលវិជ្ជាជីវៈ ក្រសួងការងារ សង្គមកិច្ច និងអតីតយុទ្ធជន - http://www.molisa.gov.vn/en/Pages/Home.aspx

បកប្រែ និងកែសម្រួលដោយក្រុមការងារ នៃក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ
ខែ សីហា ឆ្នាំ២០១៩

ASSOCIATION OF SOUTHEAST ASIAN NATIONS

@ASEAN ASEAN ASEAN www.asean.org